ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 16-Jan-2013, 10:00
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០៤នាទី**

**សវនាការលើកទី១៤៦**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក ម៉ាតេអូ គ្រីប៉ា*(Mr.Matteo CRIPPA)*

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារារស្មី

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ(*Mr.Victor KOPPE*)

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក អាកទួរ វែកគែន

(*Mr. Arthur VERCKEN*)

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស

(*Mr.Michael KARNAVAS*)

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

(*Ms. Elisabeth SIMONNEAU-FORT*)

លោក សំ សុគង់

លោក ឡោ ជុនធី

លោកស្រី បេនី យេ (*Ms. Beini YE*)

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក ច័ន្ទ តារាស្មី | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល | បារាំង |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក អាកទួរ វែកគែន | បារាំង |
| លោក សុន អរុណ | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោក សំ សុគង់ | ខ្មែរ |
| លោកស្រី បេនី យេ | អង់គ្លេស |
| លោក អ៊ុង រ៉េន (TCW-754) | ខ្មែរ |
| លោក ឆោម សែ (TCW-100) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី÷ លោក អ៊ុំ រ៉ែន** (TCW-754)

សួរបន្តដោយ លោក អាកទួរ វែកគែន ផ្តើមពី៖............................................................ទំព័រ ២

**ការសួរសំណួរទៅសាក្សី÷ លោក ឆោម សែ** (TCW-100)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី៖............................................................ទំព័រ ២២

សួរដោយលោក ច័ន្ទ តារាស្មី ផ្តើមពី៖ ............................................................ទំព័រ ២៧

សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្តើមពី៖..................................................ទំព័រ ៥១

# កិច្ចដំណើរការនីតិវិធី

[០៩:០៤:៤០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ នៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ អង្គជំនុំជម្រះនឹងបន្តស្ដាប់សក្ខីកម្មសាក្សី អ៊ុំង រ៉េន បញ្ចប់ នឹងចាប់ផ្ដើមស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-100។

លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការថ្ងៃនេះ គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះមានវត្តមាន លើកលែងតែលោក គង់ សំអុន មេធាវីជាតិការពារក្ដីឲ្យលោក ខៀវ សំផន និងលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត មេធាវីនាំមុខអន្តរជាតិ តំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីអវត្តមាន ដោយមូលហេតុមានធុរៈផ្ទាល់ខ្លួន។ ចំណែកជនជាប់ចោទ អៀង សារី និង នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ដោយមូលហេតុសុខភាព។ ហើយសាក្សីដែលត្រូវបន្តផ្ដល់សក្ខីកម្មនៅថ្ងៃនេះ គឺលោក អ៊ុំង រ៉េន លោកមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការ។

សាក្សីបន្ទាប់ដែលត្រូវផ្ដល់សក្ខីកម្ម គឺសាក្សីដែលមានរហស្សនាម TCW-100។ សាក្សីរូបនេះមានវត្តមាននៅក្នុងបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សាក្សីរូបនេះបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានជាប់ទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងបីរូប គឺលោក នួន ជា, អៀង សារី និង ខៀវ សំផន ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្ដីនេះទេ។ ហើយគាត់បានធ្វើសម្បថរួចហើយនៅចំពោះមុខរូបសំណាកលោកតាដំបងដែកកាលពីព្រឹកមិញនេះ។ សាក្សីរូបនេះនឹងមានមេធាវីប្រឹក្សា គឺលោកមេធាវី លឹម ប៊ុនហេង។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី សែ កុលវុឌ្ឍី។

នៅព្រឹកមិញនេះ អង្គជំនុំជម្រះបានទទួលរបាយការណ៍ពីលោកវេជ្ជបណ្ឌិតប្រចាំការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបានពិនិត្យសុខភាពរបស់លោក នួន ជា មុនពេលសវនាការនេះ និងបានកត់សម្គាល់ឃើញថា លោក នួន ជា មានបញ្ហាសុខភាព ហើយលោកគ្រូពេទ្យបានផ្តល់អនុសាសន៍ថា គាត់មិនអាចចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះបានទេ។ ប៉ុន្តែលោក នួន ជា គាត់អាចចូលរួមសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះបាន។

[០៩:០៨:១៣]

ដើម្បីជៀសវាងការពន្យារពេល និងដើម្បីប្រយោជន៍យុត្តិធម៌ ដោយផ្អែកលើរបាយការណ៍របស់លោកវេជ្ជបណ្ឌិតប្រចាំការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះបង្គាប់ឲ្យលោក នួន ជា ចូលរួមសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញ១ថ្ងៃនេះ។ ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះអាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយដែលស្ថិតនៅក្រោមសាលសវនាការនេះ សម្រាប់រយៈពេលនៃកិច្ចដំណើរការសវនាការពេញ១ថ្ងៃនេះ។

ជាកិច្ចបន្តអង្គជំនុំជម្រះ សូមផ្តល់វេទិកាជូនទៅមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការបន្តតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

[០៩:០៩:០៥]

**លោក អាកទួរ វ៉េកកែន៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយបន្តលោក អាកទួរ វ៉េកកែន៖**

**ស៖** លោកសាក្សីកាលពីម្សិលមិញ យើងបានផ្អាកសវនាការនៅពេលដែលខ្ញុំព្យាយាមសួរចង់ដឹងអំពីថ្ងៃដែលលោកទៅស្តាតអូឡាំពិក ដើម្បីចូលរួមពិធីបុណ្យពាក់ព័ន្ធទៅនឹងការបង្កើតកងពល៨០១។ តើនៅពេលនុំងលោកនៅ ស្នាក់នៅមន្ទីរពេទ្យ ឬក៏លោកចេញពីមន្ទីរពេទ្យហើយដើម្បីទៅចូលរួមនៅភ្នំពេញនោះ? នេះជាសំណួរដែលខ្ញុំសួរដែលឡើងវិញម្តងទៀតនៅព្រឹកថ្ងៃនេះ ដើម្បីកំណត់ពេលវេលាឲ្យបានច្បាស់ ថាតើពិធីនោះប្រព្រឹត្តនៅពេលណា? អ៊ីចឹងខ្ញុំចង់ដឹងថា ពេលនុំងលោកនៅសម្រាកមន្ទីរពេទ្យ

ហើយ ឬក៏លោកចេញពីមន្ទីរពេទ្យ ហើយឬក៏លោកបានទៅជួបកូនចៅរបស់លោកនៅភ្នំពេញរួច ហើយ?

**លោក អ៊ុង វ៉េន៖**

**ឆ៖** ពេលនោះខ្ញុំបានចេញពីមន្ទីរពេទ្យហើយ ខ្ញុំបានទៅពិគ្រោះជាមួយរងខ្ញុំនៅកន្លែងខាងលិច ពហុកីឡាដ្ឋាន។

**ស៖** ប្រសិនបើលោកចាំ លោកអាចឆ្លើយ ប៉ុន្តែបើលោកមិនចាំទេ ក៏មិនអីដែរ ព្រោះថាហេតុការណ៍នោះបានកើតឡើងយូរមកហើយ។ គឺថាមានរយៈពេលប៉ុន្មាន រយៈពេលរវាងលោកចេញពីមន្ទីរពេទ្យ ហើយនិងពិធីដែលប្រព្រឹត្តទៅនៅស្តាតអូឡាំពិកនោះ តើមានរយៈពេលប៉ុន្មានដែរ?

[០៩:១១:០២]

**ឆ៖** ខ្ញុំមិនចាំបាន គឺថាមានរាប់ថ្ងៃខែអីទេ នេះទេ ប៉ុន្តែគ្រាន់តែថាពីពេលដែលខ្ញុំមកចេញពីពេទ្យមកនៅខាងលិចស្តាតអូឡាំពិកនេះ ទម្រាំនឹងចាត់តាំងហ្នឹងវាយូរដែរ។

**ស៖** បាទ ពិធីបុណ្យនោះ តើគេកោះហៅអ្នកណាខ្លះឱ្យចូលរួមនោះ? ខ្ញុំចង់ដឹងថាតើមនុស្សប្រភេទណាខ្លះដែលចូលរួមនៅក្នុងនុំង គឺថាអ្នកនយោបាយ ជនស៊ីវិល ឬក៏អ្នកយោធា ឬក៏ចម្រុះគ្នា? តើលោកអាចបញ្ជាក់បានទេថា មនុស្សប្រភេទណាខ្លះដែលចូលរួមនៅក្នុងពិធីនៅស្តាតអូឡាំពិកនោះ?

**ឆ៖** បាទ គឺដូចខ្ញុំបានបញ្ជាក់ពីថ្ងៃមុនហើយ គឺមានតែកម្លាំងកងពល គឺចាប់តាំងពីវរសេនាតូចអនុសេនាធំឡើងមកលើ គឺថាចូលទៅស្តាប់ការចាត់តាំង -- រៀបរយការចាត់តាំង។

**ស៖** នៅពេលដែលលោកសហាចៅក្រមស៊ើបអង្កេតសួរសម្ភាសលោក ហើយនិងនៅក្នុងតុលាការនេះផងដែរ លោកបានលើកឈ្មោះអ្នកនយោបាយ អ្នកដឹកនាំនយោបាយដែលមានវត្តមាននៅក្នុងពិធីនោះ ហើយលោកបាន -- មិនបានលើកឡើងនូវឈ្មោះរបស់លោក ខៀវ សំផន ទេ។ ប្រសិនបើយើងស្តាប់ខ្សែអាត់សម្ភាសលោក ដោយអ្នកស៊ើបអង្កេតតុលាការនោះ គឺថានៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៩ ដែលមានលេខកូដ D232/34.4 លោកឆ្លើយយ៉ាងច្បាស់ថា "លោក ខៀវ សំផន មិនមានវត្តមាននៅក្នុងពិធីនោះទេ"។ ដូច្នេះតើលោកនៅរក្សាចម្លើយរបស់លោកដដែលទេ ថាលោក ខៀវ សំផន មិនមានវត្តមាននៅក្នុងពិធីនោះទេ?

[០៩:១៣:២៩]

**ឆ៖** បាទ ខ្ញុំនៅតែរក្សាចម្លើយរបស់ខ្ញុំ គឺពេលនោះគឺ បានជាខ្ញុំនៅចាំថា ខ្ញុំដឹងច្បាស់ថា ប៉ុល

ពត, អៀង សារី, នួន ជា ហើយ សុន សេន តែប៉ុណ្ណោះឯង។ នេះដែលខ្ញុំស្គាល់។ ហើយក្នុងនោះទៀត ខ្ញុំឃើញបងៗទាំងអស់ដែរ ប៉ុន្តែខ្ញុំមិនស្គាល់ មិនដឹងជាឈ្មោះអីៗ ដូច្នេះខ្ញុំស្គាល់ប៉ុនណា ខ្ញុំនិយាយប៉ុណ្ណោះ។ ព្រោះតាមពិតគឺ ដូចលោក ខៀវ សំផន ណេះខ្ញុំមិនដែលស្គាល់ផងទេ ហើយមកដល់ភ្នំពេញហើយក៏ខ្ញុំមិនដែលស្គាល់គាត់ ឲ្យខ្ញុំចាំយ៉ាងម៉េច។ ដូច្នេះខ្ញុំស្គាល់ ខ្ញុំនិយាយតាមខ្ញុំដឹង។

**ស៖** ចុះអ្នកដែលធ្វើបទឧទ្ទេសនាមនៅក្នុងឱកាសនោះ តើគេមានប្រាប់ឈ្មោះទេ ថាឈ្មោះអ្វីដែរ?

**ឆ៖** បាទ ប្រាប់អ្នកឧទ្ទេសនាមកាន់កម្មវិធី គេប្រាប់ឈ្មោះដែរ ប៉ុន្តែខ្ញុំចាំតែបី ខ្ញុំនិយាយតែត្រឹមបីបួនហ្នឹងឯង។

[០៩:១៥:០០]

**ស៖** តើកម្មវត្ថុនៃការជួបជុំគ្នានៅក្នុងពិធីនោះ គឺអ្វីដែរ? គេមានប្រាប់ទេ ថាចូលរួមនៅក្នុងពិធីនោះ គឺដើម្បីអ្វី?

**ឆ៖** បាទ ក្នុងកម្មវិធីនោះ ដើម្បីរៀបចំចាត់តាំងកងពល១៤ គឺបញ្ចូលគ្នា ច្របាច់គ្នាជាមួយ គឺដើម្បីទៅរតនគិរី។

**ស៖** ហើយចុះពេលចប់ពិធីនោះទៅ តើរយៈពេលប៉ុន្មានដែលលោកចេញទៅបំពេញភារកិច្ចថ្មីនោះ តើរយៈពេលយូរទេ បន្ទាប់ពីពិធីនោះទៅ លោកអាចបានកំណត់ទេ ចំនួន អាចជាចំនួនថ្ងៃ ចំនួនសប្តាហ៍ បន្ទាប់ពីចប់ពិធីហ្នឹងទៅ ហើយលោកក៏ចេញដំណើរទៅកាន់មុខតំណែងថ្មីនោះ?

[០៩:១៦:១៤]

**ឆ៖** បាទ ខ្ញុំសូមឆ្លើយនឹងសំណួរនេះ គឺក្រោយពីចប់ប្រកាសចាត់តាំងកងពលទៅ គឺក្នុងអង្គភាពដែលរៀបចំនេះនីមួយៗ គឺមានភារកិច្ចគឺនយោបាយកងធំមួយៗ ហើយវរសេនាតូចនីមួយៗគ្រប់វរសេនាធំទាំងអស់ហ្នឹង គឺចុះទៅតាមមុខព្រួញដើម្បីពិនិត្យសមរភូមិ រៀបចំកន្លែងរស់នៅរបស់កងទ័ពដែលនៅភ្នំពេញនៅឡើយ មិនទាន់ទៅ។ ដូច្នេះ ទៅរៀបចំជាមុន។

**ស៖** ហើយចុះលោកនោះ បន្ទាប់ពីពិធីបុណ្យហ្នឹងហើយនោះ ប៉ុន្មានថ្ងៃដែលលោកចេញទៅខេត្តនោះ?

**ឆ៖** តាមខ្ញុំចាំ គឺ១៥ថ្ងៃ បានចេញទៅ។

**ស៖** ហើយចុះកូនទាហានរបស់លោកនោះ ទៅជាមួយលោកទេ ពេលនុ៎ង?

**ឆ៖** ទៅ ទៅជាមួយ។ ទៅជាមួយនោះ គឺមានតែវរសេនាតូច អនុសេនាតូច អនុសេនាធំទេ ដើម្បីទៅរៀបចំកន្លែងនោះ ហើយរៀបចំបោះកន្លែងណាៗអី គេរៀបចំជាស្រេច ដល់ពេលកម្លាំងទៅដល់ គេដឹងថា កន្លែងគេនៅត្រង់ណោះៗ។

[០៩:១៧:៥៧]

**ស៖** ដូច្នេះគឺថាលោកចាកចេញទៅនោះ គឺថា១៥ថ្ងៃក្រោយពិធី ហើយចុះកូនចៅរបស់លោកនោះចាកចេញទៅនុ៎ង ប្រហែលប៉ុន្មានថ្ងៃដែរ បន្ទាប់ពីបញ្ចប់ពិធីនុ៎ង?

**ឆ៖** បាទ តាមៗខ្ញុំចាំ គឺពីព្រោះពេលនោះ ទឹកៗនៅ ទន្លេនៅនេះនៅឡើយ គឺថា ប្រហែលជាខែ១០ កម្លាំងដែលចេញទៅ។

**ស៖** ដូច្នេះ តើកងទ័ពទាំងអស់នោះ ត្រូវការពេលវេលាប៉ុន្មានដែរ ដើម្បីចាកចេញពីភ្នំពេញទៅដល់កន្លែងចាត់តាំងថ្មីនោះ? អាចជាប៉ុន្មានម៉ោង? ប៉ុន្មានថ្ងៃ ឬប៉ុន្មានសប្តាហ៍ដែរ?

**ឆ៖** បាទ គឺពេលនោះ គឺគ្មានមធ្យោបាយទេ មានកង់ មានអី គឺទៅដល់ពោធិ៍ថ្ម -- គេហៅថ្មគ្រែ -- ភូមិថ្មគ្រែ ក្រចេះហ្នឹង គឺខ្ទង់ខែ១១ បាទ ខ្ទង់ខែ១១ ដល់ថ្មគ្រែ ហើយសម្រាកហ្នឹងបីបួនថ្ងៃទៅ ទម្រាំមានកម្លាំង ហើយអូសកង់ដើរខ្លះ អីខ្លះអីចឹងទៅ ទៅដល់ស្ទឹងត្រែង ប្រហែលជាថ្ងៃ១៥ ខែ១២ បាទ។ ចោលកម្លាំងរតេករតាកខ្លះនៅតាមផ្លូវ គ្រុនឈឺអីអីចឹងទៅ នៅ គេហៅថា ភូមិគីឡូ៨ខាងកើតស្ទឹងត្រែង ហើយកម្លាំងខ្លះគឺសម្រុកឲ្យដល់ទិសដៅ ដើម្បីរៀបចំកម្លាំង ដឹងកន្លែងនៅយ៉ាងណាយ៉ាងណាហើយ គឺរៀបចំមួយចំនួនច្រូតស្រូវ រៀបចំផ្ទះសម្បែង។ ក្នុងរៀបចំផ្ទះសម្បែងទៀត រកកម្លាំងមួយចំនួនមើលកន្លែងធ្វើស្រែ ធ្វើចម្ការដើម្បីដោះស្រាយជីវភាពសម្រាប់ក្នុងកងទ័ព។

**ស៖** ប្រសិនបើខ្ញុំស្តាប់មិនច្រឡំនោះទេ គឺថាការធ្វើដំណើរហ្នឹងគឺថាវែងណាស់ បើយើងរាប់មើលទៅនោះ តើអីចឹងទេ?

**ឆ៖** បាទ។

**ស៖** ឥឡូវត្រឡប់មកនិយាយអំពីពិធីនោះវិញ។ បើតាមលោកដឹងនោះ តើមានពិធីបុណ្យប្រភេទនេះច្រើនទេនៅស្តាតអូឡាំពិកនោះ ដើម្បីប្រមូលផ្តុំយោធាសម្រាប់បង្កើតកងពល៨០១នោះ ឬក៏មានតែពិធីតែមួយហ្នឹងទេសម្រាប់បង្កើតហ្នឹង ឬក៏មានពិធីច្រើនដងដើម្បីអាចឈានទៅដល់ការបង្កើតកងពល៨០១នោះ?

[០៩:២១:១៧]

**ស៖** បាទ មុននឹងឆ្លើយសំណួរនេះ គឺខ្ញុំបញ្ជាក់អ៊ីចឹងគឺថា បង្កើតកងពល៨០១ហើយ បានគេរៀន គឺថារៀនគ្រប់កងពល។ ហើយពិធីធំៗ គឺខ្ញុំបានចូលរួមតែក្នុងពិធីចាត់តាំងហ្នឹងម្ដង ហើយនិងនៅស្ដាតអូឡាំពិកហ្នឹងម្ដង ហើយនៅពហុកីឡាដ្ឋានពីរដង។ តែម្ដងហ្នឹងទេ។ បើសរុបគឺប្រហែលជាពីរដងបីដង ប៉ុណ្ណឹងឯង។

**ឆ៖** ដូច្នេះតាមចម្លើយរបស់លោក គឺថាលោកបានចូលរួមពិធីនៅស្ដាតអូឡាំពិកនោះច្រើនដង អ៊ីចឹងមែនទេចម្លើយរបស់លោកអម្បាញ់មិញនេះ?

**ឆ៖** បាទ ខ្ញុំបញ្ជាក់ថា ខ្ញុំបានធ្វើនៅស្ដាតអូឡាំពិកហ្នឹងតែពីរដងទេ។ ទី១ ចាត់តាំងកងពល ៨០១។ ទី២ គឺរៀនសូត្រនៅក្នុងគ្រប់អង្គភាពទូទាំងប្រទេសដែលមកចូលរួមរៀន មានខាងស្រុក មានខាងភូមិភាគ មានខាងកងពល មានខាងវរសេនាធំម្ដង។ ហើយម្ដងនោះទៀត គឺខ្ញុំមិនចាំ មិនដឹងជាបុណ្យអីទេ គឺនៅស្ដាត -- នៅពហុកីឡាដ្ឋាននោះម្ដង។

[០៩:២២:៥៦]

**ស៖** បាទសូមអរគុណលោកសាក្សី។ ហើយចុះកិច្ចប្រជុំពីរផ្សេងទៀតនោះ គឺជាការប្រជុំពាក់ព័ន្ធនឹងការបង្កើតកងពល៨០១ ឬក៏មានប្រធានបទអ្វីផ្សេង?

**ឆ៖** បាទ បញ្ហានេះ គឺខ្ញុំបញ្ជាក់ថា គឺរៀនសូត្រអំពី ទី១ ហៅថាជ័យជម្នះ១៧ មេសា បញ្ជាក់ពីអត្ថន័យខ្លឹមសារហ្នឹងហើយ បានបញ្ជាក់អំពីទិសដៅរបស់យើងបន្តទៅទៀត យើងត្រូវធ្វើអី ត្រូវធ្វើយ៉ាងណាៗទៀត។ ឯភារកិច្ចរបស់ -- ក្នុងនោះគឺនិយាយហើយ គឺភារកិច្ចរបស់កងទ័ព គឺទី១ គឺការពារប្រទេស ពិសេសតាមជួរព្រំដែន តាមមុខសញ្ញាក្នុងកងពលនីមួយៗ ត្រូវក្ដាប់ភូមិសាស្ត្រ ក្ដាប់ដីរបស់ខ្លួន បាទ ក្ដាប់ដីរបស់ខ្លួន។ ទី២ គឺយកចិត្តទុកដាក់ដោះស្រាយជីវភាពក្នុងកងពលនីមួយៗឲ្យបាន។ នេះជាភារកិច្ចស្នូលសម្រាប់ក្នុងជួរកងទ័ព។ ខ្ញុំសូមបញ្ជាក់ដែរថា ក្នុងបញ្ហានេះ គឺខ្ញុំបានទទួលការរៀនសូត្រវគ្គទី១ គឺបញ្ហាដែល គឺបានជាដែលទៅនៅសៀមប៉ាង គឺខិតខំធ្វើចម្ការ ធ្វើស្រែ ធ្វើម៉េចដោះស្រាយជីវភាពឲ្យអង្គភាពរបស់ខ្លួនឲ្យបាន។ ហើយជារួមមកគឺក្នុង--

[០៩:២៥:០០]

**ស៖** បាទ លោកសាក្សីសូមអភ័យទោស អ្វីដែលលោកឆ្លើយនោះ គឺថាមានការចាប់អារម្មណ៍ណាស់ ក៏ប៉ុន្តែវាឆ្លើយតបដោយផ្នែកទៅនឹងសំណួររបស់ខ្ញុំនោះទេ។ ខ្ញុំគ្រាន់តែចង់ដឹងថា តើការប្រជុំបីដងដែលលោកបានចូលរួមនៅស្ដាតអូឡាំពិកនោះ ក្នុងយៈពេល៣លើកនោះគឺថា សម្រាប់បង្កើតកងពល

៨០១។ តើខ្ញុំចង់ដឹងថាតើទាំងបីហ្នឹងដើម្បីបង្កើត ឬក៏តែការប្រជុំលើកទី១ ទេដែលសម្រាប់បង្កើតនោះ? ហើយពីរដងចុងក្រោយទៀតនោះ គឺពាក់ព័ន្ធនឹងប្រធានបទដែលលោកបានឆ្លើយអម្បាញ់មិញនោះ ថា តើអ៊ីចឹងមែនទេ? ប្រសិនបើលោកមិនយល់នឹងសំណួររបស់ខ្ញុំទេ អាចសួរខ្ញុំឲ្យបញ្ជាក់ម្តងទៀតបាទ។

**ឆ៖** បាទ ខ្ញុំយល់នឹងសំណួរនេះ ប៉ុន្តែខ្ញុំចង់បញ្ជាក់ថា ខ្ញុំអំមិញឆ្លើយសំណួរ គឺខ្ញុំមិនបានបញ្ជាក់អំពីការបង្កើតកងពលទេ ពីព្រោះខ្ញុំឆ្លើយថា វាមានបី។ ទី១ ប្រមូលផ្តុំបង្កើតកងពល ខ្ញុំអត់និយាយទេ។ ខ្ញុំនិយាយថា តើជួបជុំថ្ងៃទី២ អ៎! វគ្គទី២ អី បានខ្ញុំនិយាយពី -- ដូចខ្ញុំបានបញ្ជាក់អំមិញអ៊ីចឹង គឺភារកិច្ចទី១ គឺការពារ រំឭកអំពីជ័យជម្នះ១៧ មេសា។ ទី២ គឺភារកិច្ចព្រំដែន--

**ស៖** លោកសាក្សីមិនបាច់ឆ្លើយម្តងទៀតទេ ខ្ញុំយល់ហើយអ្វីៗត្រូវបានកត់ត្រាទុកក្នុងប្រតិចារិករួចហើយ។ ខ្ញុំគ្រាន់តែចង់ធ្វើការពិនិត្យផ្ទៀងផ្ទាត់ឲ្យបានច្បាស់ថា មានប្រធានបទច្បាស់លាស់ ឬក៏មានតែមួយឬទេ លោកបានឆ្លើយរួចហើយ។ ដូច្នេះ ខ្ញុំដឹងថា ការប្រជុំពីរផ្សេងទៀតនោះ គឺប្រព្រឹត្តទៅនៅ -- ខ្ញុំចង់ដឹងថា តើវាប្រព្រឹត្តទៅនៅឆ្នាំពី -- ៧៥ ដដែល ឬក៏ប្រព្រឹត្តទៅនៅឆ្នាំផ្សេងទៀត?

[០៩:២៧:០៨]

**ឆ៖** បាទ ប្រព្រឹត្តនៅឆ្នាំ៧៥ អត់មានឆ្នាំផ្សេងទៀតទេ។

**ស៖** ដូច្នេះសរុបទៅ គឺមានន័យថា ការប្រមូលផ្តុំប្រជុំទាំងបីលើកហ្នឹង គឺនៅឆ្នាំ៧៥ អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** បាទ សូមអរគុណ។ ដូច្នេះ គឺថាកិច្ចប្រជុំប្រមូលផ្តុំពីរលើកចុងក្រោយនោះ គឺថាអត់មានពាក់ព័ន្ធអ្វីទៅនឹងការបង្កើតកងពល៨០១ ទេ អ៊ីចឹងមែនទេ?

**ឆ៖** បាទ អត់មានទាក់ទិន និង ពាក់ព័ន្ធទេ។

**ស៖** ដើម្បីបំពេញបន្ថែមទៅនឹងចម្លើយរបស់លោក វាជាផ្នែកនៃសំណួរដែលខ្ញុំបានសួរអម្បាញ់មិញនេះ។ ខ្ញុំចង់ដឹងថា បើតាមលោកដឹងនោះ ពិធីប្រមូលផ្តុំបង្កើតកងពល៨០១ ដែលជាពិធីតែមួយគត់ដែលលោកបានស្តាប់ឮ ឬក៏លោកដឹង។ ចុះតើលោកអាចស្តាប់ឮ មានការធ្វើពិធីណាផ្សេងទៀតទេ ក្នុងរយៈពេលដូចគ្នានុ៎ងនៅកន្លែងតែមួយហ្នឹង ដើម្បីបង្កើតកងពល៨០១នុ៎ង ឬក៏លោកដឹងតែមានពិធីមួយហ្នឹងទេ។

[០៩:២៨:៥៤]

**ឆ៖** បាទ ពេលវេលានោះ គឺខ្ញុំចាំបានគឺមានតែកម្មវិធីដែលរៀបចំកងពលហ្នឹងឯង ហើយណែនាំ ដូចខ្ញុំបានបញ្ជាក់អ៊ីចឹង។ ភារកិច្ចរបស់កងពលប៉ុណ្ណោះឯង។

**ស៖** ឥឡូវនេះ ខ្ញុំផ្លាស់ប្តូរប្រធានបទ ហើយខ្ញុំចង់ដឹងសួរលោកថា តើលោកមានការបណ្តុះបណ្តាលខាងផ្នែកយោធាអ្វីខ្លះ? ពីព្រោះថាលោកបានដឹកនាំកូនទាហានជាច្រើន ដូច្នេះខ្ញុំចង់ដឹងថា តើលោកបានទទួលការបណ្តុះបណ្តាលយោធាអ្វីខ្លះ? លោកបានរៀនសូត្រជាក់លាក់ពាក់ព័ន្ធទៅនឹងយុទ្ធសាស្ត្រយោធានៅក្នុងសាលាទាហានអ្វីដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបបញ្ហានេះ គឺតាំងពីចេះធ្វើកងទ័ពមក គឺអត់មានទេ អត់មានសាលាយោធា អត់មានអីទេ អត់មានទេ។ គ្រាន់តែមាន ចូលក្នុងកងទ័ពហើយ គឺថាមាន មានតែក្រាបលូននាយអាយប៉ុណ្ណោះឯង ហើយផ្ទុះកាំភ្លើង គឺរកជង្រុក រកគល់ឈើ អត់មានបើកវគ្គ ជាវគ្គធំដុំអី មានសាលាមានអីទេ។ តែចូលវ៉ៃ គឺប្រុងប្រៀបទៅរៀបចំតែគល់ឈើ រៀបចំជង្រុក ហើយឡើងទៅមុខ ត្រូវមើលអីៗ ប៉ុណ្ណោះឯង មានគល់ មានជង្រុកអីប៉ុណ្ណោះឯង។ នេះចំពោះដែលខ្ញុំធ្លាប់ធ្វើ ហើយក្នុងរស់នៅក្នុងរបបខ្មែរក្រហម ហៅថាកម្ពុជាប្រជាធិបតេយ្យនេះ គឺតែប៉ុណ្ណឹងឯង។ អត់មានវគ្គ បើកវគ្គរៀនសូត្រជាសាលា ជាអីៗអត់មានទេ បាទ។

[០៩:៣១:០៨]

**ស៖** ហើយចុះក្នុងចំណោមកម្មាភិបាលយោធា ដូចជាលោកនោះ តើមានអ្នកណាទទួលបានទទួលការបណ្តុះបណ្តាលយោធានៅសាលាយោធាអ្វីទេ ឬក៏ថាដូចជាលោកអ៊ីចឹងដែរ គឺថាអត់មានទទួលការបណ្តុះបណ្តាលអីទេ គឺថាធ្វើការវ៉ៃប្រយុទ្ធតែម្តង?

**ឆ៖** បាទ តាមមើល គឺថាដូចខ្ញុំបានបញ្ជាក់អ៊ីចឹង គឺថាពេលនោះគឺអត់មានសាលា អត់មានវគ្គបណ្តុះបណ្តាលទេ។ តែបើមានវគ្គបណ្តុះបណ្តាល ក្នុងកងពលគឺត្រូវតែដកកងពលមួយៗឱ្យមករៀនជាមួយគ្នាហើយ ប៉ុន្តែនេះអត់ អត់ៗទេ។ រហូតដល់តែថា ស្អុកស្អាញនៅភ្នំពេញ ក៏នៅមិនមានបានរៀនដែរ គឺយុទ្ធសាស្ត្រគឺនៅដដែល ដូចតែពីមុនអ៊ីចឹងឯង។ ហើយមេបញ្ជាការកងពលខ្ញុំ ខ្ញុំសូមជម្រាបថា គាត់មិនបាច់ទៅហាត់ទៅរៀនអី ពីព្រោះគ្រាន់តែដើរនៅព្រំដែន ឱនហើយនិងក្រាប ក្រាបហើយនិងឱនគ្រាន់តែមុជវល្លិ៍មុជអី ក៏ដូចហាត់ដែរ មិនបាច់ទៅហាត់ទៅអីទេ។ អានេះគាត់និយាយអ៊ីចឹង។ ខ្ញុំសរុបមកវិញ គឺអត់មានសាលា អត់មានអីរៀនដូចសម័យបច្ចុប្បន្នឥឡូវនេះទេ។

[០៩:៣២:៥០]

**ស៖** កាលពីម្សិលមិញនេះ គេបានសួរលោកពាក់ព័ន្ធទៅនឹងទំនាក់ទំនងរបស់លោកជាមួយថ្នាក់លើ នៅពេលដែលលោកកាន់មុខតំណែងនៅព្រំដែន។ លោកបាននិយាយអំពីមធ្យោបាយពីរ ដែលតាមរយៈនោះលោកអាចទំនាក់ទំនងបានជាមួយថ្នាក់លើ។ លោកបានឆ្លើយថា "នៅពេលដែលយើងមានថ្ម សម្រាប់សម្ភារៈនោះ យើងអាចធ្វើទូរលេខ បើមិនអ៊ីចឹងទេយើងត្រូវដើរ៥ថ្ងៃ"។ តើលោកនៅចាំពីចម្លើយរបស់លោកនេះទេ?

**ឆ៖** បាទ ខ្ញុំចាំចម្លើយរបស់ខ្ញុំ។ បើសិនថាអត់មានទូរលេខហើយ គឺថាដើរ៤ទៅ៥ថ្ងៃបានដល់កន្លែងកងពល។

**ស៖** ហើយនៅសម័យនោះគឺថា យើងមានការងាយស្រួលក្នុងការរកភ្លើងអគ្គិសនីឲ្យដំណើរការម៉ាស៊ីននោះ ឬក៏មានការពិបាក ឬក៏ដោយសារពិបាកពេកទៅ ត្រូវដើរ៥ថ្ងៃ ដើម្បីជូនដំណឹងទៅដល់ថ្នាក់លើនោះ?

[០៩:៣៤:១៩]

**ឆ៖** បាទ ដូចបានបញ្ជាក់ពីខាងដើមហើយ គឺមិនមានទេ រឿងម៉ាស៊ីន រឿងមធ្យោបាយដល់ថ្នាក់ធំៗប៉ុណ្ណោះឯង ហើយមានតែអីគេហៅថា ទូរលេខ២វ៉ាត់មួយហ្នឹង គឺប្រើតែពីរបីថ្ងៃអស់ថ្មទៅមានៗអីទៀត អត់មានទេ។ ដូច្នេះទាល់តែកម្លាំងថ្មើរជើងហ្នឹង គេទៅជួបកន្លែងកងពល បាទ។

**ស៖** តើត្រឹមត្រូវដែរឬទេ ក្នុងការនិយាយថា ក្នុងលក្ខខណ្ឌបែបនេះនោះ លោកគឺថាជួនកាលទៅ គឺថាលោកត្រូវតែធ្វើការសម្រេចដោយខ្លួនឯងនោះ?

**ឆ៖** បាទ អត់ទាន់ត្រូវទេ ប៉ុន្តែបើការងារនៅក្នុងអង្គភាព មានបញ្ហាអី ល្មមនឹងខ្ញុំដោះស្រាយបាន ខ្ញុំសម្រេចបាន។

**ស៖** នៅសម័យនោះ គឺអង្គភាពរបស់លោកគឺនៅឈរជើងនៅក្បែរព្រំដែន ហើយវាជាមុខតំណែងយុទ្ធសាស្ត្រដ៏សំខាន់។ តើលោកអាចបញ្ជាក់ជូនយើងខ្ញុំបានទេ ថាលោកនៅក្នុងអង្គភាពសម្ភារៈគ្រប់គ្រាន់ ពីព្រោះមុខតំណែងរបស់លោកនោះ សំខាន់ណាស់សម្រាប់ប្រទេសជាតិ។ តើសម្ភារៈបរិក្ខានៅក្នុងអង្គភាពរបស់លោកនោះ មានលក្ខណៈ គ្រប់គ្រាន់ល្អប្រសើរជាងអង្គភាពផ្សេងទៀត ឬក៏មិនល្អជាងអង្គភាពទៀតទេ? ឬក៏មានលក្ខណៈស្មើគ្នាដូចអង្គភាពផ្សេងៗទៀតដែរ?

[០៩:៣៦:៤៥]

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់បញ្ហានេះ គឺចំពោះអង្គភាពខ្ញុំដែលនៅតាមព្រំដែន គឺតាមពិតសម្ភារៈ

ជាមធ្យោបាយគ្រាប់រំសេវអី គឺចង់និយាយឲ្យវែង គឺថាបើសិនណាជាសត្រូវវ៉ៃពីរបីថ្ងៃ ទប់ទល់បាន ហើយថ្នាំសង្កូវក៏ដូចគ្នា។ បើទប់ទល់បានក្នុងរយៈប៉ុណ្ណឹង គឺទម្រាំតែកន្លែងកងពលយកមកឲ្យ យកមក តាមរយៈណា គឺតាមរយៈថ្មើរជើង ក៏ប្អូនប្រាំថ្ងៃ ដូចខ្ញុំជម្រាបខាងដើមអ៊ីចឹង។

**ស៖** សូមអរគុណ ចំពោះចម្លើយនេះ។ លោកសាក្សី នេះជាសំណួរចុងក្រោយ ដើម្បីបញ្ជាក់ អំពីបញ្ហានេះ។ តើលោកនិយាយថា អាចទ្រាំបាន៣ថ្ងៃ បើសិនជាមានការវ៉ៃនេះ គឺស្ថានភាពហ្នឹង ជាស្ថានភាពទូទៅ ដូចគ្នាទៅនឹងស្ថានភាពនៃអង្គភាពផ្សេងទៀតនៅតាមព្រំដែនដែរ ឬក៏វាជាស្ថានភាពជាក់លាក់សម្រាប់តែអង្គភាពរបស់លោកនោះទេ?

[០៩:៣៨:១០]

**ប្រធានអង្គជំនុំ៖**

សូមសាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

លោកប្រធានជាទីគោរព! ខ្ញុំសូមជំទាស់ទៅលើទម្រង់នៃការសួរសំណួរបែបនេះ ដែលបានកំណត់ស្ថានភាពស្វ័យភាព។ សាក្សីបានបញ្ជាក់ហើយថា គឺគាត់មានទទួលសម្ភារៈផ្គត់ផ្គង់បាន៣ថ្ងៃ ដូច្នេះហើយ គឺមេធាវីការពារក្ដីនោះ ហាក់ដូចជាកំណត់ថា អ្វីដែលសាក្សីធ្វើនេះ គឺធ្វើឡើងដោយស្វ័យ-ភាពខ្លួនឯង។

**លោក អាកទួរ វែកគែន៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។ គឺខ្ញុំនិយាយសំដៅទៅលើស្វ័យភាព ដែលសាក្សីគាត់បានឆ្លើយដោយខ្លួនឯង គឺគាត់ជាអ្នកនិយាយទេ ថាបើមានការវ៉ៃអីនោះ គាត់អាចទប់ទល់បាន៣ថ្ងៃ គឺគាត់ឆ្លើយបែបនេះ។ ដូច្នេះ ខ្ញុំគិតថា បើមានការជំទាស់បែបនេះ ប្រហែលជាអាចមានបញ្ហាពាក់ព័ន្ធនឹងការបកប្រែ។ តើលោកប្រធានចង់ឲ្យខ្ញុំរៀបចំសំណួរនេះឡើងវិញ ឬក៏យ៉ាងណា?

[០៩:៣៩:១៨]

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** លោកសាក្សីអ្វីដែលខ្ញុំចាប់អារម្មណ៍នោះ គឺថាមិនមែនរយៈពេលនៃការទប់ទល់បាននៅក្នុងពេលដែលខ្មាំងវាយប្រហារនោះទេ។ ខ្ញុំគ្រាន់តែចង់ដឹង បើសិនជាលោកមិនអាច ក៏ឆ្លើយថា មិនអាចទេ។ ខ្ញុំគ្រាន់តែចង់ឲ្យលោកប្រៀបធៀបស្ថានភាពនៅក្នុងអង្គភាពរបស់លោក ខាងផ្នែកសម្ភារៈចំនួន

បរិមាណ គុណភាពនៃសម្ភារៈក្នុងអង្គភាពរបស់លោកនោះ ជាមួយនឹងអង្គភាពផ្សេងទៀត។ ខ្ញុំចង់ដឹងថា សម្ភារៈនុំងមានគ្រប់គ្រាន់បរិបូរជាងអង្គភាពផ្សេងទៀង ឬក៏មានខ្វះខាតតិចជាងអង្គភាពផ្សេងទៀត ឬក៏លោកមិនអាចធ្វើការប្រៀបធៀបបានទេ?

**ឆ៖** បាទ ចំពោះបញ្ហានេះ គឺខ្ញុំសូមជម្រាបថាក្នុងកងពលដែលទៅហ្នឹង គឺបើពិនិត្យអំពីមធ្យោបាយសម្ភារៈ បាទសម្ភារៈអីគឺប្រហាក់ប្រហែលគ្នាទេ មិនមានអង្គភាពណាមានជាងអង្គភាពណាទេ ប្រហាក់ប្រហែលគ្នា។ ប៉ុន្តែគ្រាន់ថា ចង់បញ្ជាក់ថា បើមានបញ្ហាសត្រូវ គឺអង្គភាពពីរដែលជាប់នឹងកន្លែងកងពល វាស្រួលជាង។ ទី១ មានផ្លូវ ហើយអង្គភាពគ្មានផ្លូវ មានតែផ្លូវរទេះ។ សូមអស់។

[០៩:៤១:00]

**លោក អាកទ្វរ វែកគែន៖**

នេះជាសំណួរចុងក្រោយរបស់ខ្ញុំហើយលោកសាក្សី។ ខ្ញុំអស់សំណួរហើយ។ លោកប្រធានសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ លោក អ៊ុង រ៉ែន ការស្តាប់សក្ខីកម្មរបស់លោករហូតដល់ពេលនេះបានចប់ហើយ។ វត្តមានរបស់លោកនៅ អ.វ.ត.ក លែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់លោក ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ អង្គជំនុំជម្រះសូមអរគុណចំពោះលោក ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកចូលរួមផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះក្នុងរយៈពេល២ថ្ងៃកន្លងមកនេះ ប្រកបដោយភាពអត់ធ្មត់ ខិតខំអស់ពីសមត្ថភាព និងលទ្ធភាពរបស់ខ្លួន។

លោក អ៊ុង រ៉ែន សក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតនៃរឿងក្តីនេះ សូមលោកជួបតែសំណាងល្អ រស់នៅប្រកបដោយសេចក្តីសុខសេចក្តីចម្រើន និងធ្វើដំណើរវិលត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះវិលត្រឡប់ទៅកាន់ទីលំនៅដ្ឋានរបស់គាត់ ឬទីណាដែលជាគោលដៅគាត់មានបំណងចង់ទៅ។ ហើយលោក អ៊ុង រ៉ែន អាចចាកចេញទៅបានហើយ។

[០៩:៤២:២០]

*(សាក្សីចាកចេញពីបន្ទប់សវនាការ)*

*(ទៅក្រុមពិភាក្សាគ្នា)*

[០៩:៤៣:៣៥]

**ប្រធានអង្គជំនុំ៖**

បាទ ជាកិច្ចបន្តនេះ អង្គជំនុំជម្រះលើកយកបញ្ហាមួយ មកដាក់ដើម្បីជូនភាគីផ្ដល់មតិយោបល់ពិភាក្សា។ ដូចជាអង្គជំនុំជម្រះបានជម្រាបជូនភាគីរួចហើយកាលពីម្សិលមិញ ហើយនិងបន្ថែមនូវលិខិតមួយទៀតតាមរយៈអ៊ីម៉ែល ដែលផ្ញើជូនទៅអំពីបញ្ហាពាក់ព័ន្ធជាមួយនឹងការពិនិត្យលើសំណើសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងការស្នើសុំកោះហៅដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-94 មកផ្ដល់សក្ខីកម្ម។ ហើយមានខ្លឹមសារដូចអង្គជំនុំជម្រះបានផ្ដល់ជូនហើយ ហើយដើម្បីបានច្បាស់លាស់ដោយសារនៅភាពមិនច្បាស់លាស់រវាងថា តើគប្បីកោះហៅគាត់ឬមិនកោះហៅគាត់មកផ្ដល់សក្ខីកម្ម ដោយមានហេតុផលដូចអង្គជំនុំជម្រះបានពិភាក្សា និងផ្ដល់ដំណឹងជូនភាគីរួចហើយ។ អ៊ីចឹងទេ អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅភាគី ដើម្បីលើកឡើងនូវបញ្ហានេះ។ ហើយជាដំបូងគឺសូមឱ្យមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដែលជាម្ចាស់សំណើលើកឡើងមុនគេពាក់ព័ន្ធជាមួយនឹងបញ្ហានេះ។ ប្រើរយៈពេលខ្លីទេតែ៥នាទីប៉ុណ្ណោះ។ សូមនិយាយសង្ខេបទៅបានហើយ។

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន ខ្ញុំសូមប្រគល់សិទ្ធិនេះជូនលោក សំ សុគង់ ហើយនិងលោកស្រីមេធាវី បេនី យេ និយាយ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត! សូមអញ្ជើញ!

[០៩:៤៥:២៩]

**លោក សំ សុគង់៖**

បាទ ជាបឋមសូមគោរពលោកប្រធានក្រុមប្រឹក្សា និងសូមគោរពក្រុមប្រឹក្សា សូមគោរពអង្គសវនាការទាំងមូល! ទាក់ទងនឹងសាក្សី TCW -- ដើមបណ្ដឹងរដ្ឋប្បវេណី TCCP-94 នេះ ដោយសារតែសាក្សីរូបនេះ គាត់ -- ខាងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ក៏ដូចជាសហមេធាវីនាំមុខមិនបានស្នើជា

ពិសេសឲ្យធ្វើសក្ខីកម្មទៅលើការជម្លៀសដោយបង្ខំទាំងករណីទី១ និងទី២ ទេ។ ប៉ុន្តែតាមសំណើរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក៏ដូចជាសហមេធាវីនាំមុខ បានស្នើសុំឲ្យធ្វើសក្ខីកម្មពាក់ព័ន្ធទៅនឹង -- ទាក់ទងទៅនឹងតួនាទីរបស់ជនជាប់ចោទ ក៏ដូចជាស្ថានភាពនៅក្នុងបឹងត្របែក ហើយក៏ដូចជាទាក់ទងនឹងគោលនយោបាយរបស់ខ្មែរក្រហម ទាក់ទងទៅនឹងអ្នកដែលត្រឡប់មកពីបរទេស។

ទោះបីជាយ៉ាងនេះក៏ដោយក៏យើងឃើញថា នៅក្នុងអង្គហេតុរបស់សាក្សីរូបនេះ អ៊ំ! សូមទោសរបស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះឃើញថា ក្រុមគ្រួសាររបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក៏ដូចជាប្ដី និងកូនក៏ជាជនរងគ្រោះនៅក្នុងការជម្លៀសដោយបង្ខំផងដែរ។ បើយើងយោងទៅលើដីកាសម្រេចបំបែកសំណុំរឿង E124 យើងឃើញថា នៅក្នុងសំណុំរឿង ០០២/០១ នេះ គឺមាននិយាយទាក់ទងនឹងតួនាទីរបស់ជនជាប់ចោទ។ ហើយនៅក្នុងនោះ យើងឃើញថាដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ គាត់បានដឹងច្បាស់ពីតួនាទីរបស់ជនជាប់ចោទ ជាពិសេសគឺលោក ខៀវ សំផន ហើយនិងលោក អៀង សារី ដែលពាក់ព័ន្ធទៅនឹងការដែលគាត់មកធ្វើជាបទបង្ហាញនៅក្នុងវគ្គសិក្ខាសាលានៅពេលដែលនិស្សិត ក៏ដូចជាអ្នកដែលវិលត្រឡប់មកពីជន -- មកពីបរទេសវិញនោះ។

[០៩:៤៧:៣៦]

ម្យ៉ាងវិញទៀត យើងឃើញ -- ដោយសារតែនៅក្នុងនេះ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះក៏ដឹងពីគោលនយោបាយនៃរបបខ្មែរក្រហមដែលទាក់ទងនឹងការជម្លៀស និងទាក់ទងនឹងការដែលប្រព្រឹត្តទៅលើអ្នកដែលវិលត្រឡប់មកពីបរទេសផងដែរ។ ដូច្នេះខ្ញុំបាទ សូម ក្នុងនាមជាដើម -- ជាមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីសុំឲ្យលោកប្រធានមេត្តាជួយឲ្យដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ មកធ្វើសក្ខីកម្មទាក់ -- ដើម្បីគាត់បានថ្លែងអំពីដំណើររឿងហេតុទាក់ទងទៅនឹងតួនាទីរបស់ជនជាប់ចោទទាំងពីរខាងលើនេះ។ ហើយសូមប្រគល់តួនាទីនេះទៅឲ្យមេធាវីអន្តរជាតិរបស់ខ្ញុំជាបន្ត។ បាទ សូមអរគុណ។

**លោកស្រី បេនី យេះ**

សូមអរគុណ។ សូមជម្រាបសួរលោក លោកស្រីចៅក្រម ហើយនិងភាគីទាំងអស់។ ខ្ញុំនិយាយទីនេះក្នុងនាមមេធាវី នូស៊ីន សាកាវ៉ាទី តំណាងឲ្យរដ្ឋប្បវេណី ៩៤។ ខ្ញុំលើកចំណុច៣ ដែលស្ថិតក្នុងអ៊ីម៉ែលរបស់អង្គជំនុំជម្រះជូនភាគីកាលពីម្សិលមិញ។ ទី១ និយាយអំពីលេខ២ នៅក្នុងអ៊ីម៉ែល គឺបញ្ហាលើកឡើង--

**ប្រធានអង្គជំនុំ៖**

ឈប់ៗយឺតឲ្យ -- អញ្ជើញ!

[០៩:៤៩:០៨]

**លោកស្រី បេនី យេះ**

ខ្ញុំនឹងនិយាយយឺត។ ទី១ ខ្ញុំនឹងនិយាយអំពីបញ្ហាបទសម្ភាសន៍នៅវិទ្យុសំឡេងសហរដ្ឋអាមេរិក ហើយមិនមាននៅក្នុងសំណុំរឿងទេ ប៉ុន្តែបោះពុម្ពផ្សាយជាសាធារណៈ។ ហើយគឺគេបោះពុម្ពផ្សាយជាសាធារណៈមុនដោយ -- ករណីនេះ គឺថាយើងគឺជាកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញា។ បន្ថែមលើនេះ គឺថាមិនមានការប៉ះពាល់ទៅដល់ភាគីផ្សេងៗទៀតទេ ដែលមិនបានដាក់បទសម្ភាសន៍ វី.អូ.អេ នៅក្នុងសំណុំរឿង។ ប៉ុន្តែបទសម្ភាសន៍ទាំងអស់នេះ គឺថាគេបានដឹងជាទូទៅ បានយោងនៅក្នុងទម្រង់ជនរងគ្រោះរបស់ TCCP-94។ នៅក្នុងសប្តាហ៍នេះ នឹងមានឯកសារដែលអាចសាធារណជនបានបើកបាន នៅក្នុងភាសាខ្មែរ-អង់គ្លេស គឺនៅក្នុងវេបសាយរបស់ វី.អូ.អេ។ ទី៣ ដើម -- មេធាវីដើមបណ្តឹងរដ្ឋប្បវេណី គឺមិនប្រើផ្នែកណាមួយនៃបទសម្ភាសន៍ វី.អូ.អេ ជាប្រតិចារឹកនោះទេ នៅក្នុងការដេញដោលនោះ។ ហើយនៅទីបំផុត មេធាវីមិនមានការជំទាស់ទៅនឹងការប្រើប្រាស់នូវប្រតិចារឹកជាភាសាខ្មែរ, អង់គ្លេស នៅក្នុងការដេញដោលរបស់ភាគីផ្សេងទៀតទេ។

[០៩:៥០:៣០]

ដូច្នេះខ្ញុំនឹងចូលទៅចំណុចទី៣ នៃអ៊ីម៉ែលរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនិយាយអំពីថាជនជាប់ចោទអាចថានឹងឆ្លើយដាក់នៅក្នុងសេចក្តីថ្លែងពីទុក្ខសោកនេះ។ ការព្រួយបារម្ភ គឺថាផ្អែកលើមូលហេតុមិនត្រឹមត្រូវ TCCP-94 គឺមិនធ្វើសក្ខីកម្មអំពីតួនាទី ពីការឈឺចាប់របស់ទេ ប៉ុន្តែផ្អែកទៅលើអង្គហេតុតែប៉ុណ្ណោះ។ នេះជាឱកាសមួយដែលភាគីទាំងអស់ទាក់ទងបញ្ហានេះ គឺដើមបណ្តឹង -- មេធាវីការពារក៏អាចសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណីដែរ។ ហើយបញ្ហាដែលលើកឡើងនៅក្នុង ទាក់ទងទៅនឹង TCCP-187 ដែលបានផ្តល់សក្ខីកម្មហើយ គឺថាមិនបានកើតមានឡើងទេ។

ចំណុចទី៤ នៅក្នុងអ៊ីម៉ែលនោះ គឺនិយាយអំពីបញ្ហាភាពចាំបាច់នៃការបន្ថែមពេលវេលាសម្រាប់សក្ខីកម្មនេះ។ តាមអ្វីដែលយើងខ្ញុំដឹង គឺថាយើងបានផ្តល់ពេលកន្លះថ្ងៃទៅ អ.ស៊.ភ និងដើមបណ្តឹងរដ្ឋប្បវេណី ហើយកន្លះថ្ងៃទៅមេធាវីការពារក្តី។ ហើយក៏បានស្នើរួចមកហើយដែរ ដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី TCCP-94 នឹងធ្វើសក្ខីកម្មអំពីតួនាទីរបស់ជនជាប់ចោទ។ យើងមិនឃើញអ្វីដែលថា

មានបញ្ហានឹងត្រូវបន្ថែមពេលវេលាលើសពីអ្វីដែលគ្រោងនោះទេ។ សូមអរគុណ។

[០៩:៥២:១០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងជម្រាបដោយសង្ខេប។ ផ្អែកទៅលើការអធិប្បាយរបស់វិទ្យុសំឡេងសហរដ្ឋអាមេរិក នៅក្នុងបទសម្ភាសន៍នៅក្នុងលិខិតរបស់ដើមបណ្តឹងរដ្ឋប្បវេណី សហមេធាវីនាំមុខដែលបានចែកជូនទៅភាគី។ យើងខ្ញុំឃើញថា នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីមិនអាចផ្តល់នូវព័ត៌មានទៅដល់តុលាការអំពីការជម្លៀសទីក្រុងភ្នំពេញនោះទេ។ នេះគឺដើមបណ្តឹងរដ្ឋប្បវេណីរូបនេះមានព័ត៌មានដ៏សំខាន់ គឺជនជាប់ចោទពីរ អំពីតួនាទីរបស់អ្នកទាំងពីរនោះនៅក្នុងរបបរបស់គេ។ ហើយជាពិសេសពាក់ព័ន្ធទៅនឹងលោក ខៀវ សំផន ដើមបណ្តឹងរដ្ឋប្បវេណីអាចនឹងបញ្ជាក់ថា មានវគ្គសិក្សានយោបាយដែលគាត់បានបើក ហើយជាពិសេសនិយាយអំពីការពិភាក្សានយោបាយ ការអប់រំ គោលនយោបាយ អំពីការប្តូរទីតាំងដោយបង្ខំនូវជនជាតិវៀតណាម។ ហើយមានសារៈសំខាន់មួយនៅក្នុងចំណុចនេះ ដើម្បីបង្ហាញភស្តុតាងថា លោក ខៀវ សំផន បានដឹងអំពីការ -- គោលនយោបាយអំពីការផ្លាស់ប្តូរទីកន្លែងប្រជាជននៅពេលនោះ។ ហើយក៏បានចង្អុលបង្ហាញដែរថា ដើមបណ្តឹងរដ្ឋប្បវេណីអាចបង្ហាញអំពីតួនាទីរបស់ អៀង សារី ទាក់ទងទៅនឹងការចូលរួមប្រជុំ ហើយនិងវគ្គដែលបង្ហាញភស្តុតាងអំពីប្រព្រឹត្តកម្មទៅលើអ្នកការទូត ហើយនិងអ្នកវិលត្រឡប់មកប្រទេសវិញនាសម័យកាលនោះ។

[០៩:៥៤:០៦]

ដូច្នេះហើយការ -- វត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះ នៅក្នុងកិច្ចប្រជុំដែលលោក អៀង សារី បាននិយាយនោះ គឺដែលក្នុងនោះ គឺបង្ហាញភស្តុតាងអំពីថា លោក អៀង សារី គាត់បានដឹងហើយគាត់បានចូលរួមទៅនឹងការធ្វើទុក្ខបុកម្នេញ ហើយនិងការបោសសម្អាត។

ផ្អែកទៅលើអ្វីដែលខ្ញុំជម្រាបជូននេះ គឺថាដើមបណ្តឹងរដ្ឋប្បវេណីនេះមានសារប្រយោជន៍ក្នុងការបង្ហាញសក្ខីកម្ម ហើយខ្ញុំយល់ស្របជាមួយនឹងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី គឺថាអង្គជំនុំជម្រះគប្បីតែកោះអញ្ជើញគាត់មក គឺថាការអញ្ជើញគាត់មិនពង្រីកពេលវេលាបន្ថែមនោះទេ។ គឺថាវាអាស្រ័យទៅលើពេលវេលាដែលថាត្រូវគ្រប់គ្រងបណ្តាប់បញ្ហាហ្នឹងឲ្យបានឆាប់រហ័ស ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីគាត់

អាចនឹងធ្វើដំណើរមកពីអាសយដ្ឋានរបស់គាត់ ដើម្បីមកជម្រាបតុលាការនៅពេលនេះ គឺថាអាចនឹងជាការល្អ ហើយនិងតុលាការអាចនឹងផ្តល់ពេលដើម្បីឱ្យគាត់បានធ្វើសក្ខីកម្ម។ នេះជាជំហររបស់សហព្រះរាជអាជ្ញាទាក់ទងនឹងបញ្ហានេះ ផ្អែកទៅលើព័ត៌មានថ្មីរបស់វិទ្យុរបស់សំឡេងសហរដ្ឋអាមេរិកនោះ គឺថាយើងមើលឃើញមាននៅក្នុងវេបសាយហើយ គឺភាគីអាចមានពេលនឹងចូលមើលតាមដែលខ្លួនចង់បាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ តំណាងសហព្រះរាជអាជ្ញា។ បាទ ជាបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី ចាប់ផ្តើមពីលោកមេធាវីការពារក្តីលោក នួន ជា មុន តើមានមតិយោបល់អ្វីដែលទេ លើបញ្ហានេះ?

[០៩:៥៥:៤៦]

**លោក វិចទ័រ កូប៉េះ៖**

សូមអរគុណលោកប្រធាន។ ទាក់ទងទៅនឹងកថាខណ្ឌមួយនៃអ៊ីម៉ែលកាលពីម្សិលមិញនោះ សូមអភ័យទោស ខ្ញុំមិនឃើញថា មានពាក់ព័ន្ធអ្វីច្បាស់ទៅនឹងរឿងក្តីបច្ចុប្បន្នទេ យើងយល់ស្របជាមួយជំហររបស់មេធាវីការពារក្តីរបស់ អៀង សារី និង ខៀវ សំផន ដែរ យើងយល់ឃើញថា សាក្សីសក្តានុពលដែលនឹងផ្តល់ភស្តុតាងជាពិសេស បាទ ហើយយើងនឹងយល់ស្របទៅតាមគំនិតនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្ត សូមផ្តល់វេទិកាជូនទៅមេធាវីការពារក្តីលោក អៀង សារី!

**លោក ម៉ៃខល កាណាវាស៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ហើយនិងភាគីទាំងអស់ ទាំងខាងក្នុងនិងក្រៅសាលសវនាការ។ ជាបឋម ជំហររបស់យើងគឺតែងតែស្របគ្នា កាលណានិយាយអំពីដើមបណ្តឹងរដ្ឋប្បវេណី ហើយបើសិនជាយើងដកនរណាម្នាក់ចេញពីការផ្តល់ភស្តុតាងនោះ គឺថាគឺវាអាស្រ័យ -- គឺថាយើងមិនជំទាស់ទៅនឹងសក្ខីកម្មដែលផ្តល់ដោយដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ដូចដែលបានជម្រាប។ គឺទាក់ទងទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីម្នាក់នេះ គឺថាគឺអាចនឹងគំនិតមួយចំនួនដែលយើងខ្ញុំ -- ដែលថាដើមបណ្តឹងរដ្ឋប្បវេណីនេះមាន គឺថាជាព័ត៌មានគឺត្រឡប់ទៅដល់ខែកុម្ភៈ ឆ្នាំ២០១១។ សហព្រះរាជអាជ្ញាចង់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីមកធ្វើសក្ខីកម្ម ហើយសហមេធាវីនាំមុខថាមិនមែនឥឡូវនេះទេ ពេលក្រោយ។ អ៊ីចឹងសហព្រះរាជអាជ្ញាថា ពេលក្រោយក៏បាន។ ដូច្នេះហើយយើងមានការច្របូកច្របល់

ទៅខាងភាគីខាងនោះទេ មិនមែនខាងយើងខ្ញុំទេ។

[០៩:៥៧:៤៦]

ម្យ៉ាងវិញ គឺថាយើងឃើញអ៊ីម៉ែលមួយ គឺយើងមើលកថាខណ្ឌទី១។ ខ្ញុំមើលឃើញថា ដូចជាចំណុចច្របូកច្របល់នៅក្នុងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ។ អ្វីដែលស្ថិតនៅក្នុងរឿង០០២/១ សម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីនេះ គឺថាជាពិសេស គឺផ្អែកទៅលើព័ត៌មានដែលគាត់ ហើយនិងក្រុមគ្រួសាររបស់គាត់ពាក់ព័ន្ធដោយផ្ទាល់នៅក្នុងការជម្លៀសនៅទីក្រុងភ្នំពេញ។

ខ្ញុំមើលឃើញថា ចំណុចនេះ អង្គជំនុំជម្រះបានបង្ហាញថា ជាគោលបំណងមួយ ដូច្នេះហើយដែលខ្លួនត្រូវដាក់បញ្ចូល។ ដោយជាក់ស្ដែង បើយើងមើលឯកសារដែលផ្ដល់ដោយដើមបណ្ដឹងរដ្ឋប្បវេណី ដែលតាមទម្លាប់ករណ៍របស់សហព្រះរាជអាជ្ញានោះ អង្គជំនុំជម្រះក៏មាននៅក្នុងដៃរបស់ខ្លួននូវព័ត៌មានហ្នឹង ថាតើដើមបណ្ដឹងរដ្ឋប្បវេណីអាចផ្ដល់ភស្តុតាងពីអ្វីថែមទៀតបាននោះ។ ហើយយើងក៏មើលឃើញដែរ ថានៅក្នុងអ៊ីម៉ែលម្សិលមិលនេះ គឺថា បញ្ហាទាំងអស់ផ្សេងទៀតនោះ គឺមិនមានសារៈសំខាន់ខ្លាំងនោះទេ ក្នុងករណីនេះ គឺក្នុងករណី០០២/០១នេះ ដោយហេតុថា ខ្ញុំសន្និដ្ឋានថា សាក្សីផ្សេងៗទៀត ក៏បានគ្របដណ្ដប់ធ្វើសក្ខីកម្មផ្នែកផ្សេងៗ ដូចដែលបានលើកឡើងនៅថ្ងៃនេះរួចមកហើយ។

ម្យ៉ាងវិញទៀត អង្គជំនុំជម្រះគឺបានធ្វើសេចក្ដីសម្រេចមួយ គឺមិនត្រូវកោះអញ្ជើញសាក្សីនេះទេ។ បាទ គឺថាប្រមើល៍សេចក្ដីសម្រេចរបស់ខ្លួន គឺថាសាក្សីនេះមិនអាចបង្ហាញភស្តុតាងពីការជម្លៀសទីក្រុងភ្នំពេញនោះទេ ដោយសារគាត់មិនបានពាក់ព័ន្ធផ្ទាល់។ ដើមបណ្ដឹងរដ្ឋប្បវេណី ហើយសហព្រះរាជអាជ្ញានិយាយថា ជាពិសេសគឺករណីបឹងត្របែក ប៉ុន្តែគឺថា ប៉ុន្តែដ៏ខ្លាំងគាត់មានព័ត៌មានអំពីនយោបាយទាក់ទងទៅនឹងការជម្លៀស ដូច្នេះហើយគឺថាសូមឲ្យសាក្សីនេះមកបំភ្លឺ។

[១០:០០:០០]

ជំហរសំខាន់របស់យើងខ្ញុំ គឺដូចខាងក្រោមនេះ៖ គឺគ្មានអ្វីពាក់ព័ន្ធទេ ដែលថាសាក្សីនេះគឺថាអាចផ្ដល់បាននោះ គឺដែលអាចនឹងបង្ហាញជូនតុលាការបានទេ។ គាត់អាចមានព័ត៌មានទាក់ទងនឹងកូនក្ដីរបស់ខ្ញុំ និងលោក ខៀវ សំផន អំពីដែលថាគាត់នៅបឹងត្របែកនៅកាលនោះ។ ខ្ញុំអាចធ្វើសម្បទានបាន គាត់អាចបន្ថែមអ្វីខ្លះ ប៉ុន្តែខ្ញុំសូមជម្រាបរំឭកអង្គជំនុំជម្រះថា ទាក់ទងទៅTCW-243 ហើយ 292 គឺថានៅទីនេះ គឺមិននៅឆ្ងាយទេ គឺគាត់នៅទីក្រុងភ្នំពេញនេះឯង។

យើងបានស្នើម្ដងហើយ ម្ដងទៀត ហើយភាគីផ្សេងទៀតដើម្បីឲ្យពួកអ្នកទាំងអស់នោះមកធ្វើ

សក្ខីកម្មដោយផ្អែកលើព័ត៌មានដែលទទួលបានពីសាក្សីមួយនោះ ដែលជាអ្នកត្រឡប់មកវិញនៅពេលនោះដែរ ហើយគាត់នៅបឹងត្របែកនៅក្នុងថ្ងៃទី១៤ ខែ៩ ឆ្នាំ២០១២ ឯកសារ E2/28។ យើងធ្វើសំណើម្តងទៀត TCW-243 ហើយនិង TCW-292 ឲ្យមកផ្តល់សក្ខីកម្ម។ អ្វីដែលជាចំណុចរបស់ខ្ញុំនោះគឺថា ប្រសិនបើអង្គជំនុំជម្រះសម្រេចថា សំខាន់ដើម្បីស្តាប់ព័ត៌មានបន្ថែមទៀតលើបឹងត្របែកនេះ យើងសូមស្នើថា សារៈសំខាន់ណាស់ដែលអង្គជំនុំជម្រះត្រូវដាក់បញ្ចូលសាក្សីពីរនេះបន្ថែមទៀត ដែលខ្ញុំបញ្ជាក់អម្បាញ់មិញនេះ ដើម្បីឲ្យមកផ្តល់សក្ខីកម្ម។ បាទជំនួស -- បើបញ្ហានេះនិយាយពីបឹងត្របែក យើងមិនមានព័ត៌មានគ្រប់គ្រាន់ពីរឿងហ្នឹងទេ។ បន្ទាប់មកយើងអាចនឹងសន្សំលុយអ្នកបង់ពន្ធអន្តរជាតិ ដូចជាត្រូវឲ្យអ្នកនោះជិះយន្តហោះពីសហរដ្ឋអាមេរិកមក ឲ្យស្នាក់នៅអូតែល។ សំខាន់បំផុត យើងកោះអញ្ជើញអ្នកនៅភ្នំពេញនេះជាការសន្សំលុយជាង។ ហើយគឺថា រដ្ឋាភិបាល ហើយតុលាការនឹងផ្តល់ឲ្យការអញ្ជើញមកហ្នឹង គឺថាឆាប់រហ័សជាង ហើយសន្សំសំចៃជាង ហើយមិនមានបញ្ហាអ្វីចម្រូងចម្រាសច្រើនទៀតផង។

[១០:០២:២៧]

តែយើងមិនជំទាស់ទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីដែលមកបង្ហាញភស្តុតាងនោះទេ ប៉ុន្តែវាផ្អែកទៅលើភស្តុតាង ឬក៏ព័ត៌មានដែលដើមបណ្តឹងរូបនេះត្រូវបង្ហាញនោះ គឺថាមិនមានអ្វីបន្ថែមតម្លៃនោះទេ។ ដូច្នេះហើយ គ្រាន់តែៗជាផ្នែកមួយឲ្យគាត់បង្ហាញទៅតាមអ្វី តាមសំណើរបស់សហព្រះរាជអាជ្ញាតែប៉ុណ្ណោះ។ ដូច្នេះ យើងសូមឲ្យអង្គជំនុំជម្រះបដិសេធសំណើរបស់ភាគីសហព្រះរាជអាជ្ញា ដើម្បីមិនអញ្ជើញសាក្សីរូបនេះទេ គឺថាសម្រេចដោយផ្អែកទៅលើព័ត៌មានទាំងអស់ ដែលអង្គជំនុំជម្រះមាន ដែលរាប់បញ្ចូលទាំងសាក្សីម្នាក់រូបនេះគឺថាដែលនិយាយថា ជាមូលដ្ឋានគឺព័ត៌មានដែលក្រុមគ្រួសារ ហើយនិងគាត់បានទទួលភាពពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការជម្លៀសទីក្រុងភ្នំពេញ។ ហើយអ្វីដែលក្រៅពីនោះមិនមែនជាករណីពាក់ព័ន្ធទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកមេធាវី!

[១០:០៣:៣៧]

**លោក អាកឡូវ វែកគែន៖**

សូមអរគុណលោកប្រធាន។ បាទ ខ្ញុំសូមរំឭកនូវអង្គហេតុមួយចំនួនដែលមាននៅក្នុងការជំនុំ

ជម្រះរបស់យើងនោះ គឺថាវាពាក់ព័ន្ធទៅនឹងបរិបទប្រវត្តិសាស្ត្រ រចនាសម្ព័ន្ធរដ្ឋបាល រចនាសម្ព័ន្ធយោធា មធ្យោបាយទំនាក់ទំនងការងារ ការជម្លៀសប្រជាជនចេញពីទីក្រុងដំណាក់កាលទី១ ទី២, ឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តក្នុងពេលជម្លៀស ឧក្រិដ្ឋកម្មប្រព្រឹត្តទៅប្រឆាំងទៅនឹងមន្ត្រីរបស់សាធារណរដ្ឋខ្មែរ។ នៅក្នុងក្របខ័ណ្ឌទាំងអស់នេះគឺមានទាំងតួនាទីរបស់ជនជាប់ចោទផងដែរ។

ដូច្នេះច្បាស់ណាស់ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះអាចនឹងពាក់ព័ន្ធទៅនឹងប្រធានបទណាមួយ នៃការជំនុំជម្រះក្តីរបស់យើង គឺដូចជាការជម្លៀសចេញពីទីក្រុងភ្នំពេញជាដើម ហើយគេប្រាប់យើងនៅពេលចុងក្រោយនេះថា ស្ត្រីរូបនោះគឺថា គាត់អត់មានអ្វីនិយាយច្រើនផ្ទាល់ពាក់ព័ន្ធទៅនឹងការជម្លៀសចេញពីទីក្រុងភ្នំពេញនោះទេ។ ដើម្បីបញ្ជាក់មូលហេតុនៃការកោះហៅរបស់គាត់នោះ គេប្រាប់យើងថា គាត់នឹងនិយាយអំពីបឹងត្របែក និយាយអំពីវគ្គរៀនសូត្រនៅបឹងត្របែក ដែលបានផ្តល់ជូនដោយលោក ខៀវ សំផន។ ដូច្នេះនេះ នៅក្នុងពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់នោះ គ្មានចំណុចណាមួយដែលគាត់បានបញ្ជាក់ថា គាត់បានទទួលការរៀនសូត្រដែលឧទ្ទេសនាមដោយលោក ខៀវ សំផន នោះទេ ហើយគាត់ក៏មិនបានបញ្ជាក់ថា គាត់នៅបឹងត្របែកនោះដែរ។

[១០:០៥:៣០]

ដូច្នេះខ្ញុំគិតថា យើងមកពេលនេះ ទើបនឹងមកប្រាប់ថា អូ៎! គាត់សំខាន់ណាស់ គាត់មានចំណុចដែលត្រូវលើកឡើងពាក់ព័ន្ធទៅនឹងចំណុចសំខាន់មួយចំនួន។ ដូច្នេះអ្វីដែលយើង -- អ្វីដែលបានលើកឡើងនៅថ្ងៃនេះ ដើម្បីឲ្យកោះហៅដើមបណ្តឹងរដ្ឋប្បវេណីនោះ គឺថាវាមិនពាក់ព័ន្ធទៅនឹងប្រធានបទនៃការជំនុំជម្រះក្តីយើងនោះទេ។ ហើយលើសពីនេះទៅទៀតនោះ គឺថាមិនមានការបញ្ជាក់ណាមួយនៅក្នុងពាក្យសុំតាំងខ្លួនរបស់គាត់នោះទេ អំពីអង្គហេតុទាំងអស់នេះនោះ។

សហភាគាខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដើមបណ្តឹងរដ្ឋប្បវេណីបាននិយាយអម្បាញ់មិញនេះ គឺថាវាមិនត្រឹមត្រូវនោះទេ។ គោលជំហររបស់យើង គឺថាសាក្សីទាំងអស់ ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់អាចមកផ្តល់សក្ខីកម្ម។ យើង -- ជាគោលការណ៍នោះគឺថាយើងមិនជំទាស់ទេ យើងទទួលយកនូវការជជែកពិភាក្សាដេញដោលគ្នាក្នុងតុលាការ ក៏ប៉ុន្តែត្រូវតែមានលក្ខខណ្ឌផងដែរ។ លក្ខខណ្ឌនោះគឺថា សក្ខីកម្មនោះត្រូវតែពាក់ព័ន្ធទៅនឹងការជំនុំជម្រះក្តីរបស់យើង ក៏ប៉ុន្តែគាត់មិនមានអ្វីពាក់ព័ន្ធទៅនឹងប្រធានបទនៃការជំនុំជម្រះក្តីរបស់យើងនោះទេ។

[១០:០៦:៥២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបាទ!

**លោកស្រី បេនី យេះ**

សូមអរគុណលោកប្រធាន។

ខ្ញុំគ្រាន់តែចង់ឆ្លើយតបទៅនឹងអ្វីដែលលើកឡើងដោយមេធាវីការពារក្តី ចំពោះហេតុផលថាហេតុអ្វីបានជាយើងកោះហៅ TCCP-94។ ខ្ញុំចង់លើកឡើងអនុស្សរណៈ១៧២ ដែលចេញដោយអង្គជំនុំជម្រះនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០១ (មេធាវីនិយាយដូច្នេះ)។ TCCP-94 នេះគឺពាក់ព័ន្ធទៅនឹងបញ្ហាមន្ទីរបឹងត្របែក។ ដូច្នេះហើយយើងមិនអាចនិយាយថា ដល់នាទីចុងក្រោយនេះយើងបានប្តូរហេតុផលដែលពាក់ព័ន្ធទៅនឹងការកោះហៅគាត់មកផ្តល់សក្ខីកម្ម លើការផ្លាស់ទីលំនៅដំណាក់កាលទី១ នោះទេ។ យើងខ្ញុំៗមិនដែលធ្លាប់បានបញ្ជាក់លើបញ្ហានៃការកោះហៅគាត់ឲ្យមកផ្តល់សក្ខីកម្ម លើបញ្ហាផ្លាស់ទីលំនៅនេះមែន។ ក៏ប៉ុន្តែដូចដែលខ្ញុំបានបញ្ជាក់អម្បាញ់មិញនេះ គឺវាមានហេតុផលដូច្នេះ។

[១០:០៨:០៧]

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមលើកឡើង។ មានចំណុចពីរដែលមេធាវីការពារក្តីលើកឡើង ដោយមិនត្រឹមត្រូវ ដែលយើងខ្ញុំសូមកែតម្រូវ។ ទី១ គឺការអះអាងលើកឡើងរបស់មេធាវីការពារក្តី ដែលថាចំណុចហ្នឹងមិនបានលាតត្រដាងនៅក្នុងពាក្យសុំដើមបណ្តឹងរដ្ឋប្បវេណី។ តាមពិតព័ត៌មាននេះគឺបានលាតត្រដាងនៅក្នុងសេចក្តីសង្ខេប ដែលផ្តល់ជូនដោយដើមបណ្តឹងរដ្ឋប្បវេណីរួចមកហើយ។ មេធាវីការពារក្តីនៅទីនេះបានលើកឡើងថា នៅពេលដែលគេជ្រើសរើសដើមបណ្តឹងរដ្ឋប្បវេណីនេះដំបូង គឺក៏បានបញ្ជាក់ថា នឹងមកផ្តល់ចម្លើយ ផ្តល់សក្ខីកម្មលើជម្លៀសដំណាក់កាលទី១ ផងដែរ។ ដូច្នេះក៏មិនបានបញ្ជាក់ -- នៅពេលនោះមិនបានបញ្ជាក់ឲ្យបានច្បាស់លាស់អំពីការផ្លាស់ទីលំនៅដំណាក់កាលទី១។ ហេតុដូច្នេះសេចក្តីសន្និដ្ឋានពីខាងមេធាវីការពារក្តីអម្បាញ់មិញនេះ គឺមានចំណុចមួយមិនត្រឹមត្រូវអំពីប្រវត្តិដែលថា ហេតុអ្វីបានជាយើងខ្ញុំស្នើសុំដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

[១០:០៩:១៣]

ចំណុចមួយទៀតដែលខ្ញុំសូមបញ្ជាក់ផងដែរនោះ គឺថាក្រុមមេធាវីការពារក្តីមិនបានពិចារណាទៅលើករណីដែលដើមបណ្តឹងរដ្ឋប្បវេណីនេះ មកផ្តល់សក្ខីកម្មអំពីសិទ្ធិ -- តួនាទីរបស់ ខៀវ សំផន និង

អៀង សារី។ យើងបានស្ដាប់ឮសក្ខីកម្មដែលពីសាក្សីមុនរួចមកហើយ ក៏ប៉ុន្តែមិនមែនថាយើងមិនត្រូវស្ដាប់ទៀតនោះទេពីអ្នកផ្សេង។

យើងដឹងហើយថា តំណាងសហព្រះរាជអាជ្ញាអ្នកមានបន្ទុកក្នុងការបង្ហាញភស្តុតាង ហើយការពារក្តីជាអ្នកតទល់។ ហើយដើមបណ្ដឹងរដ្ឋប្បវេណីនេះ គឺមកផ្ដល់សក្ខីកម្មអំពីតួនាទីរបស់ជនជាប់ចោទពីរនាក់ មិនមែនតែម្នាក់នោះទេ។ ដូច្នេះទើបគាត់មានភាពចាំបាច់ត្រូវមកផ្ដល់សក្ខីកម្ម។

ចំណុចមួយទៀតនោះ គឺមេធាវីការពារក្ដី ខៀវ សំផន បានលើកឡើងអំពី សំណុំរឿង ០០២/០១។ គាត់ហាក់ដូចជាមិនបានគិតថាតួនាទី អង្គហេតុពាក់ព័ន្ធទៅនឹងតួនាទីរបស់ដើមបណ្ដឹង -- របស់ជនជាប់ចោទនេះគឺមានសារៈសំខាន់នោះទេ។ តាមពិតវាមានសារៈសំខាន់ណាស់ ដែលយើងត្រូវស្ដាប់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

[១០:១០:២៣]

**លោក អាកឡូវ វ៉ែកគែន៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតបដោយសង្ខេប។ ខ្ញុំមានឯកសារមួយ គឺ D22/3732 -- 62 (សូមទោស) ដែលជាពាក្យសុំតាំងខ្លួនដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំមិនដឹងថាតើសហព្រះរាជអាជ្ញាបានយោងទៅលើឯកសារមួយនេះទេ ដែលថាគាត់បានកែប្រែខ្លឹមសារនៃពាក្យសុំតាំងខ្លួនរបស់គាត់នោះ។ ហើយខ្ញុំមិនបានឃើញថានៅក្នុងពាក្យសុំរបស់គាត់មាននិយាយអំពីបឹងត្របែកទេ។ ខ្ញុំ -- ដូច្នេះមិនដឹងថាតើសហព្រះរាជអាជ្ញាគាត់យោងទៅលើឯកសារណាមួយនោះទេ។ ខ្ញុំបញ្ជាក់ម្ដងទៀត ឯកសារអម្បាញ់មិញនេះ គឺលេខ D22/3762។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន។ ហើយនៅក្នុងសេចក្ដីសង្ខេបនោះ ក៏មិនមានលើកឡើងចំណុចដែលសហព្រះ-រាជអាជ្ញាលើកឡើងផងដែរ។ អ្វីដែលយើងមាន គឺអត់មានទេ។ នេះជាឯកសារផ្ដល់ជូនពីខាងដើម-បណ្ដឹងរដ្ឋប្បវេណី។

[១០:១១:២៥]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសូមថ្លែងអំណរគុណចំពោះមតិយោបល់របស់អស់លោក លោកស្រីជាភាគីនៅក្នុងរឿងក្ដីនេះ លើបញ្ហាដែលអង្គជំនុំជម្រះបានដាក់ជូននូវភាគីពិភាក្សា ហើយអង្គជំនុំជម្រះនឹងយក

-- មានមូលដ្ឋានក្នុងការបំពេញបន្ថែមលើឯកសារដែលពាក់ព័ន្ធលើបញ្ហានេះ ដើម្បីយកទៅពិភាក្សាសម្រេចលើករណីដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានរហស្សនាម TCCP-94 នៅក្នុងពេលវេលាសមស្របឆាប់ៗខាងមុខនេះ។

បាទ ឥឡូវនេះក៏ដល់ពេលសមល្មមសម្រាកដែរហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់សាមសិបនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:១២ នាទី ដល់ម៉ោង ១០:៣៣ នាទី)*

[១០:៣២:៥៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយមុននឹងអញ្ជើញសាក្សីដែលមានរហស្សនាម TCW-100 ចូលមកកាន់កន្លែងបន្ទប់សវនាការ។ អង្គជំនុំជម្រះសម្រេចលើបញ្ហាដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-94 ដូចខាងក្រោមនេះ៖

ក្រោយពីស្ដាប់នូវមតិយោបល់របស់ភាគីលើបញ្ហាកោះហៅ ឬមិនកោះហៅដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-94 អង្គជំនុំជម្រះសម្រេចផ្អាកការកោះហៅនេះសិន អង្គជំនុំជម្រះនឹងពិនិត្យឡើងវិញនូវភាពពាក់ព័ន្ធនៃសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ជាមួយនឹងសក្ខីកម្មសាក្សី និងសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដទៃទៀត ហើយអង្គជំនុំជម្រះនឹងសម្រេចបញ្ហានេះនៅពេលសមស្របខាងមុខ។

មន្ត្រីរដ្ឋបាលសូមអញ្ជើញសាក្សីដែលមានរហស្សមានTCW-100 ហើយនិងមេធាវីប្រឹក្សារបស់គាត់ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកសាក្សី។ តើលោកឈ្មោះអី?

**លោក ឆោម សែ៖**

**ឆ៖** ខ្ញុំបាទ ឈ្មោះ ឆោម សែ។

**ស៖** អរគុណលោក ឆោម សែ។ ក្រៅពីឈ្មោះ ឆោម សែ តើលោកធ្លាប់ប្រើ ឬក៏មានឈ្មោះហៅក្រៅផ្សេងទៀតដែរឬទេ?

**ឆ៖** បាទ មិនបានប្រើឈ្មោះផ្សេងទៀតទេ។

**ស៖** អរគុណ។ លោក ឆោម សែ តើលោកមានអាយុប៉ុន្មានឆ្នាំហើយ? ឬក៏លោកអាចប្រាប់អង្គសវនាការអំពីថ្ងៃខែឆ្នាំកំណើតរបស់លោកបានដែរឬទេ?

**ឆ៖** បាទ ជម្រាបជូនបាន។ ខ្ញុំបាទ ថ្ងៃទី១៥ ខែ៩ ១៩៥០។

[១០:៣៧:០២]

**ស៖** អរគុណ ហើយលោក ឆោម សែ តើទីកន្លែងកំណើតរបស់លោក លោកកើតនៅទីកន្លែងណា?

**ឆ៖** ខ្ញុំបាទកើតនៅភូមិដីក្រហម ឃុំព្រៃរំដេង ស្រុកគិរីវង់ ខេត្តតាកែវ។

**ស៖** អរគុណ។ តើទីលំនៅសព្វថ្ងៃរបស់លោក តើលោករស់នៅទីកន្លែងណា?

**ឆ៖** បាទ ទីលំនៅខ្ញុំបច្ចុប្បន្ន រស់នៅភូមិលំទងថ្មី ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

**ស៖** អរគុណ។ តើលោកប្រមុខរបររកស៊ីធ្វើអ្វីដែរសព្វថ្ងៃនេះ?

**ឆ៖** បាទ សព្វថ្ងៃនេះធ្វើស្រែធ្វើចម្ការ ហើយនិងជាប់និវត្តន៍ជន -- អ៎! ជនដែលចូលនិវត្តន៍ ជាប្រធានសមាគម អតីតយុទ្ធជនប្រចាំក្នុងស្រុកអន្លង់វែង។

**ស៖** បាទ អរគុណ។ តើលោកអាចប្រាប់អំពីឈ្មោះនាមត្រកូល និងនាមខ្លួន ឪពុក និងម្ដាយរបស់លោកបានដែរឬទេ តើគាត់ឈ្មោះអី?

[១០:៣៨:៣០]

**ឆ៖** បាទ ឪពុកខ្ញុំបាទ ឈ្មោះ ឆោម សំ។ បាទ ម្ដាយ គឹម ម៉ន។

**ស៖** ចុះប្រពន្ធរបស់លោកគាត់ឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ! ក្បាលមីក្រូហ្វូនមិនទាន់ប្រតិបត្តិការទេ។

**លោក នោម សែ៖**

**ឆ៖** ប្រពន្ធខ្ញុំបាទ ឈ្មោះ អន សុភាព។ បាទ មានកូន៤នាក់ សព្វថ្ងៃ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** បាទ អរគុណ។ លោក នោម សែ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះ ថាតាមសមត្ថភាពដែលលោកអាចដឹង គឺលោកមិនជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងបុគ្គលទាំងឡាយ ដែលត្រូវបានទទួលយកធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងក្តី០០២ នេះទេ ហើយក៏មិនញាតិលោហិត ឬញាតិពន្ធ ជាមួយនឹងជនជាប់ចោទទាំងបីនាក់ដែរ គឺលោក នួន ជា, លោក អៀង សារី និងលោក ខៀវ សំផន។ តើពិតមែនដែរឬទេ?

**ឆ៖** បាទ ពិតប្រាកដមែន។

**ស៖** អរគុណ។ ហើយតាមរបាយការណ៍ក្រឡាបញ្ជីសវនាការដដែលថា លោកបានធ្វើសម្បថចំពោះមុខអ្នកតាដំបងដែករួចហើយ មុនពេលលោកចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ។ តើពិតមែនដែរទេ?

[១០:៤០:00]

**ឆ៖** បាទ ពិតប្រាកដមែន។

**ស៖** បាទ ហើយកត់សម្គាល់ផងដែរថា នៅក្នុងកិច្ចដំណើរការស្តាប់សក្ខីកម្មរបស់លោកនេះ លោកបានទទួលយកនូវមេធាវីប្រឹក្សាសាក្សី គឺលោក លឹម ប៊ុនហេង។ លោក នោម សែ យើងសូមប្រាប់អំពីសិទ្ធិ និងករណីយកិច្ចក្នុងនាមលោកសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ ក្នុងនាមលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការស្នើសុំឲ្យលោកធ្វើអំណះអំណាង ឬក៏ការធ្វើអត្ថាធិប្បាយណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងខ្លួនឯង ដោយមានន័យថា ដោយសារតែចម្លើយ ឬអំណះអំណាងនោះនាំឲ្យលោកនឹងត្រូវទទួលរងការចោទប្រកាន់។ ហើយក្នុងការអនុវត្តសិទ្ធិនេះ លោកមានមេធាវីប្រឹក្សារួចហើយ។ អ៊ីចឹងគឺលោកអាច ករណីដែលមានការពាក់ព័ន្ធនឹងសំណួរ ឬក៏សុំឲ្យលោកធ្វើអត្ថាធិប្បាយនូវសំណួរតបទៅនឹងសំណួរ ឬក៏អត្ថាធិប្បាយបែបនេះ គឺលោកអាចពិភាក្សាជាមួយនឹងមេធាវីប្រឹក្សារបស់លោកដើម្បីឆ្លើយ ឬក៏មិនឆ្លើយតប។

[១០:៤១:៣៥]

ករណីយកិច្ចក្នុងនាមលោកជាសាក្សី ដែលត្រូវផ្តល់សក្ខីកម្មនៅក្នុងកិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកត្រូវឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរលោក។ លើកលែងតែករណីឆ្លើយតបនឹងសំណួរ ឬការធ្វើអត្ថាធិប្បាយណាមួយច្រើនដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ លោកជាសាក្សីត្រូវតែឆ្លើយការណាដែលពិត ដែលលោកបានឃើញ បានដឹង បានឮ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ នូវហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរ ដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរលោក។ តើលោកយល់អំពីសិទ្ធិ និងករណីយកិច្ចក្នុងនាមលោកជាសាក្សីនេះដែរឬទេ?

**ឆ៖** បាទ យល់ទាន។

**ស៖** លោក ឆោម សែ តើលោកមានដែលធ្លាប់ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ? ហើយប្រសិនបើមានការធ្វើកិច្ចសម្ភាសន៍នោះ តើប្រព្រឹត្តទៅប៉ុន្មានលើក?

[១០:៤២:៤៧]

**ឆ៖** ធ្លាប់ដែរ ធ្លាប់មានចំនួនប្រហែលជា៤លើក។

**ស៖** លោកចាំទេថា ការធ្វើកិច្ចសម្ភាសន៍ហ្នឹងនៅ ធ្វើនៅទីកន្លែងណា ហើយនៅពេលណា?

**ឆ៖** នៅក្នុងឆ្នាំ២០១០នេះគឺចំនួន២លើក។ បាទ ដល់២០១០ -- ២០១១នេះដូច២លើកដែរ នៅផ្ទះខ្ញុំបាទ។

**ស៖** បាទអរគុណ។ ហើយនៅមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ តើលោកបានពិនិត្យ ឬក៏បានអាននូវកំណត់ហេតុដែលបានកត់ត្រានូវបទសម្ភាសន៍របស់លោកនៅជាមួយនឹងសហចៅក្រមស៊ើបអង្កេត ដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** បាទ បានរំឭកដែរ បានអានដែរ ប៉ុន្តែវាដូចជាច្រើនករណីដែរ វាដូចជាចាំមិនអស់ដែរ។

**ស៖** តាមលោកចាំ តើលោកបានអាននូវកំណត់ហេតុប៉ុន្មាន? ចំនួនប៉ុន្មាន? កុំអាលទាន់ឆ្លើយ! បង្អង់បន្តិច ចាំភ្លើងក្រហមជាសញ្ញាថា ក្បាលមីក្រូហ្វូនប្រតិបត្តិការ លោកអាចឆ្លើយបានណេះ។

[១០:៤៤:៤១]

**ឆ៖** បាទបានពិនិត្យដែរ។ វាមានចំនួន៤លើកហ្នឹងដែរ បាទតែវាក៏មិនចាំមិនអស់ទេ បើវាមានកន្លែងសំណួរខ្លះវាវែងដែរ។

**ស៖** តាមការបញ្ជាក់របស់លោកអម្បាញ់មិញថា លោកធ្វើសម្ភាសនៅឆ្នាំ២០១១ ចំនួន២លើក តើច្បាស់ទេ ឬក៏មានការភ័ន្តច្រឡំលើបញ្ហាធ្វើផ្តល់កិច្ចសម្ភាសន៍ក្នុងចំនួនបួនលើកហ្នឹង គឺមានពីរលើកធ្វើនៅក្នុងឆ្នាំ២០១១?

**ឆ៖** តាមពិនិត្យនែ៎ ដូចជា២០០៩ បាទ ខ្ញុំពិនិត្យ២០១១ ដូចមិនមានទេ មានតែ២០១១ អ៊ំ! ២០០៩ និង២០១០បាទ។ អ៊ំមិញថាទៅវាដូចជាវាហួស។

**ស៖** បាទ អរគុណហើយតាមសមត្ថភាពដែលលោកអាចដឹងនិងចងចាំ ថាតើលោកអាចបញ្ជាក់បានដែរថា កំណត់ហេតុដែលកត់ត្រានូវបទសម្ភាសន៍របស់លោក ដែលលោកបានធ្វើជាមួយនឹងអ្នកស៊ើបអង្កេត ហើយលោកបានអានឡើងវិញ ដើម្បីរំឭកការចងចាំនេះ តើវាមានខ្លឹមសារត្រឹមត្រូវសមស្របទៅនឹងចម្លើយ ដែលបានលោកបានធ្វើសម្ភាសជាមួយនឹងអ្នកស៊ើបអង្កេតកាលពីឆ្នាំ២០០៩ និង ២០១០ ដែលលោកបាននិយាយអម្បាញ់មិញនេះដែរឬទេ?

[១០:៤៦:១៦]

**ឆ៖** បាទ ភាគច្រើនតាមដែលខ្ញុំពិនិត្យ ការចម្លើយដែលពាក់ព័ន្ធរបស់ផ្ទាល់ខ្លួនបានលើកឡើង គឺជាធាតុពិតច្រើន មិនសូវមានបញ្ហាអីដែលថាវា មិនច្បាស់លាស់ហ្នឹងទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះសូមជម្រាបជូនតំណាងសហព្រះរាជអាជ្ញាថា ក្នុងកិច្ចដំណើរការសវនាការពិភាក្សាដេញដោលស្តាប់សក្ខីកម្មសាក្សីរូបនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនតំណាងសហព្រះរាជអាជ្ញាតាំងសំណួរដេញដោលចំពោះសាក្សីនេះមុនភាគីដទៃទៀតនៃរឿងក្តី។ ហើយតំណាងសហព្រះរាជអាជ្ញា រួមទាំងតំណាងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេល១ថ្ងៃក្នុងការសួរដេញដោលសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក ច័ន្ទ តារាស្មី៖**

បាទ អរគុណ សូមគោរពលោកប្រធាន! សូមគោរពលោក លោកស្រីចៅក្រម! សូមគោរពអស់លោក លោកស្រីទាំងអស់ដែលមានវត្តមាននៅក្នុងសវនាការនាពេលនេះ!

សូមជម្រាបសួរលោក ឆោម សែ! ខ្ញុំឈ្មោះ ច័ន្ទ តារាស្មី សហព្រះរាជអាជ្ញារងជាតិនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានាពេលនេះ។ ខ្ញុំសូមសួរលោកនៅពេលនេះ ក្នុងនាមតំណាងឱ្យសហព្រះរាជអាជ្ញា។

ជាដំបូងខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ប្រសិនបើលោកប្រធានមិនយល់ទាស់ទេ ខ្ញុំសូមអនុញ្ញាត ដើម្បីប្រគល់ឯកសារកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីទាំងបួនលើក ដែលលោក ឆោម សែ បាន ឆ្លើយនៅចំពោះមុខមន្ត្រីស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីជាការជួយរំឭកដល់ ការចងចាំរបស់គាត់ ងាយស្រួលដល់ការឆ្លើយរបស់គាត់ ដើម្បីចម្លើយរបស់គាត់មានប្រសិទ្ធភាពនៅ ក្នុងពេលនេះបាទ។ ប្រសិនបើលោកប្រធានអនុញ្ញាត ខ្ញុំសូមប្រគល់ឯកសារនេះជូនគាត់។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត ប៉ុន្តែលោកបង្ហាញអត្តញ្ញាណឯកសារផង។

**លោក ច័ន្ទ តារាស្មី៖**

សូមអរគុណ។ ឯកសារដែលខ្ញុំបង្ហាញជូនគាត់នេះគឺ ឯកសារ E3/405 ៗ ជាភាសាខ្មែរ ជា ភាសាអង់គ្លេស និងជាភាសាបារាំង។ D232/50, បាទ ឯកសារ E3/407, D232/53, ឯកសារ D369/8។ ឯកសារទាំងអស់នេះគឺមាននៅក្នុងសំណុំរឿង។ ខ្ញុំសូមអនុញ្ញាតពីលោកប្រធានដើម្បីប្រគល់ ជូនទៅដល់លោកសាក្សីឈ្មោះ ឆោម សែ នៅពេលនេះបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះ រាជអាជ្ញា យកជូនសាក្សីពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[១០:៤៩:៣៣]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** បាទ លោក ឆោម សែ ខ្ញុំសូមអនុញ្ញាតសួរសំណួររបស់លោក។ សំណួរដំបូងគឺទាក់ទិន ទៅនឹងប្រវត្តិរបស់លោកក្នុងការចូលរួមក្នុងចលនាបដិវត្តន៍។ យោងតាមឯកសារ E3/405, D232/49 ដែលជាចម្លើយរបស់លោក ឆ្លើយនៅចំពោះមុខមន្ត្រីស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើប អង្កេត លោកបានឆ្លើយបញ្ជាក់ថា “គឺលោកបានចូលរួមក្នុងចលនាបដិវត្តន៍នៅឆ្នាំ១៩៧០”។ ខ្ញុំចង់ដឹង ថាតើមានមូលហេតុអ្វីបានជាលោកសម្រេចចិត្តចូលក្នុងបដិវត្តន៍នោះបាទ?

**លោក ឆោម សែ៖**

**ឆ៖** បាទ មូលហេតុដែលខ្ញុំចូលក្នុងចលនាបដិវត្តន៍នេះ សំខាន់ទិសដៅដំបូងមិនទាន់យល់ពីផ្នែកនយោបាយអីផ្សេងៗទេ។ ប៉ុន្តែក្នុងចលនាសម័យ១៨នេះគឺ តាមការណែនាំ ឬមតិអំពាវនាវមកគឺសម្តេច។ បាទ សម្តេចគាត់ថាគឺមានតែព្រៃម៉ាកគីទេ ដែលជាព្រៃឋានសុខស្រួលដើម្បីគិតគូរក្នុងបញ្ហារំដោះជាតិ។ ហើយវាសមស្របនឹងសភាពការណ៍នៅតាមព្រំដែន នៃកំណើតស្រុកខ្ញុំបាទផង ក៏មើលទៅវាមានបញ្ហាអាប់អួរច្រើនដែរ ក៏ឃើញ យល់បញ្ហាហ្នឹង ក៏ចូលរួមក្នុងចលនាតស៊ូហ្នឹងតទៅ បាទ។

[១០:៥១:១៤]

**ស៖** បាទ អរគុណ។ តើនៅពេលនោះលោកមានអាយុប៉ុន្មានឆ្នាំ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ!

**លោក ឆោម សែ៖**

**ឆ៖** មិនបានមើលភ្លើងបាទ។ ក្នុងឆ្នាំ១៩៧០ ខ្ញុំបាទមានអាយុ២០ឆ្នាំ។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** តើលោកអាចបញ្ជាក់បានទេថា នៅពេលដែលលោកចូលរួមក្នុងបដិវត្តន៍នោះ តើលោកចូលទៅក្នុងកងទ័ព ក្នុងក្រុមកងទ័ពណាមួយ ឬក៏អង្គភាពណាមួយរបស់ខ្មែរក្រហម?

[១០:៥២:០១]

**ឆ៖** បាទ កាលចូលដំបូង បើនិយាយអំពីរឿងចលនាខ្មែរក្រហមហ្នឹង ដូចជាមិនទាន់បានទាក់ទាមអីទេ បាទ។ ប៉ុន្តែនៅក្នុងមូលដ្ឋាន ក្នុងឃុំព្រះបាទជាន់ជុំហ្នឹងវាមានចលនាសភាពការណ៍ ប្រមែប្រមូលគ្នាហ្នឹងក៏បានចូលរួម។ រួមហ្នឹងទិសដៅតែពលរដ្ឋខ្មែរយើងទាំងអស់មកចូលរួមនៅក្នុងឃុំហ្នឹងតែម្តង។ បាទ សម្រាប់ធ្វើចលនាតស៊ូហ្នឹង ហើយមិនទាន់រួមសហការជាមួយវៀតណាមដែរកាលហ្នឹង។ វាមិនទាន់មានខ្មែរបណ្តាញ ប៉ុន្តែនៅក្នុងប្រចាំក្នុងស្រុកហ្នឹងនៅឡើយ។ ដល់បន្តទៅមកវាចេះតែមានចលនាហ្នឹងវាវែងឆ្ងាយតៗមក វាចេះតែធ្វើចលនាតាមអត្ថបទនៃចម្លើយខ្ញុំបាទហ្នឹង ធ្វើដំណើរតាមរយៈកាលហ្នឹងមក។ រហូតមកដល់កំពង់ស្ពឺនេះ បន្តបន្ទាប់មក ក៏ចូលព្រៃសហការជាមួយវៀតណាមហ្នឹងទៅ ជាប់នឹងចលនាហ្នឹងរហូតមក បាទក្នុងរយៈកាលឆ្នាំ៧០។

**ស៖** តើនៅពេលនោះ លោកធ្លាប់បានកាន់មុខតំណែង ឬក៏តួនាទីអ្វីនៅក្នុងពេលដែលលោកចូលរួមក្នុងចលនាតស៊ូនោះបាទ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

អត់ៗទាន់! ក្បាលមីក្រូហ្វូនអត់ប្រតិបត្តិការទេ។

[១០:៥៣:២៨]

**លោក នោម សែ៖**

**ឆ៖** បាទវា ដំបូងវាអត់ទាន់មានកាន់ទទួលនាទីតំណែងអីទេ វាគ្រាន់តែក្នុងឋានៈជាយុទ្ធជននៅឡើយ។ ប៉ុន្តែដល់តែរួមកិច្ចសហការជាមួយកងទ័ពវៀតណាមទៅ ក៏បានរួមចលនាតស៊ូហ្នឹងនៅជាមួយគ្នាក្នុងរយៈកាល១ឆ្នាំ បានមានអង្គភាពខ្មែរហ្នឹងបានបង្កលក្ខណៈរៀបជាកងទ័ព តស៊ូនៅក្នុងតំបន់កំពង់ស្ពឺនេះ និងតំបន់តាកែវនេះ ក៏រៀបកងទ័ពមួយ កងទ័ពរបស់ប្រចាំភូមិភាគ គឺកងលេខ៦ ហៅ ១៦០ កងហ្នឹងបន្តបន្ទាប់មក ហើយក៏រួមចលនាហ្នឹងទៅ។ ជាប់ចលនាហ្នឹងជាបន្តបន្ទាប់មក ក្នុងចលនាតស៊ូនេះ បាទ នេះក្នុងឆ្នាំ១៩៧០, ៧១ បន្តមកទៀត បាទ។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** បាទ អរគុណ។ នៅក្នុងចម្លើយរបស់លោកលើកដំបូង លើកទី១ លោកបានឆ្លើយថា "លោកបានឆ្លើយថា លោកធ្លាប់ត្រូវបានគេតែងតាំងឲ្យធ្វើជាប្រធានក្រុមគ្រប់គ្រងយោធា"។ តើនេះជាការពិតដែរឬទេបាទ?

[១០:៥៤:៥៨]

**ឆ៖** បាទ អាហ្នឹងជាពិតហើយ នៅក្នុងឆ្នាំ១៩៧១ ព្រោះរៀបចំអង្គភាពខ្មែរ។ ខ្ញុំបាទ បានធ្វើមេក្រុមមែន រួមចលនាតស៊ូនៅក្នុងរយៈកាលឆ្នាំ៧១នោះ។

**ស៖** សូមអរគុណ។ តើក្នុងនាមលោកជាមេក្រុមគ្រប់គ្រងកូនទាហាននៅពេលនោះ តើលោកទទួលខុសត្រូវអ្វីខ្លះ? ហើយលោកមានសិទ្ធិអំណាចក្នុងការសម្រេចកិច្ចការអ្វីខ្លះ បាទ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

អត់ទាន់ ក្បាលមីក្រូហ្វូនអត់ទាន់ប្រតិបត្តិការទេ។ ចាំមើលសិនណ៎ះ! មើលសញ្ញាក្រហម

ជាសញ្ញាបញ្ជាក់ថា ក្បាលមីក្រូហ្វូនប្រតិបត្តិការ សូមលោកចាប់ផ្ដើមនិយាយ។

[១០:៥៥:៥៦]

**លោក នោម សែះ**

**ឆ៖** ក្នុងឋានៈធ្វើជាមេក្រុមនោះ គ្រប់គ្រងកម្លាំង ហើយនិងដឹកនាំធ្វើការងារ និងដឹកនាំប្រយុទ្ធលើសមរភូមិបាទ។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** សូមអរគុណបាទ។ អម្បាញ់មិញ លោកបានមានប្រសាសន៍ថា កងទ័ពរបស់លោកធ្លាប់សហការជាមួយនឹងកងទ័ពរបស់វៀតណាមខាងជើង តើនេះជាការពិត? ហើយមូលហេតុអ្វីបានជាមានការសហការជាមួយនឹងកងទ័ពវៀតណាមខាងជើង? ហើយសហការនេះ កិច្ចសហការនេះកើតឡើងនៅពេលណាបាទ?

**ឆ៖** នៅក្នុងឆ្នាំ១៩៧០នេះ បើយើងនិយាយអំពីចលនាតស៊ូនេះ វាមានការកិច្ចសហការជាមួយចលនាដែលកម្លាំងវៀតណាមខាងជើងនេះ មកចូលរស់ក្នុងប្រទេសខ្មែរយើង បានជាមានកម្លាំងហ្នឹងសហការកន្លងទៅ។ បើគ្មានកម្លាំងហ្នឹង ការប្រាស្រ័យគ្នាទេ កម្លាំងខ្មែរក្រហមនេះ ក៏មានអត់មានលទ្ធភាព មិនបានមកឃោសនា មិនបានមកគ្រប់គ្រងកម្លាំងជាបន្តបន្ទាប់ដែរ ព្រោះកម្លាំងវាតិច ចលនានោះដំបូង។

**ស៖** បាទ សូមអរគុណ។ ដោយសារពេលវេលាមានកំណត់ ដូច្នេះ ខ្ញុំសូមអនុញ្ញាតសួរបន្តទៅទៀត តែខ្ញុំផ្ដោតសំណួរសំខាន់ៗតែប៉ុណ្ណោះ គឺខ្ញុំសូមឆ្លងចូលទៅប្រធានបទមួយទៀត ទាក់ទងនឹងរចនាសម្ព័ន្ធកងទ័ពបដិវត្តន៍កម្ពុជា។ សូមលោកជួយពន្យល់ជូនអង្គសវនាការនៅពេលនេះ ឲ្យបានជ្រាបអំពីរចនាសម្ព័ន្ធកងទ័ពខ្មែរក្រហម ចាប់តាំងពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧២ បាទ?

[១០:៥៧:៥៤]

**ឆ៖** រចនាសម្ព័ន្ធរបស់កងទ័ព បើនិយាយទៅកងទ័ពខ្មែរក្រហមសម័យនោះ វា -- ខ្ញុំបាទដឹងតែក្នុងមួយភូមិភាគទេ បាទ វាមិនបានដឹងទូទាំងប្រទេសទេ។ បាទ ព្រោះកិច្ចការងារដឹកនាំវាមានកម្រិតទាបដែរ។ ដឹងតែប៉ែកខាងត្បូងនេះ ចលនានេះ វាមានកងទ័ព វាមានកង១១០, កង១២០ កង១៤០, កង១៥០, កង១៦០, កង១៧០, កង១៩០ អានេះខាងភូមិនិរតី ខ្ញុំដឹងតែប៉ុណ្ណឹងទេ ចលនា។ បាទ នៅឆ្នាំ១៩៧០ -- ៧១ ដែលរៀបចំកម្លាំងឈានមកដល់ ៧២ បាទ ចលនាប៉ែកខាងត្បូងនេះ។

**ស៖** បាទ សូមអរគុណ។ តើនៅក្នុងអង្គភាពរបស់លោក លោកទទួលបញ្ជា ឬក៏អនុវត្តតាមបញ្ជាពីថ្នាក់ណាដែរបាទ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់--

**លោក ឆោម សែ៖**

**ឆ៖** បាទ ក្នុងអង្គភាពដែលយើងខ្ញុំបាទរស់នៅនេះ គឺជាអង្គភាពក្នុងអនុសេនាតូចទី១ ហើយនិងអនុសេនាធំទី១នេះ លេខ១១នេះ វានៅក្នុងកងវរសេនាតូច១៦០ វរៈ៦ ហៅ១៦០ បន្តទៅនៅប្រចាំភូមិភាគរបស់ប៉ែកខាងនិរតី។ ក្រោមការដឹកនាំរបស់វរសេនាតូចនេះ មានឈ្មោះ សួរ សារឿន ហ្នឹងជាប្រធានវរសេនាតូច១៦០នេះ។

[១០:៥៩:៥០]

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** បាទ អរគុណ។ តើពីណាគេ នៅលើពីលោក សួរ សារឿន?

**ឆ៖** កងទ័ពសម័យនោះ វាមានតែត្រឹមវរសេនាតូចនោះ ឯពីលើ សួរ សារឿន ហ្នឹងទៀតវាមានតែ ឈិត ជឿន ហៅម៉ុក ហ្នឹងបាទ។ គាត់គ្រប់គ្រងភូមិភាគ។

**ស៖** បាទសូមអរគុណ។ នៅក្នុងឯកសារនៃការស្តាប់ចម្លើយសាក្សី ក្នុងចម្លើយទី២របស់លោក យោងឯកសារ E3/405 លោកបានឆ្លើយថាយុទ្ធភូមិភាគពិសេសត្រូវបានបង្កើតឡើង។ តើលោកអាចបញ្ជាក់ជូនអង្គសវនាការនៅពេលនេះជ្រាបបានដែរឬទេថា មានមូលហេតុអ្វីបានជាបង្កើតយុទ្ធភូមិភាគពិសេសនេះឡើង?

**ឆ៖** ខ្ញុំបាទមិនសូវដឹងពីយុទ្ធសាស្ត្រជ្រាលជ្រៅទេសម័យនោះបាទ។ ប៉ុន្តែគ្រាន់តែភូមិភាគពិសេសនេះដកចេញពីភូមិភាគផ្នែកផ្សេងៗមក ដើម្បីធ្វើចលនាតស៊ូក្នុងប្រព័ន្ធទីក្រុង បាទ រាជធានីភ្នំពេញយើងនេះ បានបង្កើតជាភូមិភាគពិសេស។ ហើយភូមិភាគពិសេសនោះតាមលំដាប់ការរៀបចំកន្លងទៅវាមានបីកងពលទេ ប្រចាំនៅក្នុងតំបន់ភូមិភាគពិសេស។ ជុំវិញភ្នំពេញពីខាងកើត ពីខាងត្បូង និងប្រឆាកខាងលិចមកបាទ។

[១១:០១:៤១]

**ស៖** បាទ តើលោកអាចបញ្ជាក់បានអំពីទីតាំងដែលយុទ្ធភូមិភាគពិសេសនេះស្ថិតនៅដែរឬទេ? តើយុទ្ធភូមិភាគពិសេសនេះបង្កើតឡើងនៅក្នុងទីតាំងណាដែរបាទ?

**ឆ៖** ទីតាំងរបស់យុទ្ធភូមិភាគពិសេសនេះ វាដូចខ្ញុំបានលើកថា វាមាន៣កងពល ប៉ុន្តែកងពលលេខ១២ ប្រចាំប៉ែកខាងកើត។ កងពលលេខ១១នេះ វាប្រចាំប៉ែកខាងត្បូងនេះ។ កងពលលេខ១៤នេះ ប្រចាំប៉ែកខាងជើង ប្រឆាកខាងលិចនេះមក។ មានតែបីទិសនេះបាទ។

**ស៖** បាទសូមអរគុណ។ តើអ្នកណាធ្លាប់ធ្វើជាប្រធានយុទ្ធភូមិភាគពិសេសនេះបាទ។

**ឆ៖** គឺឈ្មោះ វន វ៉េត បាទ។

**ស៖** តើលោក វន វ៉េត ជាអ្នកណា ហើយគាត់ទទួលខុសត្រូវអ្វីខ្លះនៅពេលនោះ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយៗ! រង់ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការសិន។

[១១:០៣:២៥]

**លោក នោម សែ៖**

**ឆ៖** បាទ កាលសម័យនោះ ខ្ញុំបាទក៏មិនសូវដឹងជ្រាលជ្រៅដែរប៉ុន្មានដែរ ប៉ុន្តែគ្រាន់តែថាការដឹកនាំ ការគ្រប់គ្រងរបស់តាមផ្នែកកងពលនីមួយៗ ដឹងតែសភាពការណ៍ជាក់ស្តែងចំពោះតែក្នុងកងពលរបស់ខ្លួនកាលដែលខ្ញុំស្ថិតនៅក្នុងកងពល១១ បាទ។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** បាទ សូមអរគុណ។ តើលោកដឹងថាលោក វន វ៉េត ធ្វើជាប្រធានយុទ្ធភូមិភាគពិសេសនេះ លោកដឹងព័ត៌មាននេះមកពីប្រភពណា? អ្នកណាជាអ្នកប្រាប់លោក?

**ឆ៖** គឺមេបញ្ជាការកងពលនេះឯង គឺលោក សួរ សារឿន នេះឯង។

**ស៖** អរគុណ។ តើនៅចន្លោះឆ្នាំ១៩៧៣ ដល់ខែមេសា ឆ្នាំ១៩៧៥ លោកស្ថិតនៅក្នុងកងពលណាដែរបាទ?

**ឆ៖** ក្នុងឆ្នាំ១៩៧៣ៗ ខ្ញុំក៏ស្ថិតនៅក្នុងកងពល១១ ដដែល មិនទាន់ប្រែប្រួលទៅឯណាទេ។

[១១:០៥:០២]

**ស៖** បាទ អរគុណ។ គិតមកដល់ពេលរំដោះទីក្រុងភ្នំពេញ តើកងពលលេខ១១ ស្ថិតនៅដដែល ឬក៏មានការផ្លាស់ប្តូរឈ្មោះកងពល ឬក៏មានការផ្លាស់ប្តូរមេកងពល? សូមលោកជួយបញ្ជាក់អំពីចំណុច

នេះបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អត់ទាន់ -- លោកមើលឃើញទេ? មើលឃើញភ្លើងទេ?

**លោក ឆោម សែ៖**

មើលឃើញ។

**ប្រធានអង្គជំនុំ៖**

សូមអង្ងបន្តិចណ៎ា!

[១១:០៥:៤០]

**លោក ឆោម សែ៖**

**ឆ៖** បាទ កងពល១១ ក្នុងឆ្នាំ៧៣, ៧៤, ៧៤ នេះ ចុង៧៤នេះ វាអាចទៅប្ដូកជាមួយ១៤ ពាក់កណ្ដាល ពីប៉ែកខាងលិច ពីឆាកខាងជើងមកវិញ។ ដូច្នេះអង្គភាពខ្ញុំក៏ទៅត្បូងកង១៤នេះវិញ វ៉ៃបុកពីប៉ែកខាងជើងវិញ។ ចូលដល់៧៥ បានឈានវ៉ៃរំដោះទីក្រុងភ្នំពេញនេះ នៅក្នុងកងពល១៤វិញ។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** បាទ អរគុណ។ អម្បាញ់មិញលោកបានមានប្រសាសន៍ថា មានការបូកបញ្ចូលគ្នារវាងកងពលលេខ១១ និងកងពលលេខ១៤ តើនេះជាការពិតមែនទេបាទ? ហើយមានមូលហេតុអ្វីដែលតម្រូវឲ្យមានការបូកបញ្ចូលគ្នារវាងកងពលទាំងពីរនេះបាទ?

**ឆ៖** តាមខ្ញុំពិនិត្យក្នុងចលនាកន្លងទៅ វាឃើញថា ១៤នេះវាមានបញ្ហាបាត់បង់កម្លាំងច្រើន។ ដូច្នេះ១១ វាមានកម្លាំងច្រើន ហើយកម្លាំងពេញទេ វាស្នាក់ផ្លូវខាងណោះផ្លូវតូច បូកនឹង១២ ពីខាងកើត។ ដូច្នេះ១១ ត្រូវយកកម្លាំងពាក់កណ្ដាលទៅបូកជាមួយ១៤ មុននឹងវ៉ៃសម្រុកជុំវិញនៅទីក្រុងនេះ។

[១១:០៧:០៩]

**ស៖** បាទ ខ្ញុំសូមឲ្យលោកជួយបញ្ជាក់បន្ថែមឲ្យច្បាស់បន្តិចថា តើកងពលលេខ១១ ត្រូវបានបូកបញ្ចូលជាមួយនឹងកងពលលេខ១៤ ឬក៏កងពលលេខ១៤ ត្រូវបានបញ្ចូលទៅក្នុងកងពលលេខ១១? សូមលោកជួយបញ្ជាក់អំពីចំណុចនេះឲ្យបានច្បាស់បន្តិច។ សូមអរគុណ។

**ឆ៖** បាទ ១១ យកកម្លាំងទៅបូកនឹង១៤ បាទ។ ពីម្តុំឧដុង្គមក ទិសដៅតាមផ្លូវជាតិលេខ៥។ ហើយ១១នេះ ពាក់កណ្ដាលនេះ កម្លាំងគេនៅស្ថិតមុខព្រួញខាងត្បូងនេះដដែលបាទ។ ហើយដោយឡែក

តែអង្គភាពរបស់ខ្ញុំផ្ទាល់នេះ ស៊ូ សារឿន នេះក៏ទៅភ្ជាប់នឹង១៤វិញ លែងនៅ១១ ហើយ មេបញ្ជាការនេះ។

**ស៖** បាទ សូមអរគុណ។ ក្រោយពេលបញ្ចូលរវាងកងពលលេខ១១ និងកងពលលេខ១៤ បញ្ចូលគ្នា តើការបញ្ចូលគ្នារវាងកងពលទាំង២នេះ មានឈ្មោះហៅដើម្បីសម្គាល់នូវអង្គភាពនៃការបញ្ចូលកងពលទាំងពីរនេះដែរឬទេ?

[១១:០៨:៣៩]

**ឆ៖** បាទ មានឈ្មោះហៅ មែន។ បាទ ដល់ក្រោយមកវាបានមានសរុបកងពលទាំងបីនេះត្រូវប្រែឈ្មោះឡើងវិញ ដាក់ឈ្មោះថ្មី។ ក្រោយវ៉ៃសម្រុកចូលក្នុងទីក្រុងភ្នំពេញហើយ រំដោះភ្នំពេញនេះ ហើយក៏បានអង្គភាពនេះត្រូវប្រែឈ្មោះ កងពល១៤នេះទៅជា៨០១ ហើយកងពល១១ ទៅជា៦០៥ កងពល១២នេះវាទៅជា៧០៣។ បាទ ប្រចាំនៅក្នុងភូមិភាគពិសេស។

**ស៖** បាទ អរគុណ។ ក្រោយពេលបញ្ចូលកងពលទាំងពីរនេះ តើនៅពេលនោះលោកស្ថិតនៅក្នុងកងពលណា? ហើយលោកទទួលមុខតំណែងជាអ្វីដែរបាទ?

**ឆ៖** ការបញ្ចូលក្នុងកងពលនេះ ខ្ញុំទទួលតំណែងគឺជាចូលក្នុងរងអនុសេនាធំហើយ បញ្ជាការអនុសេនាធំរង នៅក្នុងកងពល៨០១។

**ស៖** បាទ អរគុណ។ ខ្ញុំសូមឲ្យលោកជួយបញ្ជាក់ក្នុងអំឡុងពេលនោះ តើលោកមានសិទ្ធិអំណាចក្នុងការសម្រេច ឬក៏ធ្វើកិច្ចការអ្វីខ្លះក្នុងកងពលរបស់លោក ដែលលោកគ្រប់គ្រងនោះបាទ? ឬក៏លោកធ្វើកិច្ចការនៅក្នុងកងពលនោះ តើលោកមានសិទ្ធិអំណាចអ្វីខ្លះ?

**ឆ៖** បាទ សិទ្ធិអំណាចមានតែការគ្រប់គ្រងរបស់កងអនុសេនាធំ មានចំនួនមនុស្សជាង១០០នាក់ តែប៉ុណ្ណឹងទេបាទ ខាងកិច្ចការងារយោធា។

**ស៖** បាទ អរគុណ។ ខ្ញុំនៅតែបន្តសួរសំណួរលោកមុននឹង មុនឆ្នាំ១៩៧៥ដដែល ទាក់ទងនឹងតួនាទីរបស់លោកបាទ។ សូមលោកជួយបញ្ជាក់ តើអ្នកណាជាមេដឹកនាំដ៏សំខាន់នៅកងពលរបស់លោកបាទ?

[១១:១១:០២]

**ឆ៖** មេសំខាន់នៅក្នុងកងពលបាទ សួរ សារឿន។

**ស៖** អរគុណ។ តើលោកអាចបញ្ជាក់អំពីតួនាទី ភារកិច្ច ឬក៏មុខតំណែង និងការទទួលខុសត្រូវ

របស់លោក សូរ សារឿន បានដែរឬទេបាទ?

**ឆ៖** សម័យ បាទ សម័យនោះគឺគេដឹកនាំរបៀបគេហៅថា "របបប្រធានមួយ"។ ដូច្នេះ អ្នកនយោបាយវាធំជាងយោធា។ បាទដូច្នេះ សូរ សារឿន ហ្នឹងគឺជាប្រធាននយោបាយ ផ្នែកខាងនយោបាយ ត្រូវទទួលបន្ទុករួមផ្នែកទាំងអស់។ បាទ កិច្ចការងារសម្រេច ហើយនិងមានទិស។ និយាយរួមវាទៅជាកងពលចល័តរបស់ប្រចាំប្រទេសហើយ ដូច្នេះគាត់មានទិសបាទ។ ដូច្នេះ -- ដោយឡែកតែអង្គភាពទេ ដែលត្រូវមានទិសក្រោយពីបញ្ចប់សង្គ្រាមមកក៏មានទិសទៅរតនគិរីតែម្តង ផ្នែកខាងជើង។

**ស៖** បាទ សូមអរគុណ។ តាមឯកសារបានបង្ហាញថានៅក្នុងពេលចលនាបដិវត្តន៍ តស៊ូនៅក្នុងពេលធ្វើចលនាបដិវត្តន៍នោះ តែងតែមានការប្រើឈ្មោះលេខកូដដើម្បីសម្គាល់បុគ្គល តើលោក សូរ សារឿន ដែលលោកបញ្ជាក់អម្បាញ់មិញនេះ សូរ សារឿនៗ ដែលលោកបញ្ជាក់អម្បាញ់មិញនេះ គាត់មានលេខកូដសម្គាល់លេខប៉ុន្មាន? លោកអាចបញ្ជាក់ ឬក៏លោកចងចាំបានដែរឬទេបាទ? ខ្ញុំចង់ដឹងអំពីកូដសម្គាល់លោក សូរ សារឿន នៅក្នុងពេលប្រើសម្រាប់អំឡុងពេលធ្វើបដិវត្តន៍នោះ។

[១១:១២:៥៨]

**ឆ៖** បាទ លេខកូដរបស់គាត់គេហៅ ០៥។

**ស៖** បាទ អរគុណ។ តើលោកស្គាល់លោក តាសាន ទេបាទ? តាសាន តើលោកស្គាល់ទេបាទ? តាសាន ជានរណា? ហើយគាត់ធ្វើកិច្ចការ ទទួលខុសត្រូវក្នុងនាមជាអ្វីដែរបាទ?

**ឆ៖** តាសាន នេះគាត់ជាមេបញ្ជាការរង បន្ទាប់ពី សូរ សារឿន។ បាទ លេខកូដរបស់គាត់គេហៅ ០៦។

**ស៖** តាសាន ជាមេបញ្ជាការរងនៅក្នុងកងពលលេខប៉ុន្មាន? សូមលោកជួយបញ្ជាក់លេខកងពលបន្តិចបាទ ឬអង្គភាពដែលគាត់ឈរជើងបាទ?

**ឆ៖** គឺកងពល៨០១។

**ស៖** បាទ អរគុណលោក ឆោម សែ។ ខ្ញុំសូមអនុញ្ញាតសួរបន្តទៀត។ តើលោកមានឋានៈ និងមុខតំណែងជាអ្វីនាដំណាក់កាលចុងក្រោយនៅក្នុងកងពលរបស់លោកមុនពេលរំដោះទីក្រុងភ្នំពេញ?

**ឆ៖** មុនពេលរំដោះទីក្រុងភ្នំពេញ ខ្ញុំបាទមានតំណែងជាអនុ បាទ អនុបញ្ជាការកងពល អ៎! កងអនុសេនាធំបាទ។ ដែលគេហៅថាអនុកងរយៗ ពីដើមជាទម្លាប់។

[១១:១៤:៤៧]

**ស៖** បាទ អរគុណ។ តើកងទ័ពរបស់លោក ឬក៏កងពលរបស់លោកធ្លាប់បានចូលរួមប្រយុទ្ធជាមួយនឹងកងទ័ពនៃរបប លន់ នល់ នៅក្នុងអំឡុងចន្លោះឆ្នាំ១៩៧៣ និងឆ្នាំ១៩៧៤ ដែរឬទេបាទ?

**ឆ៖** បាទ ធ្លាប់វ៉ៃទិសខាងត្បូង ផ្នែកខាងកំពង់ស្ពឺនេះ ហ្នឹងធ្លាប់កាលពីសម័យ លន់ នល់ នេះ។ ហើយមកវ៉ៃរំដោះទីក្រុងភ្នំពេញនេះ វ៉ៃទិសខាងត្បូង និងទិសខាងជើងនេះ ដែលសម្រេចចុងក្រោយ បាទ ខាងជើងភ្នំពេញនេះ។

**ស៖** សូមលោកជួយបញ្ជាក់អំពីកាលបរិច្ឆេទបានដែរឬទេ ថាតើការវ៉ៃទីតាំងមួយៗហ្នឹង ចាប់ពីពេលណា ដល់ពេលណា? ហើយវ៉ៃហ្នឹង ក្នុងនាមចលនាអ្វីដែរបាទ?

**ឆ៖** បាទ តាមមើលទៅ ដូចចាំមិនអស់ ក្នុងចន្លោះនេះ។ វាច្រើនកន្លែងពេក បាទ។

**ស៖** អរគុណ។ នៅពេលប្រយុទ្ធគ្នានៅក្នុងកងយោធារបស់របប លន់ នល់ លោកធ្លាប់ឃើញមានយោធារបប លន់ នល់ មានរងរបួស ឬក៏ស្លាប់ ឬក៏ត្រូវបានចាប់ខ្លួន ហើយបើសិនជាមានការចាប់ខ្លួនយោធានៃរបប លន់ នល់ តើមានបញ្ហាអ្វីកើតឡើងចំពោះយោធាទាំងអស់នោះដែរឬទេបាទ?

[១១:១៦:៤១]

**ឆ៖** បាទ នៅក្នុងពេលប្រយុទ្ធសមរភូមិ វាត្រូវការការបាញ់ និងបោក។ ពេលប្រយុទ្ធនៅក្នុងពេលនេះ គឺវាអត់អធ្យាស្រ័យគ្នាបានទេ បាទ ក្នុងពេលវ៉ៃប្រហារគ្នានេះ។ ដោយឡែក តែបញ្ចប់នៃសមរភូមិមួយៗ ការចាប់គ្នារវាងម្ខាង ទៅម្ខាងហ្នឹង ជាឈ្លើយសឹកហ្នឹង វាត្រូវតែមានការបញ្ជូនបន្តៗទៅកន្លែងផ្សេងៗហើយ អត់មានទុកនៅកន្លែងហ្នឹងទេ បាទ កន្លងទៅ។ ឯការវ៉ៃតប់ឈ្លើយសឹក អានេះខ្ញុំបាទ មិនសូវដឹងទេ បាទ តែបញ្ចប់សមរភូមិ អាហ្នឹងស្រេចតែពីខាងលើគេដោះស្រាយយ៉ាងម៉េច អាហ្នឹងតាមការដាក់ស្តែងរបស់គេ។

**ស៖** បាទ សូមអរគុណ។ ទាក់ទិននឹងបញ្ហានៃការរំដោះទីក្រុងឧដុង្គ នៅក្នុងខែមីនា ឆ្នាំ១៩៧៤ តើកងពលរបស់លោកត្រូវបានបញ្ជូនទៅចូលរួមប្រយុទ្ធដើម្បីរំដោះទីក្រុងឧដុង្គ នៅក្នុងខែមីនា ឆ្នាំ១៩៧៤ ដែរឬទេបាទ?

**ឆ៖** ការរំដោះឧដុង្គនេះ ខាងកងពលរបស់ខ្ញុំបាទ មិនទាន់បានមកដល់ទេ បាទ។ អត់បានមកដល់ទេ មកអត់ទាន់កម្លាំងកាលហ្នឹង។

**ស៖** អរគុណ។ តើកម្លាំងរបស់លោកនៅពេលនោះឈរជើងនៅទីតាំងណា?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

[១១:១៨:៣១]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ!

**លោក នោម សែ៖**

**ឆ៖** បាទ នៅតាមផ្លូវលេខ៣៨ កំពង់ទួល កន្ទួតនេះ មួយជួរនេះ វត្តហា បាទ ខ្សែខាងត្បូងនេះ។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** អរគុណ។ តើនៅពេលនោះ លោកបានដឹងព័ត៌មានអ្វីខ្លះអំពីចលនានៃការរំដោះទីក្រុងឧដុង្គដែរឬទេ? ហើយបើសិនជាលោកដឹង តើដឹងមកពីប្រភពណា? អ្នកណាជាអ្នកនិយាយប្រាប់លោក?

**ឆ៖** បាទ ការរំដោះឧដុង្គនេះ ខ្ញុំបាទមកអត់ទាន់ទេ អត់ដឹងសូវសាច់រឿងហ្នឹងទេ ខាងឧដុង្គ។ ដឹងតែងក្រោយទេ ក្រោយខាងប្រសិទ្ធិ៍ អដ្ឋវស្សនេះ។

**ស៖** អរគុណ។ តើលោកអាចជម្រាបជូនអង្គសវនាការបានដែរឬទេ ថាលោកអាចដឹងថាអ្នកណាដែលត្រូវបានបក្ស ឬក៏កងទ័ពបដិវត្តន៍ចាត់តាំងឲ្យបុគ្គលណាជាអ្នកឲ្យទទួលខុសត្រូវនៅក្នុងការរៀបចំផែនការប្រយុទ្ធ សម្របសម្រួល ដើម្បីរំដោះទីក្រុងឧដុង្គនៅក្នុងអំឡុងពេលនោះដែរឬទេ ប្រសិនបើលោកអាចដឹង លោកអាចឆ្លើយ? ប្រសិនជាលោកមិនដឹងទេ ក៏មិនមានបញ្ហាដែរបាទ អរគុណ។

[១១:១៩:៥៨]

**ឆ៖** ខ្ញុំបាទ សភាពការណ៍សមរភូមិធំអ៊ីចេះ ខ្ញុំបាទមិនបានដឹងទេ ពីព្រោះក្នុងឋានៈវានៅទាបនៅឡើយ។ មិនទាន់បានស៊ីជម្រៅក្នុងកិច្ចការងារសមរភូមិរំដោះប្រទេសនេះទេ។

**ស៖** អរគុណ។ ក្រោយពេលដែលមានការរំដោះទីក្រុងឧដុង្គរួចហើយ។ តើលោកអាច ឬក៏លោកធ្លាប់បានទទួលព័ត៌មានអ្វីខ្លះពីមជ្ឈដ្ឋានផ្សេងៗ ទាក់ទិននឹងការរំដោះទីក្រុងឧដុង្គ ឬក៏ស្ថានភាពប្រជាជនក្រោយពេលរំដោះនៅក្នុងទីក្រុងឧដុង្គដែរឬទេ?

**ឆ៖** បាទ សភាពការណ៍ហ្នឹង ខ្ញុំបាទអត់បានដឹងទេ។

**ស៖** អរគុណ។ សំណួរមួយទៀតទាក់ទងនឹងបញ្ហានៃការរំដោះទីក្រុងឧដុង្គដែរ។ ក្រោយមកតើលោកបានដឹងអំពីការជម្លៀសប្រជាជនចេញពីទីក្រុងឧដុង្គដែរឬទេ?

[១១:២១:០៧]

**ឆ៖** បាទ អត់បានដឹងដែរសាច់រឿងនេះ។

**ស៖** អរគុណ។ នៅក្រៅពីទីក្រុងឧដុង្គ នៅមុនខែមេសា ឆ្នាំ១៩៧៥ តើលោកធ្លាប់បានដឹងដែរឬទេថា មានទីក្រុងផ្សេងទៀតត្រូវបានរំដោះដោយកងទ័ពបដិវត្តន៍ដែរឬទេ?

**ឆ៖** បាទ ចាំមិនអស់ ក្នុងខែមេសានេះ ខ្ញុំបាទចាំមិនអស់។ មិនដឹងសាច់រឿង កិច្ចការងារទូទាំងអត់បានដឹងទេ។

**ស៖** អរគុណ។ តើលោកអាចបញ្ជាក់អំពី ឬក៏ការចងចាំរបស់លោកអាចចងចាំបានដែរឬទេ ឬក៏លោកអាចដឹងអំពីទិដ្ឋភាពដែលបានកើតឡើងនៅក្នុងខេត្តក្រចេះ ខេត្តកំពង់ចាម និងខេត្តកំពង់ស្ពឺនៅមុនខែមេសា ឆ្នាំ១៩៧៥ដែរឬទេ?

**ឆ៖** បាទ សភាពការណ៍តាមទីរួមខេត្តប៉ុន្មានគាត់បានលើកនេះ ខ្ញុំបាទមិនសូវបានដឹងទេសាច់រឿងនេះបាទ។

[១១:២២:៣០]

**ស៖** អរគុណ។ ទាក់ទិននឹងតំបន់ ឬក៏ខេត្តផ្សេងៗទៀតនៅទូទាំងប្រទេស ក្រោយមកតើលោកធ្លាប់បានឮគេនិយាយប្រាប់ថា មានការរំដោះទីក្រុង ឬក៏ខេត្តណាដោយកងទ័ពបដិវត្តន៍ដែរឬទេ?

**ឆ៖** បាទ ឮដែរ មិនមែនថាអត់ទេ ខាងខេត្តតាកែវ ខេត្តកំពង់ស្ពឺ ប៉ែកខាងត្បូងនេះបានដឹងខ្លះដែរ ប៉ុន្តែកំណត់ខែថ្ងៃអី វាអត់បានដឹងទេបាទ។

**ស៖** អរគុណ។ សូមលោកមេត្តាជួយបញ្ជាក់អំពីទិដ្ឋភាព ឬក៏ព័ត៌មានដែលលោកបានដឹងអំពីខេត្តតាកែវ និងខេត្តកំពង់ស្ពឺ ដែលលោកបានបញ្ជាក់ជូនអង្គសវនាការនៅពេលនេះ អម្បាញ់មិញនេះអំពីទិដ្ឋភាពនៃការរំដោះទីក្រុងនោះដោយកងទ័ពបដិវត្តន៍។ សូមលោកមេត្តាជួយបញ្ជាក់អំពីចំណុចនេះបន្តិចបាទ សូមអរគុណ?

**ឆ៖** បាទ ក្រោយទីតាំងដែលគេវ៉ៃចូលក្នុងទីរួមខេត្តមួយៗ គេច្រើនតែជម្លៀសបាទ ជម្លៀសឲ្យចេញក្នុងមួយរយៈកាល។ បាទ ខ្ញុំឃើញតែសភាពការណ៍គេធ្វើអ៊ីចឹងបាទ ក្នុងចលនាការណែនាំ មិនទុកឲ្យប្រជាជនមាននៅកាន់កាប់នៅក្នុងតំបន់ប្រជុំជននេះនៅក្នុងរយៈកាល នៅពេលដែលវ៉ៃរំដោះថ្មីៗនេះភ្លាមទេ គឺខ្លាចមានអសន្តិសុខនឹងកើតឡើងបន្តទៅទៀត។ បាទ ដឹងតែសាច់រឿងប៉ុណ្ណឹងទេ។

[១១:២៣:៥៧]

**ស៖** អរគុណ។ អម្បាញ់មិញលោកបានបញ្ជាក់ថា ការជម្លៀសប្រជាជនចេញ ដោយមានការ

ព្រួយបារម្ភអំពីបញ្ហាសន្តិសុខ។ សូមលោកជួយបញ្ជាក់ក្នុងន័យសន្តិសុខ តើការព្រួយបារម្ភសន្តិសុខនេះក្នុងន័យយ៉ាងដូចម្ដេច? មានន័យយ៉ាងដូចម្ដេច?

**ឆ៖** ការអសន្តិសុខនេះ ពីព្រោះទីប្រជុំជនមួយៗ វាអារឿងអារុធៗ វាមិនងាយអស់ទេក្នុងការដែលពេលដែលយើងវ៉ៃសម្រុកទៅ ហើយយើងរំដោះទៅ វានៅកប់ នៅមានសេសសល់ ហើយមនុស្សក៏វានៅរបាត់របាយនៅមានការប្រយុទ្ធប្រកួតគ្នា នៅក្នុងពេលហ្នឹងទៀត វាអាចប្រឡូកប៉ោកប៉ាក់នៅក្នុងនោះ គឺអាចធ្វើឲ្យគ្រោះថ្នាក់ដល់អ្នកស្រុក។ គេត្រូវឲ្យតែដកចេញ បទបញ្ជាត្រូវតែឲ្យដកចេញតែម្តងក្នុងកាលៈទេសៈដែលពេលវ៉ៃហើយ ដើម្បីស្ពានភាពឈរជើងគ្រប់គ្រងក្នុងរយៈកាលខ្លី។ វាខ្លាចសភាពការណ៍ វាផ្ទុះឡើងវិញ។ អ៊ីចឹងកន្លងទៅបាទ។

**ស៖** អរគុណ។ ក្រៅពីមូលហេតុនៃការបារម្ភផ្នែកសន្តិសុខ តើលោកធ្លាប់បានឮគេនិយាយប្រាប់ ឬក៏លោកធ្លាប់ជួបផ្ទាល់ កងទ័ពខ្មែរក្រហមធ្លាប់ប្រាប់ប្រជាជនថាមានមូលហេតុអ្វីផ្សេងទៀត ដែលបង្ខំឲ្យប្រជាជនត្រូវតែជម្លៀសចាកចេញពីទីក្រុង ឬពីតំបន់ទីប្រជុំជនដែរឬទេ? សូមលោកជួយបញ្ជាក់អំពីមូលហេតុផ្សេងទៀតដែលលោកបានដឹងឮ ឬក៏គេនិយាយប្រាប់លោកក្នុងអំឡុងពេលនោះបាទ។

[១១:២៥:៣៥]

**ឆ៖** បាទ រឿងរ៉ាវហ្នឹងគឺវាសុទ្ធតែមានហេតុផលដែរបាទ ប៉ុន្តែពេលវេលានោះខ្ញុំបាទដូចជាវាភ្លេចការចងចាំអស់ហើយ វាយូរលង់មកហើយ វានឹកវាមិនឃើញសាច់រឿងហ្នឹងច្រើន។

**ស៖** អរគុណ។ តើលោកអាចបញ្ជាក់ជូនសវនាការបានដែរឬទេនៅពេលនោះ តើគេជម្លៀសប្រជាជនចេញពីទីក្រុងទៅតំបន់ណា? ទៅគោលដៅណាដែរ?

**ឆ៖** ការជម្លៀសប្រជាជនចេញវា ទិសដៅស្រេចតែគេទេ ដូចវ៉ៃរំដោះទីក្រុងភ្នំពេញ។ ម្តងគេឲ្យទៅកើត ម្តងគេឲ្យទៅលិច ម្តងគេឲ្យទៅជើង ទៅត្បូង តាមតែបទបញ្ជា ខ្ញុំបាទមិនសូវដឹងរឿងរាក់ជ្រៅអីប៉ុន្មាន មានតែក្នុងឋានៈការពារនៅទល់មុខទេបាទ ផ្នែកខាងកងទ័ព។

**ស៖** អរគុណ។ នៅពេលដែលមានបទបញ្ជាតម្រូវឲ្យប្រជាជនចាកចេញពីទីក្រុង ឬពីផ្ទះសម្បែងរបស់ខ្លួន តើនៅពេលនោះប្រជាជនអាចមានសិទ្ធិក្នុងការជំទាស់តវ៉ា សូមមិនចាកចេញពីលំនៅដ្ឋានរបស់ខ្លួន ឬក៏ពីភូមិកំណើតរបស់ខ្លួនបានដែរឬទេ? បើមានហេតុអ្វី? បើមិនបានមានមូលហេតុអ្វីបាទ? សូមៗមេត្តាឆ្លើយបាទ។

[១១:២៧:០៩]

**ឆៈ** បាទ មាន។ ហេតុផលគឺមានការដែលប្រជាជនគាត់លើកឡើង គឺរឿងផ្ទះសម្បែង ទ្រព្យសម្បត្តិ គាត់នៅអាឡោះអាល័យ គាត់មិនចង់ចេញទេ បាទមាន អាហ្នឹងមានច្រើន។ ប៉ុន្តែបទបញ្ជារបស់មេបញ្ជាការគឺត្រូវតែចេញ ឱ្យត្រូវតែចេញ។ មានតែមតិណែនាំតែប៉ុណ្ណឹងទេ។ តែរឿងធ្វើសកម្មភាពរកបាញ់ រកវ៉ៃ រកគប់ រកអីគាត់ មិនមានសកម្មភាពហ្នឹងធ្វើទេ គ្រាន់តែនិយាយគាត់ឱ្យឃើញហេតុផលត្រូវតែទៅៗ វាស្ងប់ជាងបញ្ហា។ ឯខាតបង់ពេលវេលា អាហ្នឹង ឬទ្រព្យសម្បត្តិអីផ្សេងៗ អាហ្នឹង ខ្ញុំបាទមិនសូវដឹងទេ ព្រោះបទបញ្ជាគេបញ្ជាមក គឺត្រូវតែធ្វើអ៊ីចឹងតែម្តង បាទ។

**សៈ** បាទ អរគុណ។ នៅពេលដែលមានការតវ៉ាពីប្រជាជនមិនព្រមចាកចេញ ហើយប្រឈមមុខដាក់គ្នារវាងកងទ័ពខ្មែរក្រហម ដែលឱ្យប្រជាជនចាកចេញនៅពេលនោះ។ តើមានរឿងអ្វីកើតឡើងចំពោះប្រជាជនណាដែលមិនព្រមចាកចេញ ឬក៏ជំទាស់នឹងបទបញ្ជារបស់កងទ័ពបដិវត្តន៍នៅពេលនោះបាទ?

[១១:២៨:២៥]

**ឆៈ** បាទ តាមការជាក់ស្តែងចំពោះមុខព្រួញដែលខ្ញុំបាទធ្វើ កន្លងទៅវាដូចអត់មានឃើញបញ្ហាទទឹងរឹងរូស ចចេសវែកញែកអី ហើយទៅជាបាញ់សម្លុតគំរាម ឬក៏ទៅជាធ្វើឃាតកម្មអីផ្សេងៗចំពោះអ្នកស្រុកដូចមិនមានទេ បាទមិនមានប៉ះពាល់ទេ។ ព្រោះកងទ័ពរំដោះនេះគេត្រូវមានគុណធម៌ ត្រូវមានសីលធម៌ដែរ អានេះចំពោះមេដឹកនាំបទបញ្ជា មិនឱ្យធ្វើឃោរឃៅចំពោះអ្នកស្រុកទេ។ បើអ៊ីចឹងវាគ្មានលទ្ធភាពរំដោះប្រជាជន រំដោះប្រទេសអីបានទេ។ បាទ វិន័យរបស់យោធាគឺអ៊ីចឹងតែម្តងកន្លងទៅ។

**សៈ** បាទ អរគុណ។ នៅពេលដែលបង្ខំឱ្យប្រជាជនចាកចេញ ប្រាប់ប្រជាជនឱ្យចាកចេញជាបទបញ្ជាពីថ្នាក់លើ តើកងទ័ពខ្មែរក្រហមបានណែនាំឱ្យប្រជាជនត្រូវយកអ្វីខ្លះជាប់ទៅជាមួយខ្លួនដែរឬទេ? ឬក៏បានហាមឃាត់មិនឱ្យប្រជាជនយកអ្វីខ្លះទៅតាមខ្លួនដែរឬទេ នៅពេលនោះបាទ?

**ឆៈ** បាទ ការហាមឃាត់ វាមិនហាមឃាត់ទេ ធ្វើម៉េចឱ្យយករួច ប៉ុន្តែយកវាមិនរួច មួយកម្លាំងទល់ខ្លួន ខ្លួនមួយទល់នឹងខ្លួន គ្នាអត់មានអីយកទេអាហ្នឹង យកបានមួយសំពាយតូចៗ។ បាទ តែអត់មានការបង្ខំអីទេ តាមលទ្ធភាពរបស់គាត់តែប៉ុណ្ណឹងឯង។

**សៈ** អរគុណ។ សំណួរមួយទៀតទាក់ទងនឹងការជម្លៀសដែរ ខ្ញុំសូមអនុញ្ញាតសួរលោកថា តើកងទ័ពខ្មែរក្រហមបានប្រើប្រាស់មធ្យោបាយក្នុងការដឹកជញ្ជូនប្រជាជនចាកចេញពីទីក្រុង ឬក៏ទីប្រជុំជនដោយប្រើមធ្យោបាយអ្វីខ្លះ? តើមានដែរឬទេ? តើមានមធ្យោបាយដើម្បីដឹកប្រជាជនចាកចេញដែរឬទេ?

**ឆ៖** បាទ គឺអត់មានមធ្យោបាយទេ បាទ ឲ្យឃើញគាត់ធ្វើដំណើរតាមដំណើរដែលខ្លួនគាត់ហ្នឹងតែម្តងបាទ។ អត់មានរថយន្ត អត់មានស្អីផ្សេងៗទេ បានជូនដំណើរទេកន្លងទៅ គាត់ធ្វើដំណើរតាមដំណើរថ្មើរជើង ដំណើរស្អីផ្សេងៗ អាវឿងសម្ភារៈបើកបរអីផ្សេងៗគាត់អត់មានសិទ្ធិ។ បាទ កន្លងទៅគឺឃើញអ៊ីចឹង។

[១១:៣១:១៨]

**ស៖** បាទ អរគុណ។ ទាក់ទងនឹងការសង្កេតរបស់លោកផ្ទាល់នៅមុនខែមេសា ឆ្នាំ១៩៧៥ តើលោកអាចដឹងទេថា កងទ័ពបដិវត្តន៍បានចាត់ទុកប្រជាជននៅទីក្រុងជាមនុស្សប្រភេទអ្វីចំពោះកងទ័ពបដិវត្តន៍? ចាត់ទុកជាសត្រូវធម្មតា ឬក៏ចាត់ទុកជាប្រភេទមនុស្សយ៉ាងដូចម្តេច?

**ឆ៖** ទេ តាមដែលខ្ញុំយល់ជាអារម្មណ៍ ជាទស្សនៈ ហើយជាការប្រព្រឹត្តរបស់យើងខ្ញុំផ្ទាល់នេះ ព្រោះប្រជាជនមិនថាតំបន់ក្នុង តំបន់ក្រៅទេ សុទ្ធតែប្រជាជន និងពលរដ្ឋរបស់ខ្លួនពិតប្រាកដ។ បាទ មិនមានការហួងហែង មិនមានការចោទថាប្រជាជននៅក្នុងតំបន់ដែលសត្រូវកាន់កាប់នោះទៅជាសត្រូវដែរទេ អត់មានទេ។ បាទ ទិសដៅ គឺមានតែបង្រួបបង្រួមជាតិ ប៉ុន្តែត្រង់ថាកិច្ចការ លើកិច្ចការងារមូលដ្ឋានផ្សេងៗដែលគេអនុវត្តនោះមិនដឹងជាបែបផែនយ៉ាងម៉េច ខ្ញុំបាទក៏មិនសូវដឹងដែរសាច់រឿងនេះ។ បាទ ដែលពេលប្រជាជនទៅដល់ក្នុងតំបន់នេះ ឬក៏ស្រុកនេះ ស្រុកនោះ ឬក៏ឈានទៅស្រុកកំណើតមិនដឹងជាគេអនុវត្តយ៉ាងម៉េច ខ្ញុំបាទក៏មិនដឹងដែរ។ បាទ បើខ្ញុំនៅខ្សែជួរខាងកងទ័ព វានៅខាងមុខមិនសូវសាច់ដឹងរឿងទេ។ បាទ នេះតាមសភាពជាក់ស្តែងរបស់ខ្លួន។

**ស៖** បាទ អរគុណ។ នៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំសូមឲ្យលោកជួយបញ្ជាក់ជូនអង្គសវនាការនៅពេលនេះឲ្យបានជ្រាប អំពីខ្សែសង្វាក់បញ្ជាដែលបានកើតមាននៅក្នុងជួរកងទ័ពបដិវត្តន៍កម្ពុជា។ សូមលោកជួយបញ្ជាក់អំពីចំណុចនេះបាទ។

[១១:៣៣:២៣]

**ឆ៖** បាទ សូមម្តងទៀត ស្តាប់មិនសូវយល់បញ្ហាហ្នឹង។

**ស៖** បាទ អរគុណ។ ខ្ញុំចង់ឲ្យលោកជួយបញ្ជាក់ជូនអង្គសវនាការឲ្យបានជ្រាបអំពីខ្សែសង្វាក់បញ្ជាដែលកើតមាននៅក្នុងកងទ័ពបដិវត្តន៍កម្ពុជានៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥បាទ?

**ឆ៖** បាទ ខ្សែបណ្តាញនៃការបញ្ជា ខ្ញុំបាទក៏មិនបានរៀបរាប់ ហើយនិងយល់អីឲ្យស៊ីជម្រៅប៉ុន្មានដែរទេ ព្រោះដំណាក់កាលពេលនោះ។ ជាបែបផែនរបស់ផ្សេងៗ ខ្ញុំដឹងតែទទួលបញ្ជាតែពីមេបញ្ជា

ការផ្ទាល់ខ្លួនតែម្តងបាទ។ ក្នុងកងពលទទួលបញ្ជាឲ្យធ្វើអីៗ ធ្វើតាមគាត់ទៅ បែបបទតែប៉ុណ្ណឹងទេ។ ឯកងពលផ្សេងៗ ខ្ញុំបាទមិនសូវបានដឹងរឿងជម្រៅផ្សេងៗទេ គ្រប់កិច្ចការងារ។

**ស៖** អរគុណ។ តើមេដឹកនាំខ្មែរក្រហម ឬក៏ថ្នាក់លើរបស់លោកដាក់បទបញ្ជាមកកងពលរបស់លោក ដើម្បីអនុវត្តតាមបទបញ្ជានោះ។ តើការបញ្ជូនបទបញ្ជានេះ ថ្នាក់លើបានប្រើមធ្យោបាយបែបណាខ្លះ? ហើយការដាក់បញ្ជានេះគឺប្រើប្រាស់តាមរយៈមនុស្សប្រភេទណាខ្លះ ទើបបទបញ្ជានោះមកដល់កងពលរបស់លោក ដើម្បីអនុវត្តតាមបាទ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ!

**លោក នោម សែ៖**

**ឆ៖** បាទ ខ្ញុំបាទច្រើនតែទទួលពីបញ្ជាពីកងពល ជូនកាលមានខាងគេអូ ប្រើបញ្ជាគេអូ។ ជូនកាលប្រើជានីរសារ រត់ជូនព័ត៌មានផ្សេងៗ បាទ បណ្តាញទាក់ទងគ្នាពីកន្លែងមួយទៅកន្លែងណាបាទ។

**សួរដោយលោក ច័ន្ទ តារាស្រី៖**

**ស៖** បាទ អរគុណ។ នៅក្នុងពេលប្រយុទ្ធគ្នាក្នុងសមរភូមិ តើកងពលរបស់លោក ឬក៏លោកផ្ទាល់ទាក់ទងទៅថ្នាក់លើ ឬក៏ទាក់ទងទៅផ្នែកក្នុងកងពលរបស់លោក ដោយប្រើប្រាស់វិទ្យុទាក់ទងបានល្អដែរឬទេ? ការទាក់ទង ដោយប្រើវិទ្យុទាក់ទងគ្នានោះ គឺជាមធ្យោបាយយ៉ាងដូចម្តេចនៅក្នុងកងពលរបស់លោក ជាមួយនឹងថ្នាក់លើ ក៏ដូចជាមួយនឹងសហការីរបស់លោក ក្នុងអំឡុងពេលនៃការប្រយុទ្ធគ្នានៅពេលនោះបាទ?

[១១:៣៦:២៥]

**ឆ៖** បាទ សភាពការណ៍ជូនដំណឹងនៃព័ត៌មានក្នុងពេលប្រយុទ្ធសម័យនោះ មានការយឺតយ៉ាវដែរបាទ ព្រោះគេអូក៏វាតិច វាមិនសូវគ្រប់គ្រាន់ទេ ដោយច្រើនតែនីរសាររត់នាំពាក្យបាទ។ អ៊ីចឹងហើយដែលមានការគ្រោះថ្នាក់របស់មនុស្សអ្នកដែលនាំសារ បាទ ក្នុងការប្រយុទ្ធក្នុងសមរភូមិ។ ជួបការលំបាក ឬក៏ស្មុគស្មាញ ឬក៏ពេលវើលុក វានៅជាប់ដៃគ្នាដ៏តឹងតែង បាទ។ ហ្នឹងវាច្រើនតែការផ្លាស់ប្តូរជីវិតមនុស្សយកផ្តល់ព័ត៌មានជូនទៅផ្ទាល់ៗបាទ។

**ស៖** បាទ អរគុណ។ នៅពេលដែលមានការប្រយុទ្ធគ្នា តើជាញឹកញាប់ ឬក៏ជារឿយៗ លោកតែងតែមានការទាក់ទងគ្នាដែរឬទេ ជាមួយនឹងថ្នាក់លើ ឬក៏បុគ្គលណា ដែលលោកទាក់ទងគ្នាជាញឹក

ញាប់តាមរយៈវិទ្យុទាក់ទង ដែលលោកបានប្រើប្រាស់នៅក្នុងអំឡុងពេលនៃការប្រយុទ្ធគ្នានោះ?

**ឆ៖** បាទ នៅក្នុងសកម្មភាពដែលពេលប្រយុទ្ធ ការទាក់ទងជាមួយខាងលើ គម្រោងការទទួលផែនការបានសព្វគ្រប់ហើយ សំខាន់ក្រុម កង កងតូច កងធំ ត្រូវម្ចាស់ការក្នុងសមរភូមិជាក់ស្តែងនៅពេលប្រយុទ្ធ បាតុភាពអ្វីល្អៗនិងអាចដោះស្រាយបាន មិនសូវពឹងពាក់ពីខាងលើទេ ច្រើនតែដោះស្រាយលើបញ្ហានេះ ទៅតាមក្របខ័ណ្ឌដឹកនាំកម្រិត តាមកម្រិតមេបញ្ជាការ ដើម្បីការពារកម្លាំង និងសម្រេចកិច្ចការងារនៅពេលឧបសគ្គនេះ បាទ ដោះស្រាយ។

[១១:៣៨:១៤]

**ស៖** បាទ អរគុណ។ សូមលោកជួយបញ្ជាក់ជូនអង្គសវនាការ ថាតើនៅពេលដែលរបបភ្នំពេញដួលរលំទៅ តើលោកធ្លាប់បានចូលរួមប្រជុំណាមួយ ឬក៏លោកធ្លាប់បានចូលរួមជាច្រើនដង ជាមួយនឹងមេដឹកនាំខ្មែរក្រហមដែរឬទេ? បើសិនជាមាន តើកិច្ចប្រជុំប្រភេទណា ហើយជាមួយមេដឹកនាំខ្មែរក្រហមឈ្មោះអ្វីដែរបាទ?

**ឆ៖** បាទ ក្រោយរំដោះទីក្រុងភ្នំពេញហើយ ខ្ញុំបាទមានសិទ្ធិបានចូលរួម។ បាទ ដូចខ្ញុំបានធ្វើរបាយការណ៍ហ្នឹងអ៊ីចឹង បានចូលរួមក្នុងអង្គសន្និបាតមួយ ដើម្បីប្រកាសជំហរ ក្នុងក្របខ័ណ្ឌការដឹកនាំរបបទូទាំងប្រទេស ក្នុងថ្នាក់ដឹកនាំ ហើយនិងត្រូវកំណើតខ្លួនរបស់កងទ័ពគ្រប់ប្រភេទ ដែលប្រចាំនៅក្នុងតួនាទីរបស់ប្រទេស បាទ នៅក្នុងស្តាតអូឡាំពិកនេះដែរ។ ព្រោះពេលនោះ គេត្រូវជម្រើសឲ្យចូលរួមទៅមានក្របខ័ណ្ឌតាំងពីអនុសេនាធំទៅ បាទ ទៅចូលរួម ប្រហែលជាចុងឆ្នាំ ក្នុងខែកញ្ញា ឬខែតុលាបាទដែលចូលរួមនេះ ខ្ញុំបាទវាមិនសូវចាំពិតប្រាកដបាទ។ ប៉ុន្តែនោះបានចូលទៅរួម គឺប្រកាសមជ្ឈិមដឹកនាំទូទៅប្រទេស បាទ មានលំអានឈ្មោះជាលំដាប់បន្តៗ ដូចខ្ញុំបាទរាយជូននៅក្នុងរបាយការណ៍នេះអ៊ីចឹងបាទ។ ហើយក្នុងនោះ ក៏ខ្ញុំបាទបានទៅចូលរួមដែរ។

[១១:៤០:១០]

**ស៖** បាទអរគុណ។ ទាក់ទិននឹងការចូលរួមប្រជុំនេះ ខ្ញុំសូមឲ្យលោកជួយឆ្លើយបំភ្លឺឲ្យបានច្បាស់ជូនអង្គសវនាការ ទាក់ទិននឹងព្រឹត្តិការណ៍មុនពេលរំដោះទីក្រុងភ្នំពេញ ថាតើលោកធ្លាប់បានចូលរួមប្រជុំណាមួយ ឬក៏ធ្លាប់បានចូលរួមប្រជុំជាច្រើនដងជាមួយនឹងមេដឹកនាំខ្មែរក្រហមណាខ្លះដែរឬទេ? ចំណុចនេះខ្ញុំចង់ដឹងព្រឹត្តិការណ៍មុនពេលរំដោះទីក្រុងភ្នំពេញ? បាទ សូមអរគុណ។

**ឆ៖** បាទ លើគម្រោងការនេះ ខ្ញុំបាទមិនបានចូលរួមប្រជុំក្នុងផ្នែកការងារធំៗទេបាទ។ បានតែ

ទទួលបទបញ្ជា ឬក៏សិក្សានៅតាមក្នុងអង្គភាពរបស់កងពលតែប៉ុណ្ណោះបាទ។

**ស៖** បាទ ការប្រជុំតូចតាច ឬក៏ការសិក្សាតាមអង្គភាពដែលលោកបានបញ្ជាក់អម្បាញ់មិញ ខ្ញុំសូមឲ្យលោកជួយបញ្ជាក់ថា តើការសិក្សានោះបានផ្តោតទៅលើប្រធានបទអ្វី គេនិយាយអំពីអ្វីជម្រាបជូនលោក ឬក៏ដល់សមាជិកដែលបានចូលរួមនៅក្នុងពេលនោះ?

[១១:៤១:៣៦]

**ឆ៖** បាទ ការសិក្សានោះវាមានឯកសារសំខាន់ៗច្រើនដែរ ប៉ុន្តែខ្ញុំបាទមិនសូវចាំទាំងអស់ទេ។ ឯកសារនោះវាឲ្យយើងយល់អំពីសភាពការណ៍រួម និងសភាពការណ៍ដោយឡែក។ សភាពការណ៍ទល់មុខក្នុងសភាពការណ៍យោធាដែលយើងកំពុងដំណើរការនេះ វាមានដល់កម្រិតណា ហើយនិងការកសាងកម្លាំងចលនាតស៊ូរបស់ឯងនោះ វាមានកម្រិតណា ប៉ាន់ប្រមាណនឹងសភាពការណ៍ វាសព្វបែបសព្វយ៉ាង វាច្រើនដែរក្នុងការសិក្សានេះដើម្បីបំពេញសមត្ថភាពដឹកនាំអង្គភាព និងបើកសមរភូមិប្រយុទ្ធនេះលំដាប់ទៅរំដោះប្រទេសតៗទៅមុខទៀត អ៊ីចឹងបាទ តាមខ្លឹមសារនៃការអប់រំ វាមានលក្ខខណ្ឌច្រើនដែរបាទ។ សិក្សានយោបាយគ្រប់ផ្នែក និងខាងចិត្តសាស្ត្ររវាងមិត្ត និងសត្រូវ។ នេះក៏កាន់តែជ្រាលជ្រៅដែរបាទ។ ឲ្យឃើញច្បាស់លាស់ ហើយដើម្បីយើងបន្តកិច្ចដំណើរការទៅឲ្យវាកាន់តែទទួលយកជ័យជម្នះនេះបាន។

[១១:៤៣:០៣]

**ស៖** បាទអរគុណ។ សូមលោកជួយបញ្ជាក់ថា កាលដែលគេបង្រៀនលោក ឬក៏ក្រុមរបស់លោកឲ្យកសាងចលនាតស៊ូដើម្បីទទួលបានជ័យជម្នះ តើការតស៊ូនេះក្នុងន័យដើម្បីអ្វីទៅជាសំខាន់? សូមលោកជួយបញ្ជាក់ចំណុចនេះបាទ?

**ឆ៖** ទិសដៅ គឺរំដោះទឹក រំដោះដី រំដោះប្រទេស កសាងរបបសង្គមមួយសម្រាប់អនាគតរបស់ប្រទេស ដែលគំនិតអ្នកតស៊ូនេះដែលត្រូវការចង់បាន។ តែត្រង់ធ្វើលទ្ធិអីៗ ខ្ញុំបាទមិនទាន់ដឹងពីមុនទេ -- បាទ ជាមុនទេ ឲ្យដំណើរយ៉ាងម៉េចឲ្យតែបានប្រជាជនរស់នៅឲ្យបានសេចក្តីសុខ ទុក្ខដោះស្រាយគ្រប់បញ្ហា។ ហ្នឹងឯករាជ្យហ្នឹង ក៏វាបញ្ចប់នៃដំណើរការនេះបានបាទ។

**ស៖** អរគុណ។ នៅក្នុងពេលនៃការប្រជុំរៀនសូត្រនោះ តើគេមានបានពន្យល់ប្រាប់លោកអំពីពាក្យថា “កសាងចលនាតស៊ូដើម្បីផ្តួលរលំរបបទីក្រុងភ្នំពេញដែរឬទេ”? គេមានបានប្រើពាក្យនេះដែរឬទេនៅពេលដែលគេបង្រៀន ឬក៏ពន្យល់ណែនាំដល់លោក ឬក៏ក្រុមរបស់លោក?

**ឆ៖** បាទ ប្រើពាក្យនេះបាទ។ រំដោះរំលំហើយ និងរំដោះកសាងដំណើរការដែលលទ្ធិយើងត្រូវការចង់បាន។

[១១:៤៤:៥៩]

**ស៖** អរគុណ។ សូមលោកជួបបញ្ជាក់ តើអ្នកណាជាប្រធាននៃវគ្គសិក្សា ឬក៏វគ្គប្រជុំតូចតាចដែលលោកបានចូលរួមនោះ គាត់ឈ្មោះអ្វីដែរ?

**ឆ៖** បាទ អាហ្នឹងវាច្រើនតែមេបញ្ជាការក្នុងវរសេនាតូច។ វរសេនាតូចនេះគាត់មានការសិក្សាក្នុងមួយខែអ៊ីចឹងទៅ បណ្ដុះបណ្ដាលខាងផ្លូវចិត្ត និងផ្លូវអារម្មណ៍ ផ្លូវខាងទស្សនៈអីផ្សេងៗឲ្យកងទ័ពយល់ពីបញ្ហានេះបាទ កុំឲ្យវាមានអារម្មណ៍ វាលម្អៀងឯលិច លម្អៀងឯកើត ភិតភ័យ ខ្លាច បារម្ភ ព្រួយសព្វបែបសព្វយ៉ាងអ៊ីចឹងទៅ វាកាន់តែប្រកាន់ជំហររឹងប៉ឹង រួមចំណែកធ្វើការតស៊ូតទៅទៀតទៅបាទ។

**ស៖** អរគុណ។ តើលោកអាចបញ្ជាក់បានដែរឬទេ អំពីគំរូផែនការនៃការវាយលុកផ្ដួលរំលំរបបទីក្រុងភ្នំពេញដែលរៀបចំឡើងដោយកងទ័ពបដិវត្តន៍នៅពេលដែលគេពន្យល់លោកនៅក្នុងអង្គប្រជុំនោះបាទ តើគេមានបានបញ្ជាក់អំពីផែនការប្រយុទ្ធដើម្បីរំដោះទីក្រុងភ្នំពេញដែរឬទេ?

**ឆ៖** បាទ មាន។ សុទ្ធតែមានទិសដៅនៃយុទ្ធសាស្ត្របាទ។ យុទ្ធវិធីកំពុងតែអនុវត្ត ឯយុទ្ធ-សាស្ត្រទិសដៅដើម្បីក្រោយរំដោះ វាយរំលំរដ្ឋអំណាចគ្រប់គ្រងនៅក្នុងប្រទេសជំនាន់នេះបាទ។ គឺត្រូវមានគោលការណ៍ មានទិសដៅតទៅមុខទៀតបាទ។

[១១:៤៦:៥៣]

**ស៖** សូមលោកអាចរៀបរាប់ត្រួសៗបានដែរឬទេអំពីយុទ្ធសាស្ត្រ និងយុទ្ធវិធីដែលកងទ័ពខ្មែរក្រហមបានសម្រេចចិត្ត ហើយត្រូវតែធ្វើតាមគម្រោងផែនការយុទ្ធសាស្ត្រ និងយុទ្ធវិធីនោះ ដើម្បីផ្ដួលរំលំរបបទីក្រុងភ្នំពេញបាទ។

**ឆ៖** ខ្ញុំបាទ រំឭកមិនបានទេបាទ វាមានយុទ្ធសាស្ត្រច្រើនពេកបាទ មិនអាចចងចាំបានសព្វគ្រប់ទេ មានទិសដៅ តែអាចមានលទ្ធភាពល្មមអាចនឹងធ្វើកើតតាមទិសហ្នឹងកន្លងទៅ។ ប៉ុន្តែឲ្យការចងចាំអីលំនាំ គោលការណ៍អីផ្សេងៗ ដូចជាការភ្លេចភ្លាំងច្រើន។

**ស៖** បាទ អរគុណ។ សូមលោកជួយបង្ហាញ បើសិនជាលោកចងចាំ។ តើអ្នកដែលចូលរួមជាមេដឹកនាំអង្គប្រជុំ ឬក៏មេវគ្គសិក្សារៀនសូត្ររបស់លោក ឬក្រុមលោកដែលលោកបានចូលរួមនោះ គាត់ឈ្មោះអ្វី? ហើយគាត់មានតួនាទីជាអ្វីនៅក្នុងអំឡុងពេលនោះ?

**ឆ៖** ឈ្មោះហ្នឹងដូចជាច្រើនពេកហើយ មេៗបន្តៗគ្នាមកហ្នឹងវាចាំវាមិនអស់មេ។ មេផ្លាស់ប្តូរ វរសេនាតូច វរសេនាធំហ្នឹងក៏វាចេះតែបែកគ្នាបាត់ទៅ ចាំបាត់ ចាំមិនអស់ទេឈ្មោះ។

[១១:៤៨:៣៧]

**ស៖** អរគុណ។ នៅមុនខែមេសា ឆ្នាំ១៩៧៥ តើលោកធ្លាប់បានជួបមេដឹកនាំក្រហមជាន់ខ្ពស់ដែរឬទេ ដូចជាលោក អៀង សារី, លោក ខៀវ សំផន, លោក នួន ជា ឬក៏អ្នកណាផ្សេងទៀតដែលលោកអាចជួប ឬក៏លោកមិនដែលបានជួបបាទ? ប្រសិនបើលោកអាចបញ្ជាក់បាន សូមមេត្តាបញ្ជាក់បាទ។

**ឆ៖** បាទ ជួបនេះក៏ជួបគាត់បានពីចម្ងាយ មិនស្គាល់ច្បាស់បាទ។ ដឹងឈ្មោះ ដឹងត្រកូល ប៉ុន្តែគ្រាន់តែមើលសម្រាប់ផ្ទាល់ខ្លួនទេ មិនបានជិតស្និទ្ធ ហើយនិងដឹងពិតប្រាកដ ដូចថា លោក ខៀវ សំផន អីចឹងទៅ លោក នួន ជា អីចឹងទៅ មើលពីចម្ងាយឃើញដឹង ភិនភាគរូបគាត់ ប៉ុន្តែឲ្យជិតដល់ជិតស្និទ្ធរវាងគាត់ហើយនិងខ្ញុំ មើលមិនស្គាល់គ្នាទេ មិនដែលស្គាល់គ្នាទេបាទ។ ព្រោះន៎ៃ ខ្ញុំបាទវានៅក្នុងការដឹកនាំវាកម្រិតទាប វាមិនអាចចូលទៅ និងកៀក និងជិត ហើយសន្ទនាបានទេបាទ ហ្នឹងបើនិយាយពីតួនាទីវិញ។

[១១:៥០:០០]

**ស៖** អរគុណ។ តើមេដឹកនាំដែលលោកបានឮឈ្មោះ ខ្ញុំគ្រាន់តែចង់ដឹងថាលោកបានឮឈ្មោះ ឬក៏លោកឮគេប្រាប់លោកនៅក្នុងអំឡុងពេលនៃការតស៊ូធ្វើបដិវត្តន៍នោះ តើមេដឹកនាំជាន់ខ្ពស់នោះមានឈ្មោះអ្វីខ្លះដែលលោកបានដឹងឮ? ឬក៏លោកបានឃើញពីចម្ងាយដែលលោកបានបញ្ជាក់អំមិញនេះ? សូមលោកជួយរៀបរាប់ឈ្មោះ បើសិនជាលោកចង់ចាំបាទ។

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

កុំអាល់ទាន់ឆ្លើយ! រង់ចាំ។

**លោក នោម សែ៖**

**ឆ៖** បាទ ដឹកនាំនោះ ពេលដែលខ្ញុំបានជម្រាបជូន ថាបានមកសន្និបាតនៅស្តាតអូឡាំពិកនេះ ឃើញទៅវាក្នុងការដឹកនាំប្រទេសវាមាន២១រូប របស់មជ្ឈិមបក្សនោះ។ បាទ តែឈ្មោះដែលចាំៗហ្នឹង វាចាំឈ្មោះច្រើនដែរ ប៉ុន្តែមុខឲ្យស្គាល់ច្បាស់ហ្នឹង វាមិនច្បាស់អស់ទេ ច្បាស់ខ្លះ។ ទី១ ដូចជា ប៉ុល ពត,

ទី២ នួន ជា, ទី៣ ឈិត ជឿន អ៊ីចឹង ដែលវាកៀកជាងគេហ្នឹង ឈិត ជឿន ហ្នឹងដែលបាននៅផ្ទាល់វាជិត ហៅ តាម៉ុក នោះ។ ហ្នឹងដូចរាងប្រទាក់ស្គាល់ចុះស្គាល់ឡើងដែរ ហើយក្រៅពីហ្នឹងបន្តៗមកសុទ្ធតែអស់លោកនៅតាមភូមិភាគផ្សេង។ ប៉ុន្តែត្រកូលហ្នឹង ក៏ខ្ញុំបាទហៅវាមិនចំអស់ដែរ កុយ ធួន អី, លោក ធុច អី, លោក យ៉ា លោកអីគេ ហើយនិង សុន សេន នេះ, អៀង សារី, លោក ខៀវ សំផន, អៀង ធីរិទ្ធ, មាន រស់ ញឹម អ៊ីចឹងទៅ, កង ចាប នោះទៅ, វន វ៉េត អ៊ីចឹងទៅ, ជ័យ សួន នោះបាទ, ចេង អន ហ្នឹងហើយសុទ្ធតែថ្នាក់ដឹកនាំធំៗ។ រាប់ទៅវាទាល់គ្នា២១រូបដែរ។

[១១:៥២:២៧]

**សួរដោយលោក ច័ន្ទ តារាវស្នី៖**

**ស៖** បាទ អរគុណ។ ដោយសារពេលវេលាមានកម្រិត ខ្ញុំសូមឆ្លងចូលប្រធានបទចុងក្រោយរបស់ខ្ញុំ គឺប្រធានទី៣ ទាក់ទងនឹងការរំដោះទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ នៅក្នុងឯកសារនៃការស្តាប់ចម្លើយរបស់លោក លោកបានឆ្លើយថា "លោកស្គាល់អ្នកស្រីឈ្មោះ វ៉ាន់"។ តើលោកស្រីឈ្មោះ វ៉ាន់ ហ្នឹងគាត់គឺជាអ្វី? មានមុខតំណែងជាអ្វី? ហើយទទួលខុសត្រូវអ្វីនៅក្នុងអំឡុងពេលនៃធ្វើកិច្ចការជាមួយលោកក្នុងអំឡុងនោះបាទ សម័យមុនខែមេសា ឆ្នាំ៧៥នោះ? ហើយក្រោយមកគាត់ធ្វើអ្វីខ្លះបាទ?

**ឆ៖** បាទ តាមខ្ញុំបាទស្គាល់ហ្នឹងវា វ៉ាន់ ហ្នឹងដែលគាត់សួរ វ៉ាន់ ហ្នឹង វ៉ាន់ (ប្រុស) ប៉ុន្តែខ្ញុំបាទស្គាល់តែ វ៉ាន់ (ស្រី)។ វ៉ាន់ (ស្រី) ហ្នឹងមេបញ្ជាការវរសេនាតូច២៩ ប៉ែកខាងលិច មេទ័ពស្រីបាទ។ ខ្ញុំបាទស្គាល់ ប៉ុន្តែសព្វថ្ងៃគាត់រស់នៅរតនគិរីនោះ មិនដឹងជារស់ឬស្លាប់ដែរ។

[១១:៥៣:៤៣]

**ស៖** អរគុណ។ នៅពេលដែលវៃរំដោះទីក្រុងភ្នំពេញ តើលោកជាមួយនឹងស្ត្រីរូបនេះ ឈ្មោះ វ៉ាន់ ហ្នឹង តើការវៃចូលទីក្រុងភ្នំពេញហ្នឹង គឺបានធ្វើកិច្ចការអ្វីខ្លះជាមួយគ្នា? ហើយចូលទីក្រុងភ្នំពេញហ្នឹងគឺចូលតាមច្រកណា? ហើយបានធ្វើសកម្មភាពអ្វីខ្លះបាទ?

**ឆ៖** បាទ ពេលដែលវៃចូលក្រុងភ្នំពេញនេះ អង្គភាពហ្នឹងវានៅស្ថិតនៅជាមួយគ្នាបាទ។ កងទ័ពប្រុសកងទ័ពស្រីហ្នឹងវាជាប់គ្នា។ ចូលមកណេះព្រលានពោធិ៍ចិនតុង ផ្សារពោធិ៍ចិនតុងនេះ ហើយរហូតទៅដល់ទាល់គ្នានឹងក្រសួងឃោសនាការហ្នឹង។ បាទ អង្គភាពហ្នឹងមានទិសមកប៉ុណ្ណឹងបាទ។

**ស៖** អរគុណ។ នៅពេលដែលលោករើចូលទីក្រុងភ្នំពេញ តើលោកឃើញទិដ្ឋភាពយ៉ាងដូចម្ដេច នៅទីក្រុងភ្នំពេញ និងចំពោះទីតាំងទាំងឡាយដែលលោកបានទៅដល់ បានឃើញនៅពេលដែលលោកចល័តទ័ពចូលទៅក្នុងទីក្រុងភ្នំពេញ ដើម្បីរំដោះទីក្រុងភ្នំពេញនោះបាទ?

[១១:៥៥:០២]

**ឆ៖** សភាពការណ៍វាតានតឹងដែរ ព្រោះទីក្រុងវាមនុស្សណែនណាន់តាន់តាប់ដែរ ហើយទាហានគ្រប់តែកន្លែង។ បាទ វាមានការច្របូកច្របល់ដែរហ្នឹង តែខ្ញុំបាទមិនសូវបានចូលនៅយូរទេក្នុងទីក្រុងភ្នំពេញនោះ។ វាត្រូវបទបញ្ជាគេឲ្យបញ្ជាយកឡានទៅដឹកកម្លាំងនៅខាងក្រោយចេញទៅពីក្រៅមក យកមកក្នុងវិញ។ បាទ ទៅជញ្ជូនកម្លាំង។ ហើយនិងឲ្យប្រជាជនចេញក្នុងរយៈកាលប៉ុន្មានថ្ងៃៗហ្នឹងបាទ។ ហើយគេបទបញ្ជាហើយក៏យកអង្គភាពហ្នឹងចេញក្រៅវិញ អត់ឲ្យមាននៅក្នុងក្រុងហ្នឹងទេ។ បាទ មកខាងឃ្លួញ ខាងបាយ៉ាបនេះ។

[១១:៥៥:៤៥]

**ស៖** អរគុណ។ តើនៅពេលដែលរំដោះទីក្រុងភ្នំពេញនុ៎ង កងទ័ពប្រើពេលរយៈពេលប៉ុន្មានទើបរំដោះទីក្រុងភ្នំពេញបាន?

**ឆ៖** បាទ ពេលវេលាយូរដែរ ប្រហែលប៉ុន្មានជា ៣ខែដែរ។ បាទ តាំងពីកប់ស្រូវតូច កប់ស្រូវធំមកទម្រាំតែនឹងចូលចុះមក មកតាមមួយដំណាក់ៗ វាមានសភាពការណ៍តឹងតែងដែរបាទ។

**ស៖** អរគុណ។ ខ្ញុំសូមឲ្យលោកឆ្លើយសំណួរបន្តទៀត។ នៅពេលដែលកងទ័ពបដិវត្តន៍ចូលមកដល់រំដោះទីក្រុងភ្នំពេញបានហើយ តើយោធាខ្មែរក្រហម (សូមទោស) យោធានៃរបប លន់ នល់ត្រូវបានយោធាខ្មែរក្រហមសម្លាប់ ឬក៏ចាប់ខ្លួន។ តើនៅពេលនោះគឺមានវិធានការអ្វីខ្លះកើតឡើងចំពោះយោធាដែលនៅរស់ ហើយមិនព្រមសារភាពថាខ្លួនជាអតីតយោធានៃរបបលន់ នល់? ហើយប្រសិនបើគាត់សារ --ក្លែងខ្លួនធ្វើជាជនស៊ីវិល ក្រោយមកគេរកឃើញថាគាត់ជាអតីតយោធាក្នុងរបបលន់ នល់ តើមានរឿងអ្វីកើតឡើងចំពោះបុគ្គលដែលនិយាយមិនស្មោះត្រង់ចំពោះប្រវត្តិរូបរបស់ខ្លួនបែបនេះ?

[១១:៥៧:១២]

**ឆ៖** ខ្ញុំបាទកិច្ចការងារអ៊ីចឹងវាអត់សូវបានដឹងទាន។ បាទ ព្រោះរឿងនោះវាពាក់ព័ន្ធដល់ខាងក្រសួងដឹកនាំ តំបន់ ស្រុក ដែលពេលជម្លៀសចេញទៅក្រៅនៅតាមជនបទនោះ។ បាទ មិនសូវដឹងសាច់រឿងទេបាទ។

**ស៖** អរគុណ។ ខ្ញុំមានតែ ៣សំណួរទៀតទេដើម្បីបញ្ចប់នូវការសួររបស់ខ្ញុំចំពោះលោក ដោយសារពេលវេលាមានកំណត់បាទ។ សំណួរជាបន្តទៅទៀតនេះ គឺសុំសួរថា នៅពេលដែលលោកចូលមកដល់ទីក្រុងភ្នំពេញឃើញទិដ្ឋភាពអ្វីខ្លះដែលកើតមានចំពោះការជម្លៀសប្រជាជននោះ? តើលោកបានឃើញថាមានការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញពិតមែនដែរឬទេ? ក្រោយពេលដែលលោកចូលដល់ទីក្រុងភ្នំពេញមានការរំដោះហើយ តើលោកមានបានឃើញថាប្រជាជនទីក្រុងភ្នំពេញត្រូវបានគេជម្លៀសឲ្យចាកចេញពីទីក្រុងភ្នំពេញពិតមែនដែរឬទេ ចំពោះចំណុចនេះ?

[១១:៥៨:០៦]

**ឆ៖** បាទ ពិតប្រាកដមែន។ គេបើកមួយច្រកៗមិនឲ្យចេញគ្រប់ច្រកទាំងអស់ទេមុនដំបូង។ បាទ វាឆ្អេកឆ្អាចច្រើនពេក ខ្លាចមានគ្រោះអាសន្ន ពីព្រោះកាំភ្លើងវាអត់ទាន់ស្ងប់បាទ។

**ស៖** អរគុណ។ តើលោកមានបានដឹងអំពីផែនការរបស់ថ្នាក់លើ តើមានផែនការយ៉ាងដូចម្ដេចទៀតក្រោយពេលរំដោះទីក្រុងភ្នំពេញហើយ?

**ឆ៖** បាទ មានគម្រោងការផ្សេងៗច្រើនដែរ តែខ្ញុំបាទមិនសូវចាំទេ ប៉ុន្តែអង្គភាពខ្ញុំបាទហ្នឹងវាត្រូវត្រៀមលក្ខណៈចេញទៅខាងរតនគិរីតែម្ដងមិនបានសូវនៅយូរទេបាទ។

**ស៖** អរគុណ។ សំណួរចុងក្រោយរបស់ខ្ញុំ សុំសួរថា តើលោកធ្លាប់ឮគេនិយាយថា ការជម្លៀសឲ្យប្រជាជនចាកចេញពីទីក្រុងភ្នំពេញគឺក្នុងបំណងមួយទៀត ក្នុងមូលហេតុមួយទៀតគឺ ដើម្បីបញ្ចៀសប្រជាជនកុំឲ្យរងគ្រោះពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកដែរឬទេ? លោកធ្លាប់ឮពាក្យនេះដែរឬទេបាទ?

**ឆ៖** មិនធ្លាប់ឮទេបាទ។

**លោក ច័ន្ទ តារាស្មី៖**

បាទ អរគុណលោក ឆោម សែ។ ក្នុងនាមខ្ញុំតំណាងឲ្យសហព្រះរាជអាជ្ញា និងក្នុងនាមខ្ញុំផ្ទាល់ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកដ៏ជ្រាលជ្រៅ ដែលបានចូលរួមចំណែកក្នុងការឆ្លើយសំណួររបស់ខ្ញុំយ៉ាងក្បោះក្បាយនៅក្នុងអំឡុងពេលនេះ ហើយខ្ញុំសង្ឃឹមនិងជឿជាក់ថា ចម្លើយរបស់លោកពិតជាបានចូលរួមចំណែកក្នុងការស្វែងរកយុត្តិធម៌នៅសាលាក្ដីខ្មែរក្រហមនេះ។ ហើយខ្ញុំសូមជូនពរឲ្យលោកជួបតែសំណាងល្អ និងទទួលបានជោគជ័យក្នុងជីវិតក៏ដូចជាគ្រួសាររបស់លោកទទួលបាននូវសេចក្ដីជារៀងរហូត។

សូមអរគុណបាទ។

លោកប្រធាន ខ្ញុំសូមអរគុណចំពោះការអនុញ្ញាតឲ្យខ្ញុំនិយាយនៅពេលនេះ សួរសំណួរទៅលោកសាក្សីនាពេលនេះ។ សូមអរគុណបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណសាក្សី។

ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកន្លែងផ្តល់សក្ខីកម្មនេះវិញ នៅវេលាម៉ោងមួយសាមសិបនាទី។ បង្គាប់អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោកខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោម ហើយនិងឲ្យនាំគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញ នៅវេលាម៉ោង -- ឲ្យបានមុនម៉ោងមួយសាមសិបនាទីរសៀលថ្ងៃនេះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:០១ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:០៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

បាទ សូមអរគុណលោកប្រធាន អស់លោក លោកស្រីចៅក្រមជាទីគោរព។ ជម្រាបសួរសហភាតាទាំងអស់ជាទីគោរព។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ជម្រាបសួរលោកសាក្សី។ រសៀលនេះ ខ្ញុំនឹងចោទសំណួរទៅកាន់លោក ហើយខ្ញុំសូមឲ្យលោកឆ្លើយឲ្យបានច្បាស់លាស់ដែលអាចធ្វើទៅបាន។ បាទ សំណួរទី១ របស់ខ្ញុំទាក់ទងនឹងអ្វីដែលលោកបានលើកឡើងកាលពីព្រឹកមិញ។ លោកបាននិយាយថា មុនថ្ងៃទី១៧ មេសា ១៩៧៥ លោកបានចូលរួមកិច្ចប្រជុំអប់រំមួយចំនួនជាមួយនឹងសមាជិកកងពល ហើយលោកបានលើកឡើងដូចតទៅនេះ៖ “នៅពេលដែលលោកបង្រៀនឲ្យបែងចែករវាងខ្មាំង ហើយដឹងថា អ្នកណាជាខ្មាំង ហើយអ្នកណាជាមិត្ត”។ តើពេលនោះ គេនិយាយយ៉ាងម៉េចប្រាប់លោក គឺថាមុនពេលដែលដណ្តើមបានភ្នំពេញនោះ គេប្រាប់លោកថាអ្នកណាជាខ្មាំងនៅក្នុងវគ្គអប់រំទាំងអស់នោះហ្នឹង?

[១៣:៣៥:០៣]

**លោក នោម សែ៖**

**ឆ៖** គាត់ចង់នែ ស្នើឲ្យបញ្ជាក់អំពីតើអ្នកណាជាខ្មាំង? ខ្មាំងដូចជាខ្ញុំបាទបានលើកអ៊ីចឹងថា ខ្មាំងកាលសម័យនោះគឺរបប លន់ នល់ ទាហានដែល លន់ នល់ បញ្ជា អាហ្នឹងជាសត្រូវ។ ព្រោះខ្ញុំ វាធ្វើកងទ័ពដើម្បីរំដោះជាតិបញ្ចូលក្នុងចលនាហ្នឹង។ អាហ្នឹងសម័យ៧៥។ ខ្ញុំបាទ មានប៉ុណ្ណឹងទេបាទ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងអ្នកដែលធ្វើការឲ្យរបប លន់ នល់ តើលោកធ្លាប់ឮនៅសម័យនោះ គឺថានៅមុនពេលដណ្តើមបានភ្នំពេញនេះ លោកធ្លាប់ឮការប្រកាសផ្សាយតាមវិទ្យុ ឬក៏តាមមធ្យោបាយផ្សេងទៀត ដែលផ្សាយដោយអ្នកដឹកនាំចលនា ទាក់ទងទៅនឹងអ្វីដែលគេហៅថា ជនក្បត់ទាំង៧នាក់នៃរបប លន់ នល់។ តើលោកធ្លាប់ឮពីអ្នកក្បត់ទាំង៧នាក់នេះដែរឬទេ?

**ឆ៖** បាទ អាហ្នឹងឮហើយ។ សម័យនោះឮ ព្រោះទាំង គឺទម្លាក់សម្តេចនរោត្តម សីហនុ ធ្វើរដ្ឋប្រហារ។ នេះខ្ញុំបាទឮហើយ បានចលនារណសិរ្សហ្នឹងក៏វាកើតឡើង រួមកម្លាំង ពិសេសតាមជនបទ និងមានការឈឺចាប់ហ្នឹង ក៏ធ្វើការតស៊ូតាមមាគ៌ារបស់រណសិរ្សសាមគ្គីជាតិ។

[១៣:៣៧:០៦]

**ស៖** សូមអរគុណ។ ហើយតើការប្រកាសផ្សាយហ្នឹងចេញពីអ្នកណាដែរ ផ្សាយទាក់ទងទៅនឹងអ្នកក្បត់ទាំង៧នាក់នៃរបប លន់ នល់នេះ? តើលោកដឹងថាអ្នកណាផ្សាយព័ត៌មាននេះដែរឬទេ?

**ឆ៖** បាទ ចលនាហ្នឹង វាដូចអំឡុងមក វាយូរឆ្នាំហើយបាទ នឹកឃើញអាចលនាហ្នឹង វាការផ្សាយបន្តៗគ្នាហ្នឹងមក វាមិនដឹងហេតុផលយ៉ាងម៉េច ខ្ញុំបាទ វាដូចជាភ្លេច។ សម័យនោះ វាវែងមក

ហើយ វាមិនបានចងចាំអស់។ បាទ ប៉ុន្តែវាមានចលនាគេបំផុសអ៊ីចឹង វាទៅជាគគ្រឹកគគ្រេងតែម្តងក្នុងចលនាចូលរួមព្រៃ ចូលក្នុងព្រៃតស៊ូតែម្តង។ បាទ ព្រោះបាតុកម្មទៅ ក៏វាអត់មានសម្រេចបាតុកម្មហ្នឹងដោះស្រាយបានទេ មានតែការរងគ្រោះ។ ដល់អ៊ីចឹងមានតែរត់ចូលព្រៃរួមកម្លាំងគ្នាតស៊ូទៅ វាមានចលនាដឹកនាំរណសិរ្សហ្នឹងវាស្របនឹងសម្រេចចលនារបស់សម្តេចនរោត្តម សីហនុ ផង។ នេះសមានចិត្តដែលជាអ្នកចូលព្រៃតស៊ូកន្លងមក។ វាទៅជាគំនិតផ្លូវហ្នឹងទៅ ធ្វើចលនាបាទ។

**ស៖** បាទ សូមអរគុណ។ ដើម្បីឲ្យច្បាស់ជាងនេះទៅទៀតហ្នឹង តើលោកអាចដឹង -- អាចប្រាប់ថាលោកចូលមកទីក្រុងភ្នំពេញនៅពេលណាដែរឬទេ? តើកងពលរបស់លោក ឬក៏កងវរសេនាធំរបស់លោកហ្នឹងជាក្រុមទាហានដំបូងគេដែលចូលមកទីក្រុងភ្នំពេញឬ?

**ឆ៖** បាទ សម័យនោះវាមានច្រើនកងពលដែរ គេចូល ប៉ុន្តែកម្លាំងតូចៗវាមិនទាន់រៀបជាកងពល ឯកសណ្ឋានធំៗទេ ព្រោះកម្លាំងវាតិច។ ដូច្នេះមុខព្រួញហ្នឹង វាមានវរសេនាតូច វរសេនាធំ បាទតាមផ្នែកនីមួយៗ។ តែមុនចូលភ្នំពេញហ្នឹង កាលហ្នឹងវាសម័យតស៊ូហ្នឹង វាមាន មានក្នុងឋានៈការរៀបចំមានលំដាប់មេបញ្ជាការគ្រប់បែប គ្រប់យ៉ាងអី។ បាទ វាធ្វើជាកម្លាំងដែលធ្វើការតស៊ូហ្នឹង វាមានគោលការណ៍ មានឯកភាពទូទាំងប្រទេសហើយ អាហ្នឹងបានវាសម្រេចចិត្តការតស៊ូហ្នឹង ជាអ្នករំដោះជាតិហ្នឹង។

[១៣:៣៩:៤២]

**ស៖** បាទសូមអរគុណ។ ខ្ញុំសូមឲ្យលោកឆ្លើយឲ្យបានច្បាស់ជាងនេះបន្តិច គឺថាសំណួរចង់ដឹងថា សូមឲ្យឆ្លើយថា តើលោកចូលមកក្នុងទីក្រុងភ្នំពេញនេះនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥មែនទេ?

**ឆ៖** បាទ ចូល ១៧មេសា ឆ្នាំ៧៥ ហ្នឹង គឺជាកម្លាំងចូលមកវ៉ៃរំដោះទីក្រុងភ្នំពេញហ្នឹងតែម្តង។

**ស៖** បាទ សូមអរគុណ។ មុននឹងរំដោះភ្នំពេញនៅថ្ងៃទី១៧ មេសា តើមេបញ្ជាការរបស់លោក សូរ សារឿន ហ្នឹងមានចេញបញ្ជាច្បាស់លាស់ទាក់ទងទៅនឹងទាហាន លន់ នល់ ដែលស្ថិតនៅទីក្រុងភ្នំពេញដែរឬទេ? តើលោកត្រូវយកទាហាន លន់ នល់ ទៅធ្វើអ្វីនៅពេលដែលដណ្តើមទីក្រុងភ្នំពេញបាននោះ? យកទាហានទាំងអស់ហ្នឹងទៅធ្វើអី?

**ឆ៖** ទេ ក្រោយការរំដោះ វ៉ៃរំដោះយកភ្នំពេញបានហ្នឹង តែចំពោះទាហាន លន់ នល់ ហ្នឹង ខ្ញុំបាទមិនសូវដឹងថា គេយកទៅធ្វើស្អីទេ ប៉ុន្តែគេឲ្យចាកចេញពីទីក្រុងភ្នំពេញតែម្តង។ បាទ ទៅជនបទមិនដឹងជាគេមានវិធាការយ៉ាងម៉េចទេ ព្រោះខ្ញុំវាកម្រិតឋានៈដឹកនាំទាបដែរ។

[១៣:៤១:២៣]

**ស៖** បាទ សូមអរគុណ។ តើលោកអាចជម្រាបតុលាការបានដែរឬទេថា បានច្បាស់លាស់តែម្តងថា ពេលណាដែលគេចេញបញ្ជាទៅកងវរសេនាធំរបស់លោកឲ្យជម្លៀសទីក្រុងភ្នំពេញ? តើមុនពេលចូលមកដល់ទីក្រុងភ្នំពេញនោះ លោកដឹងហើយ ឬក៏ទាល់តែមកដល់ក្នុងទីក្រុងភ្នំពេញហើយ បានលោកដឹងថា គេចេញបញ្ជាឲ្យជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ?

**ឆ៖** បាទ ពេលដែលវ៉ៃចូលរំដោះទីក្រុងភ្នំពេញនេះ ហើយការជម្លៀសនេះ គេមានគម្រោងការទុកជាមុនហើយស្រេចហើយបាទ។ ព្រោះវ៉ៃកន្លែងណា ទីតាំងដែលប្រជុំជន គឺត្រូវតែដកចេញតែម្តងប្រជាជន។ ព្រោះស្ថេរភាពនៅក្នុងការផ្ទុះអាវុធសមរភូមិមួយៗកាលណាបោសសម្អាតត្រូវឲ្យអស់ បើនៅ នៅតែមានបញ្ហាអ៊ីចឹង។ ពពាក់ពពូនគ្នាទៅវាបោក ហើយនិងបាញ់វានៅតែប្រទាក់មិនអាចចប់ទេនៃការផ្ទុះអាវុធ។ បាទ ត្រូវឲ្យតែចេញ ចេញទាំងអស់គ្រប់ទីកន្លែង។ មានគម្រោងជាមុនហើយស្រេចហើយ។ បាទ មិនមែនទើបតែពន្យារពេល២-៣ថ្ងៃ ឲ្យចេញទេ។ គ្រាន់តែការចេញនោះវាយឺតពេលវាមិនឆាប់ទាន់ពេលវេលា ក៏វាមានពន្យារ២-៣ថ្ងៃទៅ វាចេះតែធ្វើដំណើរបន្តៗទៅ បាទ។

[១៣:៤២:៥៣]

**ស៖** បាទ កាលពីព្រឹកមិញលោកបានលើកឡើងថា ទាក់ទងទៅនឹងទីប្រជុំជនដែលដណ្តើមបានមុនថ្ងៃ ១៧ មេសា ៧៥ គឺថាត្រូវជម្លៀសប្រជាជនចេញដោយមូលហេតុសុវត្ថិភាពសន្តិសុខ។ តើនៅភ្នំពេញនេះ គេជម្លៀសប្រជាជនចេញពីភ្នំពេញហ្នឹង គេប្រាប់មូលហេតុដូចគ្នាដែរឬទេ? គេមានប្រាប់មូលហេតុដល់លោកដែរឬទេ ក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនេះ?

**ឆ៖** បាទ គេប្រាប់មូលហេតុអ៊ីចឹងបាទ។ ជាក់ស្តែងគេបទបញ្ជាមកភ្ជាប់រហូតអ៊ីចឹងតែម្តងគេមិនឲ្យនៅពាសវាលពាសកាលអីស្អេកស្កះអីទេ។ ព្រោះសណ្តាប់ធ្នាប់កងទ័ពវាការប្រមូលក៏វាត្រូវតែចុះធ្វើសកម្មភាពគ្រប់មុខព្រួញទាំងអស់បាទ។ តាមមុខព្រួញ តាមប្រាំពីរប្រាំបីទិសអីដែលបុកមកហ្នឹងត្រូវតែជម្លៀសចេញគ្រប់កន្លែង ដើម្បីឲ្យស្ងប់សភាពការណ៍ហ្នឹង។

**ស៖** តើគេមានបាននិយាយប្រាប់លោកថា នៅក្នុងទីក្រុងភ្នំពេញមានខ្មាំងនៅឡើយ គេមានប្រាប់លោកអ៊ីចឹងទេ?

**ឆ៖** បាទ ប្រាប់។ ខ្មាំងវ៉ៃមួយប្រឹបវាមិនទាន់អស់ទេ វានៅមាន។ ហ្នឹងវិធានការ។ ហើយកម្លាំងក៏អត់បានឈរជើងដែរ ពេលរំដោះហើយថ្មីៗ។ បន្តិចងាកចេញក្រោមកវិញ ខ្លាចសភាពការណ៍

ខាងក្នុងហ្នឹងទៀត។ មិនទាន់ឈរលើទីតាំងថា ឈ្នះដើម្បីស្ងប់នៅក្នុងពេលប្រយុទ្ធគ្នាថ្មីៗនេះដែរ។ បាទ ខ្លាចគ្រោះថ្នាក់កម្លាំង។

[១៣:៤៤:៤៥]

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងការចេញបញ្ជាឲ្យជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ តើគេឲ្យជម្លៀសប្រជាជនចេញទាំងអស់ដោយគ្មានករណីលើកលែង ឬក៏មានប្រភេទមនុស្សមួយចំនួនដែលមានសិទ្ធិនៅទីក្រុងភ្នំពេញបន្តទៀត?

**ឆ៖** បានសម្រេចឲ្យចេញទាំងអស់តែម្តង បទបញ្ជា។ អត់មាននៅសេសសល់អីទេ ប្រភេទណាក៏អត់មានឲ្យនៅដែរក្នុងប្រព័ន្ធប្រជុំជន ហើយទើបតែរំដោះថ្មីៗនេះឲ្យស្ងប់។

**ស៖** អ៊ីចឹងបើខ្ញុំយល់មិនខុសទេ គឺថាស្ត្រីមានផ្ទៃពោះ អ្នកជំងឺនៅតាមមន្ទីរពេទ្យ មនុស្សចាស់ជរា អ្នកពិការ ជនពិការហ្នឹងក៏ត្រូវតែចេញពីទីក្រុងភ្នំពេញដែរអ៊ីចឹងមែនទេ?

**ឆ៖** បាទ ជាក់ស្តែងគឺអ៊ីចឹងមែន។

**ស៖** កងទ័ពខ្មែរក្រហមចង់គ្រប់គ្រងទីក្រុងភ្នំពេញទាំងស្រុងតែម្តង ហើយក៏លោកបានលើកឡើងផងដែរ គឺថាចាប់ មានការចាប់ទាហានខ្មែរក្រហម ហើយ -- ទាហានលន់ នល់ ហើយបញ្ជូនទៅក្រោយ។ តើមានចំណុចដែលកុងត្រូលដែលគេរៀបចំឡើង ដើម្បីត្រួតពិនិត្យលើកងទ័ពលន់ នល់ ឬក៏រដ្ឋការ អ្នករដ្ឋការរបស់លន់ នល់ ដែរឬទេ?

[១៣:៤៦:៣៦]

**ឆ៖** ខ្ញុំបាទ មិនសូវដឹងល្អិតល្អន់ សព្វគ្រប់ ព្រោះក្នុងឋានៈដឹកនាំវានៅមានកម្រិតទាប។ បាទគិតសម្រេចតែមុខព្រួញរបស់ខ្លួនដែលសម្រេចតែប៉ុណ្ណោះទេ។ បាទកម្លាំងដែលគ្រប់គ្រងមានប៉ុន្មាន៥០ ៦០នាក់ក្នុងអនុសេនាធំហ្នឹង វាដឹងតែក្នុងមុខព្រួញហ្នឹងថាសហការក្នុងវរសេនាតូច វាកៀកនិស្ស័យនឹងមុខព្រួញជាប់គ្នា។ បាទ តែអត់ដឹងសន្លឹងទាំងអស់ទេ ព្រោះកម្លាំងវាច្រើន ផ្នែកច្រើនមុខព្រួញ។ ឯការជម្លៀស ការដឹកជញ្ជូនអីផ្សេងៗចំពោះឈ្លើយសឹកអីផ្សេងៗហ្នឹង លើគោលការណ៍របស់មេបញ្ជាការគ្រប់ផ្នែក ដែលគេបញ្ជាមកឲ្យចេញច្រកណា ហើយឈ្លើយសឹកយកតាមវិធីណា អាហ្នឹងស្រេចតែបទបញ្ជាគេទេ ខ្ញុំបាទបានតែអនុវត្ត បានតែធ្វើតែប៉ុណ្ណោះ។ វាអត់ទាន់មានសិទ្ធិបញ្ជាលើផែនការបាន។

**ស៖** បាទ សូមអរគុណ។ ឥឡូវខ្ញុំសូមបញ្ចប់និយាយពីប្រធានបទការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ ឥឡូវយើងនឹងនិយាយអំពីរយៈពេលបន្ទាប់ពីការជម្លៀសនេះ គឺថាចន្លោះចុងខែមេសា

៧៥ ហើយនិងពេលដែលគេចាត់តាំងឲ្យលោកទៅរតនគិរី ហើយលោកបានឆ្លើយនៅមុខចៅក្រមស៊ើបអង្កេតនៅ -- ថាគឺថាលោកទៅរតនគិរីនៅខែវិច្ឆិកា ឆ្នាំ១៩៧៥ នៅក្នុងរយៈពេលក្រោយពេលរំដោះបានទីក្រុងភ្នំពេញនេះ តើកងពលរបស់លោកឈរជើងនៅកន្លែងណា? ហើយតើ -- ហើយត្រូវយាមអីដែរនៅពេលនោះ?

[១៣:៤៨:២៩]

**ឆ៖** បាទ កងពលនេះវាបើនិយាយពីឈរជើងហ្នឹង វានៅប៉ែកខាងលិចផ្សារថ្មីទាំងអស់មួយជួរនេះ។ ហើយកម្លាំងមួយចំនួនហ្នឹង ឬក៏កន្លែងទីបញ្ជាការហ្នឹង វានៅក្បែរស្តាតអូឡាំពិកនោះទេ ចាប់ពីចំណុចហ្នឹងមក។ ហើយកងកម្លាំងរបស់ខ្ញុំបាទផ្ទាល់វាទៅខាងកើត គេឲ្យទៅការពារនៅក្រសួងឃោសនាការ។ ចូលទៅខាងក្រសួងឃោសនាការ នេះជាមុខព្រួញអង្គភាពដែលយើងខ្ញុំផ្ទាល់ ដើម្បីខ្លាចក្រែងលោពីរបីខែនេះ វាមានសភាពការណ៍ដែលសត្រូវនៅក្នុងវាមិនទាន់អស់ ខ្លាចផ្ទុះ។ ប្រហែលជារយៈ៣ខែបាទ ខ្លាចផ្ទុះសង្គ្រាមនៅក្នុងផ្ទៃក្នុងទៅទៀត នៅក្នុងកណ្តាលទីក្រុងនេះ។ ខ្ញុំបាទយល់តែពីគោលការណ៍តែប៉ុណ្ណឹង តែសភាពស្ងប់យប់ព្រលប់អីគឺដើរល្បាតគ្រប់តាមប្រព័ន្ធដងផ្លូវ។

**ស៖** បាទ សូមអរគុណ។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកលើកទី១ ដែលចុះនៅថ្ងៃទី៣១ តុលា ឆ្នាំ២០០៩ គឺជាឯកសារ E3/405 នៅក្នុងចម្លើយទី៣នៃឯកសារនេះ លោកនិយាយទៅសហចៅក្រមស៊ើបអង្កេតថា "កងពលរបស់លោកស្ថិតនៅក្រោមឱវាទកងទ័ពមជ្ឈិម ហើយកងទ័ព -- ក្រុមកងពលរបស់លោកអាចដើរក្នុងទូទាំងប្រទេស"។ តើលោកចាំរយៈពេលច្បាស់លាស់ដែលកងពលរបស់លោកត្រូវបានផ្សារភ្ជាប់ទៅនឹងកងទ័ពមជ្ឈិមតែម្តងនោះ? តើលោកចាំទេ រយៈពេលណាដែរនៅក្នុងពេលណាដែរ?

[១៣:៥០:៣៦]

**ឆ៖** នោះពេលរយៈដែលកងពលនោះ ភ្ជាប់ទៅរបស់កងទ័ពមជ្ឈិមតែម្តង រយៈពេលដែលភ្ជាប់មកចូលក្នុងភូមិភាគពិសេសហ្នឹងតែម្តង។ កងពល គឺបីកងពលប្រចាំភូមិភាគពិសេសនេះ គឺសម្រេចទីក្រុង ភារកិច្ចគឺសម្រេចទីក្រុង រំដោះទីក្រុងនេះចប់ វាទៅជាកងទ័ពចល័តសម្រាប់ប្រចាំ ហើយនិងយកកងទ័ពគ្រប់អង្គភាពរបស់ភូមិភាគនីមួយៗមកចំនួនពីរកងពល ឬក៏បីកងពលគ្រប់យុទ្ធភូមិភាគជុំវិញនេះជាប្រមាណប្រហែលជា១២កងពល របស់ទូទាំងប្រទេស កងទ័ពរបស់មជ្ឈិមតែម្តង។ ខ្ញុំបាទយល់ហើយនិងជ្រួតជ្រាបបានតែប៉ុណ្ណឹងទេបាទ។

**ស៖** បាទ សូមអរគុណ។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយលោកមួយទៀត គឺឯកសារ E2/407 នៅក្នុងចម្លើយទី១៣ លោកបានឆ្លើយដូចតទៅនេះ គឺថា “កងពល១០៥ ហើយនិងកងពលមួយចំនួនទៀត” តើលោកមានចាំថាមានកងពលផ្សេងទៀត ដែលផ្សារភ្ជាប់ទៅនឹងកងទ័ពមជ្ឈិមនេះដែរឬទេ ថាក្រៅពីកងពល៣១០, ៤៥០ និង៩២០ ជាដើមនេះ តើមានកងពលផ្សេងទៀតដែលនៅក្រោមឱវាទមជ្ឈិមនៅពេលនោះ?

**ឆ៖** មាន ប៉ុន្តែខ្ញុំបាទ មិនចាំឈ្មោះអស់ទេ មិនចាំលេខអស់ទេបាទ ខាងនិរតីនេះ ក៏មានបីកងពល ហើយខាងបូព៌ាយកពីរកងពលបញ្ចូលទៀត។ តែខ្ញុំបាទមិនចាំឈ្មោះអស់ទេ មិនចាំលេខអស់ទេ។ បាទ ចំនួន១២កងពលនោះ។

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកទី១ គឺថាឯកសារ E3/405 នៅក្នុងចម្លើយទី៣។

**លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបញ្ចាំងឯកសារនេះ ព្រោះខ្ញុំចង់ដកស្រង់លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១៣:៥៣:១០]

**សួរដោយលោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្មាឯល៖**

**ស៖** បាទ សូមអរគុណ។ នៅក្នុងចម្លើយទី៣នោះ លោកឆ្លើយដូចតទៅនេះ ខ្ញុំសូមដកស្រង់ “កងពល៨០១ ត្រូវបានបង្កើតឡើងនៅក្នុងភ្នំពេញ នៅក្នុងមហាសន្និបាតនៅស្តាតអូឡាំពិក ប្រហែលជាខែកញ្ញា”។ ខ្ញុំគិតថា បើតាមបរិបទនេះ គឺថាប្រហែល កញ្ញា ៧៥។ “ខ្ញុំជា -- នៅក្នុងកងពល៨០១ ដែលទើបតែបង្កើតថ្មីនេះ ខ្ញុំជាមេបញ្ជាការរងអនុសេនាធំលេខ១១” ហើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយដដែលនេះ លោកនិយាយថា “កងវរសេនាតូចនេះ ស្ថិតនៅក្នុងកងវរសេនាធំ -- ក្នុងកងពល៨០១”។ ព្រឹកមិញ លោកនិយាយអំពីការបង្កើតកងពល៨០១ នេះ ហើយក៏លោកបាននិយាយផងដែរ ពីអ្នកចូលនៅក្នុងសន្និបាតនេះ ដែលប្រព្រឹត្តនៅស្តាតអូឡាំពិក។ នៅពេលសន្និបាត តើគេមាននិយាយប្រាប់លោកថា កងពល៨០១ នេះ ត្រូវបញ្ជូនទៅរតនគិរីដែរឬទេ? ឬក៏គេបាននិយាយប្រាប់លោកអំពីការបញ្ជូនកងពល៨០១នេះ ទៅរតនគិរីពេលក្រោយហើយនោះទេ?

**លោក ឆោម សែះ**

**ឆ៖** ពេលក្រោយការរៀបចំនេះហើយ អាហ្នឹងវា ការផ្សព្វផ្សាយនេះ តាមរយៈកាលរបស់មេបញ្ជាការទេបាទ។ អត់មានបញ្ជារួមមកថា អង្គភាព៨០១ នេះត្រូវទៅនេះ គេលើកទិសឲ្យយើងដឹងទាំងអស់គ្នាជាទូទៅទេបាទ។ ក្រោយយើងទទួលបទបញ្ជាក្រោមការដឹកនាំរបស់កងពលវិញយកទៅផ្សព្វផ្សាយផ្ទាល់។ ឯពីអគ្គបញ្ជាការរួមផ្នែកថា អង្គភាពនេះត្រូវមានទិសទៅហ្នឹង គេអត់មានលើកជាមុនទេ។ ឲ្យនៅដោះស្រាយទប់ទល់សភាពការណ៍នៅទីក្រុងភ្នំពេញស្ងប់រវាង២, ៣ខែ ឬ៤ខែ បានត្រូវចាកចេញទៅ។

**ស៖** ព្រឹកមិញលោកបានឆ្លើយថានៅក្នុងសន្និបាតហ្នឹងមានសមាជិកកងពលទាំងអស់ តើលោកអាចធ្វើការប៉ាន់ស្មានចំនួនអ្នកចូលរួមនៅក្នុងសន្និបាតនេះដែរឬទេ? តើមានមនុស្សរាប់រយនាក់ ឬក៏រាប់ពាន់នាក់ដែលចូលរួមនៅក្នុងសន្និបាតនេះ?

**ឆ៖** ចំនួនប្រមាណជាង១.០០០នាក់បាទ។ ព្រោះចាប់ពីអនុសេនាធំរបស់កងពលឯកភាពប្រចាំយុទ្ធភូមិភាគនេះទាំងអស់។ ចាប់ពីអនុសេនាធំឡើងទៅ ត្រូវចូលរួមទាំងអស់បាទ។

[១៣:៥៦:២៧]

**ស៖** បាទសូមអរគុណ។ ព្រឹកមិញលោកបានផ្ដល់ឈ្មោះអ្នកដឹកនាំជាន់ខ្ពស់មួយចំនួនដែលបានចូលរួមសន្និបាតហ្នឹង ហើយលោកក៏បានឆ្លើយនៅក្នុងចម្លើយ E3/407 នៅថ្ងៃទី -- ចុះថ្ងៃទី៨ វិច្ឆិកា ២០០៤ ផងដែរ -- ២០០៩។ លោកនិយាយថា ចាន់ ចក្រី ហើយនិងមេកងពលផ្សេងទៀតទាំងអស់ដូចជា សុន សេន, ប៉ុល ពត, ខៀវ សំផន បានធ្វើបទឧទ្ទេសនាមនៅក្នុងមហាសន្និបាតនេះ។ តើលោកមានចាំថា នួន ជា បានធ្វើបទឧទ្ទេសនាមនៅក្នុងមហាសន្និបាតនេះដែរឬទេ?

**ឆ៖** គាត់បានធ្វើរួមសេចក្ដីថ្លែងការណ៍នៅក្នុងសន្និបាតនេះមែន ប៉ុន្តែខ្ញុំបាទមិនចាំអត្ថបទនៃសន្និបាតនេះវែងឆ្ងាយទេនៅក្នុងរយៈកាលនោះបាទ។ ប៉ុន្តែគ្រាន់ខ្ញុំបាទមើលពីចម្ងាយទៅ ឃើញគាត់ឡើងថ្លែងការណ៍។

[១៣:៥៧:៥២]

**ស៖** តើលោកដឹងឈ្មោះសម្ងាត់របស់ សុន សេន ដែរឬទេ? តើគេហៅយ៉ាងម៉េចដែរឈ្មោះសម្ងាត់គាត់ គេហៅគាត់ សុន សេន ឬក៏គាត់មានឈ្មោះជាលេខ? ឈ្មោះកូដរបស់គាត់ហ្នឹង តើគាត់ឈ្មោះអីដែរ? តើលោកដឹងទេ?

**ឆ៖** ខ្ញុំបាទមិនបានដឹងទេទាន ព្រោះនៅឆ្ងាយពីគាត់ដែរ មិនសូវបានជួបប្រទះទេ។

**ស៖** តើលោកមាននៅចាំទេ នៅក្នុងមហាសន្និបាតហ្នឹង មានចាំទេថា អ្នកដែលឡើងថ្លែងការណ៍នុ៎ង បាននិយាយអំពីវិន័យនៅក្នុងជួរកងពលផ្សេងៗទាំងអស់នុ៎ង? ឬក៏គេមាននិយាយអំពីខ្មាំងនៅក្នុងប្រទេស និងក្រៅប្រទេសដែរឬទេ?

**ឆ៖** បាទ មានអារឿងខ្មាំងក្នុងប្រទេស ក្រៅប្រទេសហ្នឹងមាន។ បាទ មិនត្រឹមតែក្រៅប្រទេសក្នុងប្រទេសទេ អាក្នុងជួរក្របខ័ណ្ឌការងាររបស់ខ្លួនហ្នឹង ក៏វាមានដែរបាទ។ ប៉ុន្តែគ្រាន់តែទិស និងវិធានការបែបបទហ្នឹង វាតាមកាលៈទេសៈដែរ វាធ្វើបានក៏បាន ធ្វើមិនបានក៏ចលនា វាចេះតែបន្តទៅទៀតទៅបាទ។ ចេះតែអប់រំបំពាក់បំប៉នពិនិត្យតាមដានគ្រប់កិច្ចការងារសព្វគ្រប់អ៊ីចឹងទៅ វាធ្វើតាមមួយដំណើរហ្នឹងមកបាទ។ នេះតាមក្របខ័ណ្ឌទេ ដឹកនាំ។

[១៣:៥៩:៣៧]

**ស៖** បាទសូមអរគុណ។ លោកបានឆ្លើយថា “មហាសន្និបាតហ្នឹងបានប្រព្រឹត្តទៅនៅខែកញ្ញា ឆ្នាំ១៩៧៥” នេះជាអ្វីដែលលោកឆ្លើយទៅសហចៅក្រមស៊ើបអង្កេត។ ខ្ញុំសូមត្រឡប់មកនិយាយអំពីរយៈពេលនេះ ហើយនិងនិយាយឲ្យបានលម្អិត ដើម្បីចង់ឲ្យដឹង ឲ្យច្បាស់ថាតើកាលបរិច្ឆេទនៃមហាសន្និបាតនៅថ្ងៃណាដោយពិតប្រាកដ? អ៊ីចឹងខ្ញុំសូមសួរលោកថា នៅក្នុងរយៈពេលខ្មែរក្រហមនេះ លោកធ្លាប់បានអានទស្សនាវដ្ដីមួយមានឈ្មោះថា “ទង់បដិវត្ត” តើលោកធ្លាប់អានទស្សនាវដ្ដីហ្នឹងដែរឬទេ ទង់បដិវត្ត?

**ឆ៖** បាទ អានេះខ្ញុំសូមបញ្ជាក់ជូនអ៊ីចេះ លោកចង់ដឹងអំពីអត្ថន័យនៃទង់បដិវត្ត។ ខ្ញុំបាទអត់ទាន់មានកម្រិតកាន់ទង់ក្រហមបដិវត្តនេះទេ។ ខ្ញុំបាទ ទើបតែចូលក្នុងកិច្ចការងារគេហៅថា សកក នេះគឺជាអង្គការមួយ។ វាបន្ទាប់នឹងទង់ក្រហមទី១ នេះ គឺទង់ទី២។ គឺទង់យុជន យុវនារី គេហៅ “សម្ព័ន្ធ”។ សម្ព័ន្ធហ្នឹង គឺជាវាមិនដល់អាទង់មួយទង់ក្រហម គឺទង់បក្ស បាទ។ ខ្ញុំបាទសិក្សាមិនទាន់ដល់ជម្រៅនោះទេ។ នេះតាមធាតុពិត។ ដូច្នេះកិច្ចការងារក្នុងវាអត់ទាន់ជម្រៅទេ បាទ និយាយពីចលនាវានៅក្នុងវណសិប្សនៅឡើយ។ ដំណើរការតស៊ូក្នុងទស្សនៈផ្ទាល់ខ្លួន វាអត់មានជ្រាលជ្រៅដូចអាកាន់អាទង់ក្រហមទី១ទេ។ បើចូលក្នុងអាទង់ក្រហមទី១ វាកាន់តែជ្រៅ។ ជម្រៅអ្វីៗផ្សេងៗនៃបដិវត្តន៍វាឃើញអស់សព្វគ្រប់ ហើយគឺជាស្នូលមួយសម្រាប់ដឹកនាំក្នុងមួយទិសរបស់កិច្ចការងាររបស់អ្នកធ្វើបដិវត្តន៍។ បាទ សូមអស់។

[១៤:០១:៤៨]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

បាទ លោកប្រធាន ដើម្បីឲ្យចំណេញពេលវេលា ខ្ញុំនឹងបង្ហាញ -- ខ្ញុំមិនបង្ហាញឯកសារហ្នឹងទេ ក៏ប៉ុន្តែខ្ញុំសូមអានទង់បដិវត្តហ្នឹងដែលចុះនៅថ្ងៃ-- នៅខែសីហា ៧៥ គឺឯកសារ E3/5 ហើយសម្រង់ដែលខ្ញុំនឹងអាននេះ គឺថានៅទំព័រ ERN ជាភាសាខ្មែរគឺ 00063324 បាទ 00063324, ជាភាសាបារាំង គឺនៅទំព័រទី១៣ នៃឯកសារនេះ។ អង់គ្លេសក៏ទំព័រ១៣ ដែរ ហើយចំណងជើងនោះ គឺថា "ជយោ! កងទ័ពបដិវត្តន៍របស់បក្សកុម្មុយនីស្តកម្ពុជាដ៏មហាអស្ចារ្យ" ខ្ញុំសូមដកស្រង់ដូចតទៅ៖ "ថ្ងៃទី២២ កក្កដា ឆ្នាំ១៩៧៥ នៅក្នុងឱកាសពិធីចាត់តាំងកងទ័ពបដិវត្តន៍របស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា សមមិត្តប្រធាននៃគណៈកម្មាធិការយោធាជាន់ខ្ពស់របស់បក្ស បានធ្វើសន្និសីទនយោបាយមួយដ៏សំខាន់ ជូនតំណាងគ្រប់អង្គភាពនៃកងទ័ពបដិវត្តន៍ប៉ុន្មាន ៣.០០០នាក់ របស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា។ ប្រធានបទនៃសន្និសីទនេះ មានដូចតទៅ៖

[១៤:០៣:៣៦]

"ទី១ គឺថា អត្ថន័យនៃមហាជ័យជម្នះជាប្រវត្តិសាស្ត្ររបស់ប្រជាជាតិ និងប្រជាជនកងទ័ព និងបក្សយើង។ ទី២ គឺប្រវត្តិសង្ខេបនៃកងទ័ពបដិវត្តន៍យើង។ ទី៣ មូលហេតុនៃមហាជ័យជម្នះរបស់កងទ័ពបដិវត្តន៍យើង និងទី៤ ភារកិច្ចថ្មីនៃកងទ័ពបដិវត្តន៍យើង" បាទ សូមបញ្ចប់ការដកស្រង់លោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

**ស៖** តើមហាសន្និបាតដែលលោកបាននិយាយជូនតុលាការនោះ លោកនិយាយថាមានអ្នកចូលរួមជា១.០០០នាក់ ហើយលោកបានផ្តល់ឈ្មោះអ្នកដឹកនាំជាន់ខ្ពស់ផងដែរ។ តើមហាសន្និបាតដែលលោកនិយាយថា ប្រព្រឹត្តទៅនៅខែកញ្ញា គឺជាកិច្ចប្រជុំមួយដែលខុសពីកិច្ចប្រជុំនៅថ្ងៃទី២២ កក្កដា ឆ្នាំ១៩៧៥ ដែរឬទេ ដែលមានខ្លឹមសារដូចអ្វីដែលខ្ញុំបានអាននោះ ឬក៏ជា ឬក៏វាដូចដែលនឹងពិធីដ៏ធំនេះ ដែលកើតមានឡើងនៅថ្ងៃទី២២ កក្កដា ឆ្នាំ១៩៧៥?

[១៤:០៥:០០]

**លោក នោម សែ៖**

**ឆ៖** បាទ តាមមតិនេះស្របបាទ ស្របអាហ្នឹងថ្ងៃហ្នឹងតែម្តងបាទ ខ្ញុំវាប៉ាន់ប្រមាណវាមិនចាំ ព្រោះខ្ញុំអត់មានកត់ត្រា ឬដឹងថាហេតុហ្នឹងវាកើតឡើងមក មកតទល់គ្នាថ្ងៃនេះ ខ្ញុំបាទមិនបានកត់ថ្ងៃខែ។

បាទ វាច្រើនឆ្នាំមកហើយ រំឭកថ្ងៃនេះវាត្រូវស្របនឹងថ្ងៃដែលគាត់លើកទង់ក្រហមនេះធ្វើកិច្ចដំណើរការនៃកំណើតកងទ័ពបដិវត្តន៍នេះ វាស្របនឹងថ្ងៃហ្នឹងមែនបាទ អត់មានថ្ងៃណាបន្តទៀតទេ។ ហើយថ្ងៃហ្នឹងក៏បានអត្ថបទផ្ទៃក្នុងគ្រប់គ្រងហេតុផល វាស្របអាហ្នឹងសភាពការណ៍ដែលគាត់បានថ្លែងអម្បាញ់មិញនេះបាទ។ នេះខ្ញុំបាទចូលរួមបានតែប៉ុណ្ណឹង។

[១៤:០៥:៥៧]

**ស៖** បាទ ខ្ញុំគិតថាការបកប្រែភាសាបារាំងនេះយើងមិនបានទទួលទាំងស្រុងហ្នឹងទេ។ ថាតើលោកគិតថាសមាជដែលលោកបានចូលរួមនោះអាចប្រព្រឹត្តទៅនៅថ្ងៃទី២២ កក្កដា ឆ្នាំ១៩៧៥ ដែរឬទេ ដែលជាកិច្ចប្រជុំប្រមូលផ្តុំកងទ័ពបដិវត្តន៍កម្ពុជានេះ តើអ៊ីចឹងទេអាចអ៊ីចឹងទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ មានភាពស្មុគស្មាញបន្តិចពាក់ព័ន្ធទៅនឹងការតាំងសំណួរដោយសហព្រះរាជអាជ្ញា ដែលសហព្រះរាជអាជ្ញាសួរទៅឲ្យសាក្សីឆ្លើយស្មានៗទៅលើរបៀបវារៈនៃកិច្ចប្រជុំនេះ។ គឺថាគឺយើងមិនគួរណាសួរទៅថា តើគាត់ជឿជាក់ថាយ៉ាងម៉េចនោះទេ? តើគាត់បានដឹងថាដូចម្តេចទៅវិញទើបត្រឹមត្រូវ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំសូមឆ្លើយ។ តាមពិតទៅ បើតាមអានទស្សនាវដ្ដីនេះ គឺថាខ្ញុំអាននោះដើម្បីឲ្យសាក្សីនឹកឃើញអំពីរយៈកាលច្បាស់លាស់ ដែលមហាសន្និបាតនេះកើត ប្រព្រឹត្តទៅ ហើយគាត់បានចូលរួម។ អ៊ីចឹងខ្ញុំចង់ដឹងថា តើមានប្រជុំទ្រង់ទ្រាយធំនេះច្រើន ឬក៏មានតែមួយនោះទេ? ហើយគឺថាមានមហាសន្និបាតដែលប្រព្រឹត្តទៅនៅថ្ងៃទី២២ កក្កដា ៧៥ នេះទេ អ៊ីចឹងហើយបានខ្ញុំសួរគាត់យ៉ាងដូច្នេះលោកប្រធាន។

[១៤:០៧:៤៦]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:០៨:២០]

**ប្រធានអង្គជំនុំ៖**

បាទ ការជំទាស់របស់មេធាវីការពារក្ដីអន្តរជាតិរបស់លោក នួន ជា ជំទាស់ទៅនឹងការតាំងសំណួរមានលក្ខណៈសមស្រប។ លោកតំណាងសហព្រះរាជអាជ្ញាគប្បីរៀបចំនូវសំណួរឡើងវិញ សំណួរបែបអម្បាញ់មិញនេះគឺមិនអាចទទួលយកបានទេ។

**លោក វាំងសង់ វ៉ាយជ៍ ដេស្មាឯល៖**

បាទ ខ្ញុំសូមរៀបសំណួរឡើងវិញលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយជ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី លោកនិយាយអំពីមហាសន្និបាតមួយដែលលោកគិតថា ប្រហែលជាប្រព្រឹត្តទៅនៅខែកញ្ញា ហើយខ្ញុំអានសម្រង់មួយនៃទង់បដិវត្តនោះនិយាយអំពីពិធីដែលរៀបចំដោយគណៈមជ្ឈិមបក្សកុម្មុយនីស្ដកម្ពុជា ដែលប្រព្រឹត្តទៅនៅថ្ងៃទី២២ កក្កដា ឆ្នាំ១៩៧៥ ដែលមានអ្នកចូលរួមជាង ១.០០០នាក់។ ហើយលោកអាចបញ្ជាក់បានដែរឬទេថា មហាសន្និបាតដែលលោកបានចូលរួមនោះបានប្រព្រឹត្តទៅ -- តើថាលោកអាចគិតថាមហាសន្និបាតដែលលោកបានចូលរួមនោះអាចជាមហាសន្និបាតដែលខ្ញុំទើបតែអានប្រាប់អម្បាញ់មិញដែរទេ?

[១៤:០៩:៥១]

**លោក អាកទូរ វែកកែន៖**

លោកប្រធាន ខ្ញុំសូមអន្តរាគមន៍ ខ្ញុំគិតថាសំណួរដែលទើបតែចោទអម្បាញ់មិញនេះមិនត្រឹមត្រូវទេ អ៊ីចឹងថាតើអាចត្រូវសួរថា អ៊ីចេះវិញ ថាតើប្រធានបទហ្នឹង វាដូចគ្នាដែរឬទេ? ឬក៏ថាគាត់ច្រឡំកាលបរិច្ឆេទដែរឬទេ? ឬយ៉ាងណា? ហើយគាត់យល់ថា ខែកក្កដានេះមិនត្រូវទេ ខែកញ្ញា បានត្រូវ។ ក៏ប៉ុន្តែបើសួរថា នេះដែលកិច្ចប្រជុំនេះជាកិច្ចតែមួយនោះ ខ្ញុំគិតថា ដូចជាមិនត្រូវទាល់តែសោះ។

**លោក វាំងសង់ វ៉ាយជ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំនឹងសួរជំហានជាជំហាន ហើយខ្ញុំមិនសួរលើប្រធានបទនេះយូរនេះទេ នោះទេ។

**សួរដោយលោក វាំងសង់ វ៉ាយជ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី ពេលខ្ញុំអានទង់បដិវត្តនេះ តើខ្លឹមសារ ដូចថា "មហាជោគជ័យជាប្រវត្តិសាស្ត្ររបស់កងទ័ពបដិវត្តន៍ ហើយភារកិច្ចថ្មីនៃកងទ័ពបដិវត្តន៍អីនេះ" ខ្លឹមសារទាំងអស់ហ្នឹង វាមានគេលើកមកនិយាយដែរឬទេ នៅក្នុងឱកាសមហាសន្និបាតដែលលោកបានចូលរួមនោះ ខ្លឹមសារទាំង

អម្បាលម៉ាន ដែលខ្ញុំនិយាយអំមិញមានប្រវត្តិសង្ខេបកងទ័ពបដិវត្តន៍យើង មូលហេតុនៃការជ័យជម្នះអីជាដើមនេះ មាននិយាយទេ នៅក្នុងមហាសន្និបាតដែលលោកបានចូលរួមនោះ?

[១៤:១១:២១]

**លោក ឆោម សែ:**

**ឆ:** បាទ ចម្លើយនេះ ខ្ញុំថា ខ្ញុំបាទ ថាមាន។ ត្រូវតាមគម្រោងដែលគាត់លើកហ្នឹងមែន ប៉ុន្តែគ្រាន់តែថ្ងៃខែ និងពេលវេលាឆ្នាំនោះ គឺថ្ងៃខែដែលគាត់លើកនេះឯង។ ខ្ញុំបាទមិនបានចាំ ក៏មិនបានកត់ដែរមួយរយៈកាលនោះ វាយូរលង់មក វាមិនមែនចាំ ព្រោះអត់មានឯកសារភ្ជាប់នៅក្នុងខ្លួនបាទទាន។ សូមអស់។

**ស:** សូមអរគុណ។ នេះជាអ្វីដែលខ្ញុំចង់ដឹងហើយ។ បន្ទាប់មកទៀត លោកបានឆ្លើយថា "លោកជាមួយនឹងកងពល៨០១ហ្នឹង គេបញ្ជូនទៅរតនគិរី"។ តើលោកចាំពីពេលដែលលោកទៅដល់រតនគិរីហ្នឹងទេ នៅពេលណាដែរ?

**ឆ:** ចុងឆ្នាំ៧៥។ ព្រោះដំណើរនេះវាយូរ ត្រង់អារឿងធាក់កង់ ពីក្រចេះ ទៅរតនគិរីនេះវាយូរ។ បាទ ពីភ្នំពេញទៅ ជិះកប៉ាល់ទឹកទៅចុះក្រចេះ កម្លាំងកងពលហ្នឹង។

**ស:** តើលោកអាចប្រាប់បានទេ ថាមានភារកិច្ចអ្វីខ្លះ ដែលត្រូវបានប្រគល់ទៅឲ្យកងពល៨០១នោះ?

**ឆ:** ទេ ភារកិច្ចមានតែទៅខាងព្រំដែនខាងជើង ខ្ញុំបាទ ដឹងតែប៉ុណ្ណឹង ការពារតាមព្រំដែនខាងជើងជាមួយវៀតណាម ហើយនិងចំណុចស្ទឹងត្រែងនេះជាមួយឡាវតែប៉ុណ្ណឹង។ គេត្រូវឲ្យកងពលនោះទៅខាងផ្នែកហ្នឹង។ បាទ ខ្ញុំបាទដឹងតែប៉ុណ្ណឹង។

[១៤:១៣:៥២]

**ស:** សូមអរគុណ។ ការបកប្រែជាភាសាបារាំង ដូចជាមិនបានពេញលេញនោះទេ។ ខ្ញុំស្តាប់ឮលោកនិយាយអំពីព្រំដែនជាមួយឡាវ។ តើលោកត្រូវត្រួតពិនិត្យព្រំដែនជាមួយវៀតណាមដែរឬទេ?

**ឆ:** បាទ ពិនិត្យតាមព្រំដែនវៀតណាម ប៉ុន្តែកងពលហ្នឹង វាមានបីវរសេនាធំ។ ដូច្នេះ មួយវរសេនាធំ មានផ្លូវលេខ១៣នេះ វាទៅឡាវ។ ពីរវរសេនាធំនោះ វាទាល់គ្នានឹងវៀតណាម បាទ ដល់ផ្លូវលេខ១៩នោះ។

**ស:** នៅសម័យនោះ តើវៀតណាមត្រូវបានគេចាត់ទុកថា ជាការគំរាមកំហែង ឬក៏ជាខ្មាំង

របស់របបខ្មែរក្រហមដែរឬទេ?

**ឆ៖** បាទ ពីមុនវាមិត្តភាព តែក្រោយមកវាបាក់បែកគ្នា។ វាស្មើនឹងសត្រូវពាក់កណ្តាល មិនទាន់កាត់ទៅជាសត្រូវពិតទេ។ ប៉ុន្តែការព្រំដែនទៅ វានៅលើបលនឹងគ្នា ចែកខណ្ឌមិនច្បាស់ទៀត បាទ ប៉ែកខាងជើង។ នៅប៉ះខាងនេះ ប៉ះខាងនោះ វាអត់ទាន់សម្រុងដែរ បានវានៅទុកថា មិត្តក៏មិនទាន់ដាច់ស្រេច សត្រូវក៏វាកាន់តែកើន។ ដូច្នេះ វាអាចមានការប៉ះទង្គិចគ្នា។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំនិយាយអំពីរចនាសម្ព័ន្ធរបស់កងពល៨០១ យើងបែងចែករយៈពេលពីរ គឺរយៈពេលដំបូងនោះ គឺរយៈពេលដែលមានចាប់ពីពេលដែលលោកទៅរតនគិរី លោកជាអនុបញ្ជាការកងវរសេនាធំ១១ ហើយបន្ទាប់មកទៀត ខ្ញុំនឹងនិយាយពីរយៈពេលមួយទៀតដែលចាប់ពីពេលដែលលោកកាន់តួនាទីនៅមន្ទីរអប់រំកែប្រែអូរកន្សែង។

[១៤:១៦:២២]

ខ្ញុំសូមចាប់ផ្តើមជាមួយនឹងរយៈពេលដែលចាប់ពីលោកទៅដល់រតនគិរី រហូតទៅដល់ចុងឆ្នាំ៧៦ ហើយប្រសិនបើខ្ញុំមិនច្រឡំទេ គឺថាលោកនៅជាអនុបញ្ជាការ កងវរៈ -- កងអនុសេនាធំ១១។ តើលោកអាចបញ្ជាក់អំពីកងវរសេនាធំទាំងបី ដែលស្ថិតនៅក្នុងកងពល៨០១ នោះ។ តើមានអ្វីខ្លះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី!

**លោក សុន អរុណ៖**

ខ្ញុំឮលោកព្រះរាជអាជ្ញានិយាយពីរដង ម្តងកងវរសេនាធំ ម្តងទៀតកងអនុសេនាធំ។ ហ្នឹងកំហុសមកពីបកប្រែក៏មិនដឹង ឬក៏លោកមានចេតនានឹងនិយាយអ៊ីចឹង។ សូមឲ្យបញ្ជាក់ឲ្យច្បាស់ ដើម្បីឲ្យសាក្សីដឹងថាគាត់ត្រូវនិយាយយ៉ាងម៉េច។ សូមអរគុណ។

[១៤:១៧:៣៤]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ ចំពោះខ្ញុំ ខ្ញុំគិតប្រហែលជាអាចមានបញ្ហាបកប្រែ។ ខ្ញុំនិយាយអំពីកងពល៨០១ ហើយអម្បាញ់មិញនេះ សាក្សីគាត់បាននិយាយអំពីកងវរសេនាធំនៅវៀតណាម។

**ស៖** ដូច្នេះខ្ញុំចង់ដឹងអំពីកងវរសេនាធំទាំងបីនៅតំបន់វៀតណាមនោះ?

**លោក នោម សែ៖**

**ឆ៖** បាទ ចង់ដឹងលេខ ឬក៏ចង់ដឹងកម្លាំង? ឬក៏ថាចង់ម៉េច? ខ្ញុំបាទសូមបញ្ជាក់សំណួរឡើងវិញ។

**ស៖** បាទ ខ្ញុំសំដៅទៅដល់លេខ ឬក៏ឈ្មោះរបស់កងវរសេនាធំទាំងបីនេះ?

**ឆ៖** បាទ សូមជម្រាបជូនថា ក្នុងកងពល៨០១ វាមានវរសេនាធំបី។ វាមានវរសេនាតូចបីទៀត របស់មួយកងពលធំនេះ។ ដូច្នេះវរសេនាធំទី១ គឺ៨១។ វរសេនាធំ៨១នេះមានភារកិច្ចចាល់ទាល់គ្នានៅបរកែវ -- អ៊ូនែ! អូរយ៉ាដាវ បាទទាល់មុខផ្លូវលេខ១៩។ មកចាល់នឹងគ្នានៅក្បាលអូរសេដ្ឋី ទៅប៉ែកខាងជើង។ ឯអាផតកន្ទុយនាគនេះ ចាប់ពីអូរសេដ្ឋីទៅ ទៅដល់ទាល់គ្នាអាកន្ទុយនាគនេះ មុខសញ្ញាធំរបស់៨៣។ បាទ ចុះមកអាកន្ទុយនាគមកប៉ែកខាងជើងនេះ ទាល់គ្នានឹងដែនឡាវនេះ គឺ៨២ ទាល់គ្នានឹងមេគង្គ។ អាហ្នឹងខ្សែក្រវាត់របស់វរសេនាធំ។ ឯបីវរសេនាតូច និងបួនកងដឹកជញ្ជូននេះ វានៅជុំវិញទីបញ្ជាការ។ ទីបញ្ជាការនេះនៅប្រចាំវ៉ឺនសៃ ក្បែរមាត់ទន្លេបាទ។

[១៤:១៩:៣៤]

តែភារកិច្ចផ្ទាល់ខ្លួនរបស់ខ្ញុំបាទ មានភារកិច្ចជាអនុសេនាធំ អនុៗសេនាធំ បាទអនុបញ្ជារបស់អនុសេនាធំ។ បាទ ក្នុងរយៈកាល៧៥ដែលទៅដល់នេះ ក្នុងមួយឆ្នាំជាងនេះ ខ្ញុំបាទនៅកិច្ចការងារយោធានៅឡើយ ទៅពិនិត្យខ្សែបន្ទាត់តាមទន្លេសេសាន ព្រំដែនក្រវាត់ចាប់តាំងពីម្តុំពីអូរត្រេះជាប់នឹងអូរយ៉ាដាវនេះ ព្រំប្រទល់នេះទៅអូរសេដ្ឋី ខាងជើងខ្សែក្រវាត់ផុតកន្ទុយនាគ។

**ប្រធានអង្គជំនុំ៖**

ប៉ុណ្ណឹងៗសិនបានហើយសាក្សី។ សូមសាក្សីឆ្លើយតបទៅនឹងសំណួរកម្រិតភាពចាំបាច់ ដើម្បីឆ្លើយតបទៅនឹងសំណួរបានហើយ។ គេអាចនឹងតាំងសំណួរជាច្រើនទៀតចំពោះលោក។

**សួរដោយលោក វ៉ាំងសង់ វ៉ាយជ័ ដេស្នាឯល៖**

**ស៖** សូមអរគុណលោកសាក្សី។ តើមានវរសេនាធំ៨៣ ដែរឬទេ? ខ្ញុំមិនសួរថា ឈរជើងនៅឯណាទេ គ្រាន់តែខ្ញុំចង់ដឹងថា តើមានវរសេនាធំ៨៣ ដែរឬទេ?

**លោក នោម សែ៖**

**ឆ៖** បាទ មាន។ ចុះខ្ញុំជម្រាបជូនបាន ហើយអំមិញ។

[១៤:២១:១០]

**ស៖** បាទ សូមអរគុណ។ ពីព្រោះថានៅក្នុងការបកប្រែបារាំង ខ្ញុំអត់បានឮ។ តើអ្នកណាជា

លេខាកងពល៨០១ នៅពេលនោះ?

**ឆ៖** បាទ ស៊ូ សារឿន។

**ស៖** ហើយអ្នកណាជាអនុរបស់គាត់?

**ឆ៖** បន្ទាប់ពី ស៊ូ សារឿន មក ប៉ោ សំអុល។

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយបញ្ហានេះនៅពេលក្រោយ។ នៅក្នុងកងពល៨០១ នោះតើមានអង្គភាពពិសេសដែរឬទេ? ហើយបើមានតើឧទាហរណ៍ដូចជាមានអង្គភាពពិសេស ទទួលបន្ទុកខាងភស្តុភារដែរឬទេ? ប្រសិនបើមានថា មានទៅ។

**ឆ៖** បាទ មាន។

[១៤:២២:២៦]

**ស៖** តើអង្គភាពភស្តុភារដែលលោកថាមាននោះ មានឈ្មោះ ឬក៏មានលេខទេ?

**ឆ៖** បាទ មានលេខ៨០៦។

**ស៖** លោកបានរៀបរាប់អំពីរចនាសម្ព័ន្ធដឹកនាំនៃគណៈកម្មាធិការព្លិសាន នៅក្នុងកំណត់ហេតុរបស់លោកដែលមានលេខ E3/405។ លោកបានឆ្លើយថា "តាយ៉ា ជាលេខា ហើយដែលក្រោយមកត្រូវបានជំនួសដោយ តាឡៅ ក្រោយពីគេចាប់ខ្លួន តាយ៉ា។ បន្ទាប់មក តា០៥ សៅ សារុន ឡើងជាលេខា"។ តើលោកអាចនិយាយអំពីការបាត់ខ្លួន ម៉ែន សាន ហៅ តាយ៉ា នេះបានដែរឬទេ?

**ឆ៖** ទេ ម៉ែន សាន ខ្ញុំបាទមិនដែលស្គាល់ឈ្មោះទេ។ បើតាយ៉ា នេះតែបាត់ខ្លួនដោយហេតុផលយ៉ាងម៉េច ខ្ញុំបាទក៏មិនបានដឹងដែរ ព្រោះគេឋានៈខ្ពស់ដែរ។ ប៉ុន្តែការបាត់រូបរាងនោះ វាមិនដឹងជាបាត់ក្នុងរយៈឆ្នាំពីពាន់ -- ១៩៧៧ ខ្ញុំដឹងតែពេលវេលាប៉ុណ្ណឹងទេ។

[១៤:២៤:១៨]

**ស៖** តើលោកដឹងថា តាយ៉ា ហ្នឹងបាត់ខ្លួនដោយរបៀបណា? អ្នកណាជាអ្នកប្រាប់រឿងនេះដល់លោក?

**ឆ៖** រឿងប្រាប់រឿងអីនោះ រឿងវាវែងឆ្ងាយច្រើនដែរ ខ្ញុំបាទមិនសូវបានរៀបរាប់វែងឆ្ងាយច្រើនទេ ប៉ុន្តែគ្រាន់តែថា កិច្ចការងាររបស់យុទ្ធភូមិភាគ របស់ភូមិភាគខាងព្លិសាន ក្នុងឋានៈខ្ញុំបាទនៅក្នុងកងពលវាដឹងតែកិច្ចការងារក្នុងកងពល។ តែត្រង់គេបាត់រូបរបស់ភូមិភាគហ្នឹងរឿងហេតុអីផ្សេងៗលុះត្រាតែកងពលហ្នឹងគេផ្សព្វផ្សាយមកប្រាប់ តែពេលខ្លះគេប្រាប់ ពេលខ្លះគេមិនប្រាប់។ អាហ្នឹងគឺជា

រឿងកិច្ចការងារផ្ទៃក្នុង។ អ៊ីចឹងទេ បាទ។

[១៤:២៥:០៦]

**ស៖** សូមអរគុណ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្ទាឯល៖**

លោកប្រធាន ខ្ញុំសូមអានកំណត់ហេតុស្ដាប់ចម្លើយសាក្សីដែលមានលេខ E3/405 សំណួរ-ចម្លើយ២១។ ប្រហែលជាលោកមេធាវីអាចបង្ហាញនូវផ្នែកដែលពាក់ព័ន្ធដែលខ្ញុំចង់អាននេះជូនគាត់បាន ហើយសុំការអនុញ្ញាតពីលោកប្រធានបង្ហាញជូននៅលើអេក្រង់។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្ទាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំច្រឡំទេលោកប្រធាន អម្បាញ់មិញមិនមែនសំណួរ-ចម្លើយ២១ ទេ គឺសំណួរ-ចម្លើយ២២។

[១៤:២៦:០៨]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្ទាឯល៖**

**ស៖** លោកសាក្សី លោកឆ្លើយថា "ក្រោយថ្ងៃរំដោះ១៧ មេសា ឆ្នាំ៧៥ តាយ៉ា ជាប្រធានភូមិភាគព្លៃសាន។ តាធាត់ ជាអ្នកទទួលបន្ទុកយោធាភូមិភាគ។ នៅពេល តាយ៉ា បាត់ខ្លួននៅឆ្នាំ១៩៧៧ ដោយគេហៅគាត់មកធ្វើការនៅភ្នំពេញ ហើយក៏គេចាប់ខ្លួនគាត់តែម្ដង។ ខ្ញុំដឹងតាមរយៈការប្រជុំផ្សព្វផ្សាយ ដោយក្នុងអង្គប្រជុំគេប្រាប់ថា តាយ៉ា ពាក់ព័ន្ធជាមួយនឹងយួន និងការចូលដៃចូលជើងសហព័ន្ធឥណ្ឌូចិន។ តាយ៉ា ជាសមាជិកគណៈមជ្ឈិម ប្រហែលជាមនុស្សទី៧ ឬទី៩"។ សូមបញ្ចប់ការដកស្រង់។ លោកសាក្សី តើវាជារឿងធម្មតាដែរឬទេនៅពេលដែលកម្មាភិបាលជាន់ខ្ពស់ភូមិភាគដែលត្រូវបានគេបញ្ជូន -- កោះឲ្យមកភ្នំពេញនោះ ហើយបន្ទាប់មកបាត់ខ្លួននោះ?

**លោក ឆោម សែ៖**

**ឆ៖** អានេះ ក្របខ័ណ្ឌនេះ ខ្ញុំបាទបញ្ជាក់ទៅរឿងនេះវាជារឿងពិតបាទកន្លងទៅ។ ការផ្សព្វផ្សាយដូចខ្ញុំបានជម្រាបជូនអ៊ីចឹង វា -- បាទ ខ្ញុំបាទស្របនូវមតិដែលខ្ញុំបាទបានរាយជូនអ៊ីចឹង។ បាទ ព្រោះជាការផ្សព្វផ្សាយកិច្ចការងារផ្ទៃក្នុង គេតែងតែផ្ដល់ហើយក្នុងក្របខ័ណ្ឌដឹកនាំ កម្រិតនេះ កម្រិត

នោះឲ្យជូនព័ត៌មានដឹងទាំងអស់សព្វគ្រប់ ដើម្បីពង្រឹង អ្នកដែលនៅសល់ហ្នឹងឲ្យវាកាន់តែរឹងប៉ឹងឡើង គិតគូរបែបនេះបែបនោះ តាមគម្រោងការរបស់ដឹកនាំ។

[១៤:២៨:០៦]

**ស៖** សូមអរគុណ។ កងពល៨០១ ដែលជាកងពលរបស់មជ្ឈិមនោះ តើមានទំនាក់ទំនងអ្វីខ្លះរវាងកងពលនេះជាមួយនឹងភូមិភាគឦសាន តើលោកអាចបញ្ជាក់បានទេថាភូមិភាគឦសាននោះក៏មានកងកម្លាំងយោធាផងដែរ?

**ឆ៖** បាទ កាលដែលធ្វើដំណើរទៅហ្នឹងវាគោលការណ៍សហការគ្នា ជួយជាកម្លាំង ផ្តល់សេវាកម្មគ្នារវាងខាងតំបន់១, តំបន់៧អីគេនេះ វាកៀកព្រំដែនជាងគេ។ ដូច្នេះវាគោលការណ៍សហការគ្នាដែរ កិច្ចការងារ។ ប៉ុន្តែចំពោះដែលខ្ញុំបាទនេះដែលវាក្នុងឋានៈដឹកនាំមានកម្រិតទាប មិនសូវជាដឹងសាច់រឿងនេះទេ រឿងជ្រាលជ្រៅអីចេះ វាមិនសូវឃើញជាក់ស្តែងទេ គិតតែពីរឿងបំពេញករណីយកិច្ចសម្រាប់ខ្លួនឯង ដើម្បីកុំឲ្យគេប្រកាន់ថ្នាក់ក្នុងការដឹកនាំដែលវាមិនពិតប្រាកដ។ អាហ្នឹងជាជំហរពង្រឹងតែខ្លួនឯងទេ ដើម្បីការពារផលប្រយោជន៍ព្រោះក្នុងឋានៈពេលនោះ វាចូលក្នុងដំណាក់កាលបន្តកិច្ចដំណើរការធ្វើសង្គមនិយម។ កិច្ចការងារនេះវាត្រូវធ្វើការតស៊ូវណ្ណៈនេះក្នុងជម្រៅកាន់តែជ្រៅឡើង។ តែផ្ទាល់ខ្លួននេះក៏វាមានការព្រួយបារម្ភដែរក្នុងចលនានេះ។ អីចឹងបានថាកិច្ចការងារ វាដឹង តែឲ្យជ្រៅ ឲ្យសព្វឲ្យគ្រប់ ខ្ញុំបាទមិនបានទទួលសព្វគ្រប់ទេបាទ។

[១៤:២៩:៤៥]

**ស៖** សូមអរគុណ។ នៅពេលនោះ ឬក៏នៅពេលក្រោយនៅពេលដែលលោកដឹកនាំមន្ទីរអប់រំកែប្រែអូរកន្សែង តើលោកដឹងថាមានការសហការគ្នារវាងកងពល៨០១ និងភូមិភាគឦសានខាងផ្នែកសន្តិសុខ ការវាយប្រហារខ្មាំងខាងក្នុង និងខាងក្រៅនៅភូមិភាគឦសាននោះ?

**ឆ៖** បាទការដែលខ្ញុំបាទមកគ្រប់គ្រងការងារដំបូង ក្នុងកិច្ចការងារខាងក្រសួងអប់រំរបស់កងពលនេះ ខ្ញុំបាទដឹងតែតួនាទីទេ បាទតួនាទីអង្គភាពដែលគេប្រមូលមកតាមវរសេនាតូច វរសេនាធំ យកមកឲ្យកសាងលក្ខណៈសម្បត្តិដែលកម្លាំងនេះមានកម្មាភិបាលថ្នាក់ត្រឹមអនុសេនាធំ បានគេឲ្យមកគ្រប់គ្រងតែអនុសេនាធំប្រធានឡើងទៅលើទៅ អាហ្នឹងវាអត់មានសិទ្ធិទេ ព្រោះកម្រិតខ្ញុំបាទវាមានកម្រិតទាប។ បាទ ទទួលបានតែប៉ុណ្ណឹងទេ ដូច្នេះមកការគ្រប់គ្រង មិនទាន់ថា មានតួនាទីទទួលខាងសហករណ៍ ឬក៏ខាងសហជីពទេ។ ខ្ញុំបាទដឹងតែតួនាទីគ្រប់គ្រងតែសមាសភាពប្រចាំកងពល៨០១។ បាទ តែប៉ុណ្ណឹងទេ។

[១៤:៣១:១៣]

**ស៖** សូមអរគុណ។ លោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្ហាញឯកសារជូនសាក្សី និងបញ្ចាំងនៅលើអេក្រង់ គឺឯកសារលេខ E3/876 ឬក៏លេខ IS21.15។ លោកសាក្សី ក្នុងឋានៈលោកជាប្រធានមន្ទីរអប់រំកែប្រែអូរកន្សែង ខ្ញុំជឿថាលោកអាចជម្រាបខ្ញុំបន្ថែមបានទៀត អំពីទូរលេខ៤៣ ដែលផ្ញើដោយឈ្មោះ ឡឹ នៅកងពល៨០១ ជូនបងរឿនជាទីស្នេហា នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៧៧។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមការអនុញ្ញាតពីលោកប្រធានផ្តល់ឯកសារក្រដាសជូនសាក្សី និងបញ្ចាំងឯកសារនៅលើអេក្រង់កុំព្យូទ័រ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ នៅក្នុងពេលដែលសាក្សីអាននោះ ទូរលេខនេះផ្ញើដោយ ឡឹ ជូនបងរឿន ជាទីស្នេហា ចុះថ្ងៃទី២៣ ខែ៤ ឆ្នាំ១៩៧៧ ចម្លងជូនបង៨៩, បង៨១, បងរឿន មន្ទីរឯកសារ។ ជាសង្ខេបគឺវាពាក់ព័ន្ធទៅនឹងការចាប់ខ្មាំង។ បញ្ហាខ្មាំងឈ្មោះ លិ ហើយគេបានប្រគល់ឲ្យ អ៊ំឡៅ ហើយ ហើយមនុស្សពីរនាក់ទៀតនោះ ត្រូវបានប្រគល់យកទៅឲ្យខាងស្រុក។ ខ្ញុំសូមអានចំណុចទី៣ នៃទូរលេខនេះដែលមានរៀបរាប់ដូចតទៅនេះ៖ “សភាពការណ៍ខាងលើ គឺការកំណត់ខ្មាំង អ៊ំឡៅ គាត់មានវិធានការចាប់ជាបន្តបន្ទាប់ ប៉ុន្តែមិនទាន់អស់។ គាត់មានសំណូមពរឲ្យយើងសហការជាមួយគាត់ជិតស្និទ្ធ និងឲ្យយើងជួយតាមដានសហការទៀត” សូមបញ្ចប់ការដកស្រង់។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី តើលោកស្គាល់ឈ្មោះ ឡឹ ដែលជាអ្នកសរសេរទូរលេខនេះទេ? ហើយគាត់ផ្ញើទូរលេខនេះជូនបងរឿន តើលោកស្គាល់គាត់ទេ?

**លោក នោម សែ៖**

**ឆ៖** ឈ្មោះ ឡឹ ខ្ញុំបាទស្គាល់ ប៉ុន្តែសាច់រឿងនេះ ខ្ញុំបាទមិនបានយល់ ហើយក៏មិនស្គាល់ ក៏មិនបានឮដែរ។ វាអត់មានពាក់ព័ន្ធមកដល់ខ្ញុំបាទទេ។

[១៤:៣៤:១១]

**ស៖** សូមអរគុណ។ តើ ឡឹ នេះគាត់មានមុខងារអ្វីនៅក្នុងកងពល៨០១?

**ឆ៖** លោក ឡឹ នេះតាមរយៈកាល ក្រោយមក ព្រោះកម្មាភិបាលមេបញ្ជាការរបស់ ៨០១ហ្នឹង ដកសមាជិកហ្នឹងចេះតែបន្តបន្ទាប់ ប្រហែលចូលទី៣ រយៈកាលទី៣ គាត់ជាសមាជិករបស់កងពល ៨០១។

**ស៖** សូមអរគុណ។ នៅពេលដែលលោកនិយាយថា សមាជិកកងពល៨០១នោះ លោកសំដៅទៅដល់សមាជិកគណៈ៨០១ ហ្នឹងមែនទេ?

**ឆ៖** បាទ ជាគណៈបាទ។

**ស៖** ចុះ អ៊ំឡៅ វិញដែលសរសេរនៅក្នុងទូរលេខនេះ តើគាត់ជាអ្នកណាដែរ អ៊ំឡៅ ហ្នឹង? ហើយក្នុងឯកសារនោះគេបញ្ជាក់ថា មានការចាប់ហើយគាត់ចង់យើងហ្នឹងសហការជាមួយគាត់ជិតស្និទ្ធ នៅក្នុងឯកសារហ្នឹង អ៊ីចឹងតើ អ៊ំឡៅ ហ្នឹងគាត់ជាអ្នកណា?

**ឆ៖** គាត់ដឹកនាំខាងមូលដ្ឋាន។ គាត់អត់មានចូលក្នុងយោធាទេ។ ខ្ញុំបាទវាមិនសូវដឹងច្បាស់ទេ ឈ្មោះ ឡៅ។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំចូលទៅពេលដែលលោកជាប្រធានមន្ទីរអប់រំកែប្រែអូរកន្សែង។ តើធ្លាប់មានទេថា ជនស៊ីវិលត្រូវបានបញ្ជូនទៅមន្ទីរអប់រំកែប្រែរបស់លោកនោះ ហើយបើមានគឺនៅពេលណាដែរ?

**ឆ៖** នៅពេលវេលាដែលជនស៊ីវិលបញ្ជូនមកខ្ញុំហ្នឹងវា ប្រហែលជាឆ្នាំ១៩៧៧ ក្នុងពាក់កណ្ដាល បាទ ក្នុងពាក់កណ្ដាលឆ្នាំ១៩៧៧។

[១៤:៣៦:៥៤]

**ស៖** សូមអរគុណ។ សូមលោកបញ្ជាក់ថានៅពេលដែលជនស៊ីវិលត្រូវបានបញ្ជូនទៅនោះ តើជារដ្ឋបាលដែលគ្រប់គ្រងដោយតំបន់ -- ដោយភូមិភាគ(សូមទោស) ឬក៏បញ្ជូនមកតាមរយៈកងពល ៨០១?

**ឆ៖** បាទ កាលនោះខ្ញុំបាទន័ះ ដូចជាមិនបានចាំទេ ប៉ុន្តែខាងមូលដ្ឋានគេប្រគល់ជូនមកវាមាន សហជីពផង សហករណ៍ផង ប៉ុនមិនប៉ុន្មានគ្រួទេ មានក្មេងផង មានចាស់ផង។ ប៉ុន្តែសេចក្ដីសម្រេចនេះ បានមកពី សួរ សារឿន ទេដែលឲ្យទទួលបាទ បានជាខ្ញុំបាទហ៊ានទទួលយកមកគ្រប់គ្រង ព្រោះខ្ញុំបាទ អត់មានសមត្ថភាពនឹងទទួល។ ដល់គាត់វេរមក ត្រូវតែទទួលទៅ យកទៅអប់រំសិនទៅព្រោះរយៈកាល

នេះមានការពាក់ព័ន្ធច្រើនណាស់។ ហ្នឹងយកមកផ្ញើក្នុងរយៈកាលហ្នឹងទៅ។ បានជាក្រោយមកបានន៉ែដោះទៅវិញឲ្យទៅផុត ដើម្បីសាងភូមិ សាងដ្ឋានវិញចុះ។ ពួកហ្នឹងគ្រប់គ្រងតែឃោធាបន្តទៅទៀត។

[១៤:៣៨:១៣]

**ស៖** សូមអរគុណ។ ប្រហែលនេះជាសំណួរចុងក្រោយមុនពេលឈប់សម្រាក។ តើលោកដឹងទេថា សៅ សារឿន (តាមសំឡេងដើម) នោះ គាត់ជួប តាយ៉ា ឬតាឡៅ ញឹកញាប់ដែរឬទេ នៅពេលដែលគាត់ នៅពេលជា ប្រធានកងពល៨០១ នោះ?

**ឆ៖** មិនអាចប៉ាន់សន្និដ្ឋានជម្រាបជូនថា គាត់ប្រក្រតី មិនប្រក្រតីទេ ព្រោះខ្ញុំបាទនៅឆ្ងាយ ហើយកិច្ចការងារនេះមិនត្រូវទទួល ព្រោះវាគ្មានតួនាទីរបស់ខ្លួនបាទ។

**ប្រធានអង្គជំនុំ៖**

អរគុណតំណាងសហព្រះរាជអាជ្ញា។ អរគុណសាក្សី។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលសម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនេះវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៩ នាទី ដល់ម៉ោង ១៥:០២ នាទី)*

[១៥:០២:១៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ ថានៅក្នុងកងពល៨០១ អ្នកណាមានសិទ្ធិអំណាចសម្រេចលើជោគវាសនាខ្មាំង ដែលរកឃើញនៅក្នុងភូមិភាគនុ៎ង នៅក្នុងភូមិភាគដែលកងពល៨០១ ឈរជើងនុ៎ង?

**លោក នោម សែ៖**

**ឆ៖** ខ្ញុំបាទនែ៎ អត់មានមតិសម្រេច បានដឹងទេពីសាច់រឿងនេះបាទ។

[១៥:០៣:២៤]

**ស៖** ហាក់ដូចជាស្មុគស្មាញ ខ្ញុំត្រឡប់មកក្រោយវិញ។ តើលោកអាចនិយាយបានទេ ថានៅមន្ទីរអប់រំកែប្រែនៅអូរកន្សែងនោះបង្កើតនោះនពេលណាដែរ នៅក្នុង -- ហេតុអីដែលមន្ទីរអប់រំកែប្រែហ្នឹងបង្កើតឡើងនៅក្នុងកងពល៨០១ ហ្នឹង?

**ឆ៖** មូលហេតុខ្ញុំក៏មិនសូវបានដឹងជម្រៅដែរ ប៉ុន្តែការពិគ្រោះពិភាក្សារបស់គណៈកម្មការរបស់កងពលនេះ គេមើលទៅវាសភាពការណ៍ព្រំដែនវាអត់ប្រក្រតី។ ដូច្នេះ កម្លាំងវារពើករពើងនៅក្នុងកងទ័ពគ្រប់កន្លែង ហើយសមាសភាព ការពាក់ព័ន្ធជនសេរីនៅក្នុងជួរកងទ័ពហ្នឹង វាដូចវាខ្វះសណ្ដាប់ធ្នាប់ច្រើន ហើយម្យ៉ាងជីវភាពរស់នៅក្នុងកងទ័ពហ្នឹងក៏វាត្រូវលំបាក សព្វគ្រប់ដែរ។ ដូច្នេះគេមើលទៅវា តាមអង្គភាពជាវរសេនាធំមួយៗ ក៏គេជម្រើសដែរ។ មានទ័ពដែលត្រូវទទួលវិន័យហ្នឹងនៅតាមហ្នឹងមួយក្រុម ឬក៏ពីរក្រុមអីចឹងទៅ មើលទៅវា ដូចជាសភាពការណ៍ការងារនេះវាមានបណ្ដាញពិបាក។ គ្រប់គ្រងលើខគ្រប់ផ្នែក ព្រំដែនផង ដោះស្រាយជីវភាពផង សភាពការណ៍ជុំវិញក្នុងអង្គភាពផង។ ដូច្នេះក៏ចលនារៀបចំ រៀបចំកិច្ចការងារក្រសួងអប់រំប្រចាំកន្លែងកងពលហ្នឹងតែមួយតែម្តង ដើម្បីដកយកកម្លាំងដែលវាមិនប្រក្រតីនេះ វាយកមកចេញឆ្ងាយពីអង្គភាពប្រយុទ្ធបាទ។

[១៥:០៥:០២៦]

**ស៖** បាទ សូមអរគុណ។ លោកក៏បានលើកឡើងផងដែរនៅក្នុងកំណត់ហេតុស្តាប់ចម្លើយលើកទី១ របស់លោកចំពោះមុខសហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/405 នៅចម្លើយទី៦ នៃចម្លើយរបស់លោកនេះ គឺថាលោកនិយាយថា “មន្ទីរអូរកន្សែងនេះកើតឡើងនៅពេលដែលមានចលនាខ្មាំងផ្ទៃ

ក្នុងកើតឡើងទូទាំងប្រទេស" បាទ សូមបញ្ចប់ការដកស្រង់។ តើពេលដែលយើងនិយាយថាចលនាខ្មាំងខាងក្នុងប្រទេសទាំងមូលនេះសំដៅលើអ្វីទៅ?

**ឆ៖** រឿងនេះរឿងកិច្ចការងារផ្ទៃក្នុងអង្គភាព ហើយក៏ដូចជាទូទាំងប្រទេស ដូចរឿងដែលបានលើកឡើងថាក្នុងអង្គភាពបន្តិចត្រូវការដកកម្មាភិបាលនេះយកទៅរៀន ថ្នាក់វរសេនីយ៍ ថ្នាក់វរសេនាតូចធំ ដកទៅមានអ្នកខ្លះមក អ្នកខ្លះបាត់ លើកកិច្ចការងារផ្ទៃក្នុងនេះវាមើលទៅវាអាសន្និសុខក្រោយរំដោះមកនេះ វាដូចវាមានបក្ខពួកច្រើនផ្នែក ដែលវាមិនស្របនឹងចលនា ដែលសង្គមនេះដឹកនាំវាចេះតែចង់ប្រេះឆាគ្នា។ អ៊ីចឹងទៅបានន័យឃើញថា ខ្មាំងវាចេះតែមាននៅក្នុងលក្ខណៈនេះ។ ដូច្នេះការអប់រំ ការផ្សព្វផ្សាយទៅក៏គេមានវិធានការធ្វើកិច្ចដំណើរការហ្នឹងទៅ។ ខ្ញុំបាទដឹងតែសាច់រឿងតែប៉ុណ្ណឹងទេ។

[១៥:០៧:១៦]

**សៈ** បាទ សូមអរគុណ។ តើលោកចាំរយៈពេលដែលគេបង្កើតមន្ទីរហ្នឹងដែរឬទេ? ហើយពេលដែលលោកធ្វើជាប្រធានមន្ទីរហ្នឹង តើនៅរយៈពេលណាដែរ ប្រហាក់ប្រហែលលោក?

**ឆ៖** ប្រហាក់ប្រហែលជាចុង១៩៧៦ ខ្ញុំគ្រប់គ្រងរយៈកាលប្រហែលជាបាន២ឆ្នាំទេ រយៈពេល។

**សៈ** បាទ សូមអរគុណ។ ទាក់ទងទៅនឹងទាហានដែលបញ្ជូនទៅអូរកន្សែង តើអ្នកណាជាអ្នកបញ្ជូនទាហានទាំងអស់នេះទៅមន្ទីរលោកនោះ? តើមន្ទីររបស់លោកហ្នឹងមានសិទ្ធិអំណាចចាប់មនុស្សដែរឬទេ? ឬក៏គេសម្រេចចិត្តនៅថ្នាក់ភូមិភាគទេ ហើយគេចាប់មនុស្សហើយ បានគេបញ្ជូនមកមន្ទីរលោក?

**ឆ៖** រឿងដែលចាប់បញ្ជូនពីមន្ទីរមកមន្ទីរខ្ញុំនេះបាទ តាមអង្គភាពវរសេនាធំ។ លើសេចក្ដីសម្រេចចិត្តរបស់ប្រធានកងពល របាយការណ៍មើលទៅវាមិនប្រក្រតី មើលទៅវាហេតុផលយ៉ាងម៉េចគេធ្វើរបាយការណ៍ហ្នឹងមក គេបញ្ជូនតាមមុខព្រួញមួយៗយកមក មួយកងៗ បីនាក់ពីរនាក់ៗ ចេះតែយកមកបន្តបន្ទាប់មក ឲ្យមកនៅកន្លែងកែប្រែនេះ។

[១៥:០៩:០៨]

**សៈ** បាទ សូមអរគុណ។ តើដល់ -- តើទាហានដែលគេបញ្ជូនមកលោកហ្នឹងនោះ មានអស់ធំបំផុតដល់ស័ក្ដិប៉ុន្មាន? តើហើយគឺថាមានស័ក្ដិដែលខ្ពស់ជាងបំផុតនោះ ដែលអត់ -- លោកអត់ដែលបានទទួលនោះ អ៊ីចឹងលោកមានឃើញថាមានការបែងចែកទេ ព្រោះថាស័ក្ដិតូចតាចហ្នឹងគេបញ្ជូនទៅមន្ទីរអូរកន្សែងរបស់លោក ហើយដល់ស័ក្ដិធំពេកទៅគេអត់មានបញ្ជូនទៅទេ លោកអាចប្រាប់ ជម្រាបជូន

តុលាការបានទេ?

**ឆ៖** បាទជម្រាបជូនបាន។ បាទ ទី១ វាសិទ្ធិនិងសមត្ថភាពផ្ទាល់ខ្លួនខ្ញុំបាទ។ វាស្មើនឹងអនុសេនីយ៍ អ៊ំន៎! នឹងអនុសេនីយ៍ទោ ឬអនុសេនីយ៍ត្រី។ ដូច្នេះអនុសេនីយ៍ឯក ឡើងទៅដល់វរសេនីយ៍ឯក មិនសូវមានសិទ្ធិបញ្ជូនមកកន្លែងខ្ញុំបាទទេ បាទ អាហ្នឹងនិយាយពីសិទ្ធិ។ ប៉ុន្តែនិយាយពីកិច្ចការងារ ផ្ទៃក្នុងវិញណ៎ះ! ពួកឡើងទៅលើអស់នោះ គេសុទ្ធតែសាខារបស់បក្សបាទ ឬអនុសាខាបក្ស មិនមែនជាសម្ព័ន្ធទេបាទ។ សម្ព័ន្ធវាជាកម្លាំង ឯបក្សជាអ្នកផ្ដើមគំនិត និងជាអ្នកដាក់ធ្វើ ដូច្នេះវាមានសិទ្ធិ កម្រិតទាបអ៊ីចេះ បើនិយាយពីផ្ទៃក្នុង ទាបខ្ពស់អ៊ីចឹងឯងបាទ។

**ស៖** តើលោកបាន -- កាលសម័យនោះលោកបានទទួលព័ត៌មានទាក់ទងទៅនឹងកន្លែងដែលអ្នកស័ក្តិធំៗនោះបញ្ជូនទៅហៅថា ក្រៅពីមន្ទីររបស់លោក តើលោកធ្លាប់បានដឹងដំណឹងអំពីកន្លែងដែលគេបញ្ជូនអ្នកធំៗបំផុតនុ៎ង ដូចជាអ្នកស័ក្តិ៤ ស័ក្តិ៥ អ៊ីចឹងបញ្ជូនទៅដល់ណាទៅ? ហើយបើសិន អង្កាល់នុ៎ង បើសិនជាមានអ្នកស័ក្តិធំៗហ្នឹងត្រូវបានគេចាប់ខ្លួននោះ គេបញ្ជូនពួកគាត់ទៅណាដែរ តើលោកដឹងទេ មានបានដឹងទទួលព័ត៌មានបែបហ្នឹងទេ?

[១៥:១១:២០]

**ឆ៖** បាទ ដឹង គឺមកតែទីក្រុងភ្នំពេញហ្នឹងតែម្ដង អត់មានទៅមណ្ឌលណាផ្សេងៗទៀតទេ។ ត្រង់មកវិញ ឬត្រឡប់វិញ ឬក៏បាត់មុខតែម្ដង ដឹងតែមកសិក្សាមក មករៀនតែម្ដង។ អ្នកខ្លះមកតាមរយៈយន្តហោះអ៊ីចឹងទៅ អ្នកខ្លះមកតាមឡានអ៊ីចឹងទៅបាទ តាមតែដំណើរអាចធ្វើមកបាន។ ព្រោះកាលនោះសម័យនោះវាមិនសូវមានយានជំនិះប្រើជាប្រក្រតីទេ វាខ្វះខាងយានជំនិះគ្រប់បែបយ៉ាងច្រើនដែរ។

**ស៖** បាទ សូមអរគុណ។ តើលោកដឹងឮព័ត៌មានបែបហ្នឹង តាមរបៀបណា? តើនៅក្នុងកងពល ៨០១នោះគេមាននិយាយពីរឿងហ្នឹង ឬក៏លោកធ្លាប់ឮនៅពេលដែលប្រជុំណាមួយ ឬក៏ ស៊ូ សារឿន ហ្នឹងធ្លាប់បាននិយាយអំពីរឿងចាប់បញ្ជូនមនុស្សមកភ្នំពេញហ្នឹង?

[១៥:១២:២១]

**ឆ៖** រឿងអ្វីៗគេមិនអាចប្រាប់យើងទេ ប៉ុន្តែរឿងអស់នេះវាមិនអាចលាក់ជិតទេ តាមអង្គភាពមួយៗនោះ វាតែងតែមានកាលៈទេសៈខ្លះពេលវេលាខ្លះទៅសិក្សាក្នុងសាលានយោបាយដូចគ្នា វាតែងតែប្រាប់ ផ្ដល់ព័ត៌មាន បាត់អ្នកនេះ បាត់អ្នកនោះអ៊ីចឹងជាបន្តបន្ទាប់ដែរបាទ។

*(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

បាទ បានហើយសាក្សី!

**លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល៖**

បាទ សូមអរគុណ។ បាទ ឥឡូវយើងនឹងកំណត់បរិបទសន្តិសុខនៅក្នុងភូមិភាគព្ញៀសាននៅពេលដែល បង្កើតមន្ទីរហ្នឹង ហើយនិងរយៈពេលដែលគេបង្កើតមន្ទីរហ្នឹង ហើយដើម្បីធ្វើរឿងនេះនិយាយ អំពីបញ្ហានេះ ខ្ញុំសូមបញ្ចាំងឯកសារមួយ ឯកសារ E3/1164។ នេះគឺជារបាយការណ៍ដែលបញ្ជូននៅថ្ងៃទី២៥ វិច្ឆិកា ឆ្នាំ១៩៧៦ ដោយ រឿន ដែលជាលេខាភូមិភាគ -- កងពល៨០១។ បាទ ខ្ញុំសូមអានផ្នែកបី នៃឯកសារនេះលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អនុញ្ញាត!

[១៥:១៤:១៧]

**សួរដោយលោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល៖**

**ស៖** ផ្នែកទី១ គឺថានៅចំណងជើងទី២ គឺថានៅទំព័រទី២ ជាភាសាខ្មែរគឺ 0052325 -- បាទ ខ្ញុំច្រឡំទេ គឺថាទំព័រទី៣ នៅក្នុងឯកសារទាំងបីភាសាហ្នឹងណា៎ះ គឺថា និយាយពីខ្មាំង ហើយនិងបណ្ដាញខ្មាំងនៅក្នុងកងពល៨០១ ជាពិសេសអំពីកងវរសេនាធំ៨៣។ នៅទំព័រទី៣ មានរៀបរាប់ដូចតទៅនេះ៖ ខ្ញុំសូមដកស្រង់ "ព័ត៌មានទាំងអស់នេះចេញមកពីចម្លើយសារភាពរបស់កងទ័ពដែលយើងបានចាប់នៅក្នុងកងវរសេនាធំ៨៣" បាទ សូមបញ្ចប់ការដកស្រង់។ ផ្នែកទី២ គឺនៅចំណងជើងលេខ៤ នៃឯកសារដដែលនេះមានឈ្មោះថា "វិធានការមួយចំនួនចំពោះមុខ"។ ជាភាសាខ្មែរគឺ 00052327, ជាភាសាបារាំងគឺថា 00532754, ជាភាសាអង់គ្លេសគឺ 00516711។ មានវិធាន៥ ដែលបានដាក់ដោយ រឿន។

[១៥:១៥:៥៨]

"វិធានការទី១ គឺថាអ្នកដែលគេសង្ស័យថាជាខ្មាំង ត្រូវតែចាប់ខ្លួន។ ចំពោះអ្នកដែលគេឆ្លើយដាក់ដោយ ខ្មាំង បន្ទាប់ពីបានពិនិត្យឯកសារ ហើយស្នើចាប់ខ្លួនជាបណ្ដោះអាសន្ន, ទី៣ អ្នកសេរីដើរហើរ ឬក៏ល្មើសវិន័យអប់រំ ហើយមិនស្ដាប់ ត្រូវមានវិធានការដកទុកមួយដុំ តាមដាន។ វិធានការទី៤ កម្មាភិបាល អនុសេនាធំ អនុសេនាតូចមិនសកម្ម ពុតត្បុតខ្ជិល ត្រូវដកចេញដាច់ខាត។ វិធានការទី៥ អ្នកមាននិន្នាការពាក់ព័ន្ធផ្នែកនយោបាយ គឺត្រូវដកជាបណ្ដើរៗ។ បន្ទាប់មកទៀតអ្នកដែលល្អត្រូវទុកសិន

ហើយអ្នកណាប្រឆាំង ហើយមិនសកម្មដកដាក់មួយដុំសិន។ បូកសរុប បើអ្នកណាល្មើសវិន័យ អប់រំមិនស្តាប់បីបួនដង ត្រូវចាប់ ឬក៏ដកចេញពីអង្គភាព”។ បាទ សូមចប់ការដកស្រង់លោកប្រធាន។

[១៥:១៧:៣២]

ហើយទំនាក់ទំនងរវាង រឿន ហើយនិង បង -- អ៊ំ៨៩ នេះដូចតទៅនេះ គឺថានៅទំព័រចុងក្រោយ គឺជាកថាខណ្ឌចុងក្រោយ គឺថានេះជា “សេចក្តីរាយការណ៍របស់គណៈកម្មាធិការ ៨០១ ចំពោះសកម្មភាពខ្មាំង និងវិធានការដូចខាងលើ ស្នើអ៊ំមានមតិ និងជួយយោបល់។ យើងខ្ញុំរង់ចាំមតិណែនាំរបស់បក្ស”។ បាទ សូមបញ្ចប់ការដកស្រង់។

សំណួរទី១ របស់ខ្ញុំទាក់ទងនឹងសម្រង់នេះ ដែលយើងនិយាយអំពីការសារភាពរបស់ទាហាននៅក្នុងកងវរសេនាធំ៨៣។ លោកសាក្សី គឺថារបាយការណ៍នេះចុះថ្ងៃទី២៥ វិច្ឆិកា ឆ្នាំ១៩៧៦។ បាទ ខ្ញុំចង់ដឹងថាចម្លើយសារភាពយោធាក្នុងកងវរសេនាធំ៨៣ នៅទីនេះ ត្រូវបានទទួលនៅក្នុងមន្ទីរអប់រំកន្សែងហ្នឹង ឬក៏នៅឯណាផ្សេង?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល់ទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី!

[១៥:១៨:៥១]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំយល់មិនបានច្បាស់ទេ ថាតើការតាំងសំណួរនេះវាស្ថិតនៅក្នុងវិសាលភាព ដែលអង្គជំនុំជម្រះបានកំណត់ឡើង ឬយ៉ាងណានោះទេ ទាក់ទងទៅនឹងមន្ទីរសន្តិសុខនោះ។ ដូច្នេះ ខ្ញុំសូមជំទាស់ចំពោះការតាំងសំណួរបែបនេះ វាមិនស្ថិតនៅក្នុងវិសាលភាពនៃការកំណត់ឡើងដោយអង្គជំនុំជម្រះនោះទេ។

**លោក វ៉ាំងសង់ វ៉ាយដ៏ ដេស្នាឯល៖**

លោកប្រធាន ទាក់ទងទៅនឹងមន្ទីរអប់រំអប់រំកន្សែង យើងនឹងមិននិយាយលាតសន្ធឹងទាក់ទងទៅដល់លក្ខខណ្ឌឃុំឃាំងនោះទេ។ យើងនៅតែក្នុងក្របខ័ណ្ឌជំនុំជម្រះយើងនេះទេ។ ក៏ប៉ុន្តែយើងចង់ដឹងថាក្នុងឋានៈជាអង្គភាពមួយដែលនៅក្នុងកងពល៨០១ តើអង្គភាពនេះមានឋានៈជាអ្វី? ហើយនិងទាក់ទងនឹងវិធានការទំនាក់ទំនងរវាងមន្ទីរនេះ ហើយនិងថ្នាក់លើ។ ហើយចំណុចមួយទៀត យើងចង់ដឹងអំពីនយោបាយទាក់ទងទៅនឹងខ្មាំងនៅពេលនោះ ហើយយើងចង់ដឹងថាតើអ្នកណាមានសិទ្ធិអំណាចក្នុងការ

សម្រេចលើជោគវាសនាខ្មាំង? តើត្រូវដោះលែង ឬក៏ត្រូវប្រហារជីវិត ឬក៏ត្រូវដាក់គុកជាដើម? អ៊ីចឹង តើនៅក្នុងកងពល៨០១ នោះតើអ្នកណាមានសិទ្ធិអំណាចរាយការណ៍មកភ្នំពេញ? អ៊ីចឹងទំនាក់ទំនង -- បញ្ហាទាំងអស់នេះ ខ្ញុំគិតថាសាក្សីនេះវាអាចឆ្លើយបាន។ ហើយមានព័ត៌មានមួយចំនួនដែលគាត់អាចប្រាប់យើងដោយសារ គាត់ជាប្រធានមន្ទីរអប់រំកែប្រែនេះ ហើយគាត់ក៏បានសិក្សាអំពី -- គាត់ដឹងអំពីចម្លើយសារភាពរបស់អ្នកទោសនៅទីនោះ។ អ៊ីចឹងបានខ្ញុំសុំឲ្យគាត់ឆ្លើយតបទៅនឹងសំណួរទី១របស់ខ្ញុំ។

[១៥:២១:០៦]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:២១:៤៣]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់របស់មេធាវីអន្តរជាតិការពារក្តីលោកនួន ជា ជំទាស់ក្នុងការតាំងសំណួរនេះមិនសមស្របទេ។ ពីព្រោះសំណួរនេះមិនមានការពាក់ព័ន្ធស៊ីជម្រៅទៅរចនាសម្ព័ន្ធ ឬក៏សកម្មភាពនៃដំណើរការប្រព្រឹត្តទៅរបស់មន្ទីរអប់រំកែប្រែអូរកន្សែងទេ គ្រាន់តែជាផ្នែកមួយនៃរចនាសម្ព័ន្ធយោធាប៉ុណ្ណោះ។ អង្គជំនុំជម្រះអនុញ្ញាតឲ្យសាក្សីឆ្លើយតបទៅនឹងសំណួរដែលសួរឡើងដោយតំណាងសហព្រះរាជអាជ្ញាចុងក្រោយអម្បាញ់មិញនេះ ប្រសិនបើលោកនៅចងចាំនូវសំណួរដែលសួរ។

**លោក ឆោម សែ៖**

**ឆ៖** ខ្ញុំបាទអត់មានចម្លើយនឹងការឆ្លើយទេទានបាទ ព្រោះរឿងនេះគាត់រៀបរាប់នេះអំពីបញ្ហាដំណើរអ៊ីចេះវាស្រប។ ប៉ុន្តែរឿងមកដល់ដំណើរការក្នុងអង្គភាពដែលយើងខ្ញុំគ្រប់គ្រងដំណើរការផ្សេងៗនេះ ខ្ញុំបាទអត់បានដឹងសាច់រឿងដែលគាត់បានចង់ដឹងនោះទេបាទ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** បាទ សូមអរគុណ។ នៅក្នុងវិធានការទាំង៥ ដែលគណៈ -- ដែល វឿន ស្នើនោះ ស្នើទៅបង៨៩ នោះ ខ្ញុំសូម "ថាអ្នកដែលសង្ស័យថាជាខ្មាំងនោះត្រូវចាប់ខ្លួន ហើយអ្នកដែលគេខ្មាំងឆ្លើយដាក់នោះត្រូវចាប់ដែរ ហើយត្រូវពិនិត្យឯកសារ។ ហើយយើងនិយាយអំពីការចាប់ខ្លួនអ្នកដែលមិនគោរពវិន័យ ហើយតាមដានពួកទាំងអស់នុ៎ង។ ហើយយើងក៏បញ្ជាក់ផងដែរ គឺថានៅ-- ថាកម្មាភិបាល អនុសេនាធំ ហើយនិងអនុសេនាតូចដែលមិនសកម្ម ពុតត្បុត ខ្ជិលអីហ្នឹងក៏ត្រូវដកចេញដាច់ខាត។ ហើយ

អ្នកមាននិន្នាការពាក់ព័ន្ធផ្នែកនយោបាយនោះក៏ត្រូវដកបណ្ដើរៗ”។ តើនៅក្នុងកងពល៨០១នេះ វិធានការទាំង៥នេះត្រូវបានផ្ញើទៅដល់កម្មាភិបាលនៃកងពល៨០១នេះ ដែរឬទេ? ហើយវិធានការទាំង៥នេះត្រូវបានអនុវត្តដែរឬទេ?

[១៥:២៤:០៦]

**ឆ៖** បាទ ចង់ដឹងវិធានការទាំង៥ នេះតាមដែលមតិលើកឡើងនេះ ខ្ញុំបាទស្របតាមអង្គភាព តែក្នុងក្រសួងខ្ញុំបាទអត់មានបានអនុវត្តអ៊ីចឹងទេគោលការណ៍ទាំង៥នេះ។ នេះសម្រាប់តែអង្គភាព ដើម្បីពិនិត្យកម្លាំងដែលខ្លួនគ្រប់គ្រងនៅតាមអង្គភាព។

**ស៖** ក្នុងឋានៈជាប្រធានមន្ទីរអប់រំកែប្រែអ្នករកន្សែង ការបញ្ជាទៅលោកទាក់ទងទៅនឹងទាហាននៅក្នុងកងពល៨០១នេះ តើទាហានទាំងអស់នេះហ្នឹងមានធ្លាប់ថាជាមនុស្សដែលមិនគោរពវិន័យ ឬក៏ដែរជាខ្មាំងដែរឬទេ?

**ឆ៖** បាទ ខ្ញុំស្ដាប់មិនបានទេកិច្ចការងារនេះ ព្រោះខ្ញុំអត់មានសិទ្ធិអីបញ្ជាទេ។ សិទ្ធិរង់ចាំតែទទួលសកម្មជនដែលគេថា វាមិនប្រក្រតីយកមកសិក្សា ឬអប់រំកែប្រែប្រគល់ជូនតែប៉ុណ្ណឹងទេបាទ។

**ស៖** បាទសូមអរគុណ។ ឥឡូវខ្ញុំចូលមកប្រធានបទនិយាយពីទំនាក់ទំនងនៅរវាងមន្ទីរអ្នករកន្សែងហើយនិងកងពល៨០១។ ក្នុងឋានៈជាប្រធានមន្ទីរនេះ តើលោកធ្វើ -- រាយការណ៍ទៅអ្នកណានៅក្នុងកងពល៨០១ នេះ?

**ឆ៖** បាទ រាយការណ៍វាមានលក្ខណៈច្រើនបែបដែរកន្លងទៅ ទាំងផ្នែកសេដ្ឋកិច្ច ទាំងផ្នែកស្អីគ្រប់សព្វបែបសព្វយ៉ាងពីមុនដំបូងនោះ ០៦ នេះគេមកគ្រប់គ្រង។ ៨០៦ទុំះ! បាទប្រធានជុំវិញក្រសួងមន្ទីរនោះ។ ០៦នេះ ៨០៦នេះ វាជាកងដឹកជញ្ជូន ប៉ុន្តែវាជាមេបញ្ជាការមួយអាចរត់ការ និយាយរួមជារត់ការគ្រប់គ្រងខាងរដ្ឋ អាផ្លូវចាត់តាំងនេះ។ ប៉ុន្តែក្រោយៗបន្តបន្ទាប់មករឿងវាដែលវាសំខាន់ៗអីផ្ទាល់ៗហ្នឹងមក គាត់មិនឲ្យទេ ព្រោះវាពាក់ព័ន្ធអារឿងនយោបាយ ទាល់តែឡើងដល់ប្រធានកងពលតែម្ដង។ បាទ រង់ចាំទទួលរបាយការណ៍នេះ។ បាទ រឿងកិច្ចការងារខ្ញុំបាទ។

[១៥:២៦:៤៣]

**ស៖** នៅពេលដែលលោកនិយាយអំពី ០៦ នោះ លោកសំដៅទៅលើបុគ្គលណាម្នាក់ជាក់លាក់ ឬក៏លោកសំដៅទៅលើអង្គភាព៨០៦។ ខ្ញុំយល់មិនច្បាស់ទេលោក លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ បញ្ជាក់ជូនបាន។ ចំពោះ៨០៦ ហ្នឹងវាមានវរសេនាតូចហ្នឹងវាមានប្រធានវាបីនាក់

ប៉ុន្តែវានៅជុំវិញក្នុងមន្ទីររបស់៨១១ នេះ។ ដូច្នេះ កិច្ចការងារខាងរដ្ឋបាលដែលវាមិនស៊ីជម្រៅនៃការងារនយោបាយ ពួកនេះវារត់ការ មេបញ្ហាការនេះវារត់ការមកខាងក្រុមដឹកនាំរបស់ការងារយើងខ្ញុំនេះ។ បាទ ជាផ្នែកអីៗ ឬចាត់តាំងអីៗធ្វើជាធម្មតា ប៉ុន្តែរបាយការណ៍ផ្ទៃក្នុងដែលស៊ីជម្រៅនៃខ្សែប្រព័ន្ធការពាររបស់សត្រូវផ្សេងៗដែលនៅក្នុងជួរបានសួរចម្លើយអ្នកដែលពាក់ព័ន្ធពីតាមអង្គភាពប្រគល់មកជូន នេះវាឡើងដល់ទីបញ្ជាការតែម្តង។ បាទ វាមានផ្លូវការអ៊ីចឹង។ វាអត់មានចម្លងមកឲ្យខាងជំនាញគ្រប់គ្រងវរសេនាតូចនេះទេ។

[១៥:២៨:០០]

**ស៖** បាទសូមអរគុណ។ ទាក់ទងទៅនឹងរបាយការណ៍ដែលលោកបញ្ជូនទៅហ្នឹង របាយការណ៍ចម្លើយសារភាព តើលោកបញ្ជូនរបាយការណ៍សារភាពចេញពីមន្ទីរលោកនុំងទៅប្រធានកងពល ស៊ូ សារឿន ហ្នឹងប៉ុន្មានដងដែរក្នុង១ខែ?

**ឆ៖** បាទ ដូចជាចាំៗមិនគ្រប់គ្រាន់ទេ។ ពេលវេលាវាដាច់ឆ្ងាយពេក ដោយហេតុការងារណាដែលចាំបាច់ ការងារណាដែលសកម្ម ការងារណាដែលវាប្រួសរាន់វាអាចមានច្រើន។ ជាបន្ទាប់ដើម្បីចង់ដឹងសាច់រឿងមួយខ្សែៗដែលវាពាក់ព័ន្ធក្នុងការងារនយោបាយនេះ។

**ស៖** បាទ សូមអរគុណ។ លោកអាចនិយាយឲ្យបានលម្អិតបានដែរឬទេ អំពីខ្លឹមសាររបាយ-ការណ៍នៃចម្លើយសារភាពនេះ តើគោលបំណងនៃការបញ្ជូនចម្លើយសារភាពទាំងអស់នេះទៅប្រធានកងពលនោះ មានប្រយោជន៍អ្វីចំពោះប្រធានកងពលហ្នឹង?

[១៥:២៩:១៤]

**ឆ៖** អានេះចង់ឲ្យគាត់ធ្វើសេចក្តីសម្រេចចិត្ត តើវាប្រភេទជម្រៅនៃទំនាស់ ឬក៏វាពាក់ព័ន្ធផ្នែកខាងនយោបាយវាចូលដល់កម្រិតណា រឿងរវាងសត្រូវនិងមិត្ត បាទ បុគ្គលនេះ។ អនុវត្តនេះវាទៅជាខ្សែប្រព័ន្ធរបស់ខ្មាំងចាត់តាំង ឬគ្រាន់តែខ្មាំងបញ្ហា ឬគ្រាន់តែដោយរោយតាមគេ ដែលជម្រៅក្របខ័ណ្ឌនោះនឹងត្រូវចាប់ ឬក៏ត្រូវមានវិន័យឲ្យកាន់តែជ្រាលជ្រៅណ៎ះ! ឬក៏ត្រូវបន្ថយសម្រាប់បុគ្គលនោះវិញនៃរបាយការណ៍នេះ ឲ្យគាត់វិនិច្ឆ័យ។

**ស៖** រាប់ឲ្យច្បាស់ជាងនេះទៅទៀតនោះ គឺថាតើ ស៊ូ សារឿន ហ្នឹងធ្វើសេចក្តីសម្រេចប្រភេទណា? គាត់សម្រេចថាត្រូវចោទសួរអ្នកទាំងអស់ហ្នឹងថែមទៀត ឬក៏គាត់សម្រេចប្រហារជីវិតអ្នកទោសទាំងអស់ហ្នឹងតែម្តង?

**ឆ៖** រឿងនេះពិបាកសន្និដ្ឋាន ហើយនិយាយឲ្យពេញលក្ខណៈដែរ ព្រោះការប្រហារជីវិតខាងយើងខ្ញុំមិនទាន់ដែលបានទទួលថា អាជ្ញាបញ្ជាឲ្យប្រហារជីវិតទេ។ ព្រោះហេតុផលនេះវាមិនជម្រៅទៅជាការប្រព្រឹត្តរបស់បុគ្គលនោះវាមិនទៅចូលជាភាពឧក្រិដ្ឋទេ។ បាទ រឿងទំនាស់អស់នោះ វាគ្រាន់តែដោយរោយ ឬពាក់ព័ន្ធ ឬគេយកឈ្មោះខ្លួនអ្នកនេះមកតាំងថាជាកម្លាំងរបស់ខ្លួនតែប៉ុណ្ណោះឯង វាមិនចូលដល់ឧក្រិដ្ឋទេ។ បាទ បានថារឿងនេះវាមិនអាចបន្ទាន់ ឬក៏បញ្ជាឲ្យវិនិច្ឆ័យបានទេ ព្រោះទង្វើរបស់អ្នកនេះ ដែលវាអត់ធ្វើទៅវាអត់មានឃើញរូបភាពអីដែលវាធ្ងន់ធ្ងរ។ បាទ ហើយអ្នកនោះចេះតែបញ្ជូនមក មកកាន់តែច្រើនឡើង ច្រើនឡើងបន្តៗយូរៗទៅវាអត់ទ័ពច្បាំង។ អ៊ីចឹងក៏បើកមានការសិក្សារៀនសូត្រទៅ វាគប់គ្នាទៅវិញទៅមកក្នុងការដែលគ្រប់គ្រង ដល់អ៊ីចឹងទៅវាចេះតែមានបញ្ហាលម្អៀង។ បាទ អានេះខ្ញុំគ្រាន់តែវាយជូនប៉ុណ្ណឹងទេ វាអត់មានបញ្ជាមកឲ្យភ្លាមថាស្លាប់ទៅអារឿងនេះ វាត្រូវអ្វែងសម្លាប់ចោលទៅ វាទោសក្បត់ជាតិ ក្បត់អី អត់មានទេ មានតែអប់រំថែម ហើយពិនិត្យតាមដានតទៅមើល តើវាពិតមិនពិត វាជាក់ស្ដែងមិនជាក់ស្ដែងតែប៉ុណ្ណឹងទេបាទ។

[១៥:៣១:៥២]

**ស៖** បាទ សូមអរគុណ។ ខ្ញុំត្រឡប់និយាយពីចំណុចនេះពេលក្រោយទៀត។ លោកនិយាយនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយលើកទី១ របស់លោកចំពោះមុខសហចៅក្រមស៊ើបអង្កេត គឺថាឯកសារ E3/405 នៅសំណួរទី៨ ចម្លើយទី៨នេះ។ នៅក្នុងចំណោមកំហុសរបស់អ្នកឃោផាមានកំហុសនោះ គឺថាមាន -- លោកឆ្លើយនៅក្នុងចម្លើយ "មាននៅក្នុងចម្លើយសារភាពរបស់គាត់ ហើយនិងមានចម្លើយសារភាពដែលធ្វើនៅភ្នំពេញផងដែរ"។ បាទសូមដកស្រង់។ អ៊ីចឹងលោកបែងចែកថាមាន អ្នកដែលគេឆ្លើយដាក់នៅក្នុងចម្លើយសារភាពនៅក្នុងមន្ទីររបស់លោក ហើយអ្នកខ្លះត្រូវបានគេឆ្លើយដាក់នៅចម្លើយសារភាពរបស់អ្នកទោសនៅភ្នំពេញផងដែរ។ តើលោក -- ចម្លើយសារភាពដែលយកបានពីភ្នំពេញនោះគេបញ្ជូនទៅឲ្យលោកតាមរបៀបណា? តើមានមធ្យោបាយផ្សេងៗ ដែលគេបញ្ជូនចម្លើយសារភាពដែលគេទទួលបានពីទីក្រុងភ្នំពេញទៅកាន់លោកដែរឬទេ? បាទ ខ្ញុំសូមបញ្ជាក់ គឺថាបើចម្លើយសារភាពដែលទទួលបាននៅភ្នំពេញ ចង់ដឹងថាតើលោកទទួលចម្លើយសារភាពរបស់អ្នកទោសនៅភ្នំពេញនេះតាមរបៀបណា?

[១៥:៣៣:៣១]

**ឆ៖** នេះខ្ញុំបាទទទួលតាមរយៈ ជួនកាលវាមានសារ សាររបស់កន្លែងបញ្ជារបស់០៥នេះមក។

បាទ ឈ្មោះនេះៗៗអ៊ីចឹងទៅ ពាក់ព័ន្ធនឹង អា"ក" នេះ ឬក៏ អា"ខ" នេះដែលវាមានចម្លើយជាប់មក។ ប៉ុន្តែមួយទៀត មានកន្លែងសេនាធិការភ្នំពេញនេះ ឈ្មោះ ណូ នេះបានមកជាក់ស្ដែងដែរ មកស៊ើបសួរអាដែលត្រូវពាក់ព័ន្ធស៊ីជម្រៅនៅក្នុងអង្គភាព៨០១ ហ្នឹង។ គាត់មកមួយរយៈកាលខ្លីដែរ ចូលមកពិនិត្យក្នុងកន្លែងការងាររបស់ខ្ញុំបាទ។

**ស៖** បាទ សូមអរគុណ។ សូមបំភ្លឺ ចម្លើយភាគច្រើនត្រូវទទួលបានតាមរយៈមន្ទីរ០៥។ ខ្ញុំចង់សួរ -- តើលោកអាចបញ្ជាក់បានទេ ថា០៥ នេះគឺជាឈ្មោះកូដរបស់ តាសារឿន ឬក៏ជាឈ្មោះកូដរបស់អ្នកផ្សេងទៀត?

**ឆ៖** ជាឈ្មោះកូដរបស់ សួរ សារឿន ហ្នឹង។

[១៥:៣៥:០៥]

**ស៖** តើនីរសារ តាសារឿន ធ្លុំងធ្លាប់ផ្ដល់ចម្លើយសារភាពហ្នឹងដល់លោកទេ មកដោយផ្ទាល់ដៃនោះ? ឬក៏លោកទទួលចម្លើយសារភាពនេះតាមរបៀបផ្សេង? អ៊ីចឹងសូមឲ្យបញ្ជាក់កន្លែងនេះឲ្យច្បាស់ នីរសារគាត់យកមកផ្ទាល់ដៃឲ្យលោក ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ មានពេលខ្លះក៏យកមកឲ្យផ្ទាល់ដៃ ប៉ុន្តែតែពេលខ្លះហ្នឹងហៅទៅជួប ទៅទីកន្លែងរបស់គាត់តែម្ដង។

**ស៖** តើមានចម្លើយសារភាពដែលទទួលបាននៅទីក្រុងទីភ្នំពេញនេះដែលលោកដឹង ដោយសារតែមានមនុស្សដែលមកចូលនៅក្នុងមន្ទីររបស់លោកយកមក។ តើអ៊ីចឹងទេ?

**ឆ៖** បាទ។

**ស៖** តើ ស៊ូ សារឿន នោះទទួលចម្លើយសារភាពហ្នឹងតាមរបៀបណាដែរ? ទទួលពីទីក្រុងភ្នំពេញនោះ តើលោកមានព័ត៌មានណាដែរឬទេទាក់ទងទៅនឹងការទទួលចម្លើយសារភាពពីទីក្រុងភ្នំពេញនេះ?

[១៥:៣៦:៤៣]

**ឆ៖** បាទ គាត់មានវិទ្យុទាក់ទងគាត់គ្រប់ប្រភេទ។

**ស៖** សូមអរគុណ។ លោកនិយាយអំពីឈ្មោះ ណូ ដែលមកពីសេនាធិការ ដើម្បីឲ្យបានច្បាស់នោះថាតើបុគ្គលនុ៎ងជាអ្នកនាំចម្លើយសារភាពមកពីភ្នំពេញមែនទេ?

**ឆ៖** បាទ គាត់មានឯកសារពីនោះមក ពីព្រោះគាត់តាមដានការងារហ្នឹងដែរ ដែលមានពាក់ព័ន្ធមកក្នុងអង្គភាពនេះគាត់ចុះមកក្នុងមួយរយៈកាល។

**ស៖** តើចម្លើយសារភាពដែលលោកបានឃើញ ដែលផ្ញើមកពីភ្នំពេញនោះចេញមកពីយោធាកងពល៨០១ ឬក៏កម្មាភិបាលតំបន់ -- ភូមិភាគឦសាន?

**ឆ៖** វាចេញតែមកពី៨០១ ព្រោះកងពលវាបញ្ជាការដែលត្រូវដកហូតចេញខ្លះ ដែលទៅបន្តបន្ទាប់ហ្នឹង។

**ស៖** តើលោកចាំឈ្មោះរបស់បុគ្គលមួយចំនួន ឬក៏មុខងាររបស់អ្នកទាំងអស់នោះនៅពេលដែលមានចម្លើយសារភាពមកពីភ្នំពេញនោះ?

**ឆ៖** បាទ មិនបានចាំ ភ្លេចភ្លាំងអស់ ពេលវេលាវាឆ្ងាយពេក។

[១៥:៣៨:៥៩]

**ស៖** តើ ស៊ូ សារឿន មានផ្តល់សេចក្តីណែនាំជាក់លាក់ឲ្យលោកពាក់ព័ន្ធនឹងការឆ្លើយដាក់នៅក្នុងចម្លើយសារភាពដែលចេញមកពីភ្នំពេញដែរឬទេ? គឺថាមានន័យថា តើណែនាំថាមានលោកត្រូវធ្វើយ៉ាងម៉េចៗទេ នៅពេលដែលគេបញ្ជូនចម្លើយសារភាពមកនោះ?

**ឆ៖** បាទ គាត់ប្រាប់ដែរឲ្យយកចិត្តទុកដាក់ ហើយពិនិត្យតាមដានមើល តើហេតុការណ៍ហ្នឹងវាៗជ្រៅកម្រិតណា ហើយវាគ្រោះអាសន្នដល់កម្រិតណា។ បើវាសភាពធម្មតាទេ អាហ្នឹងពិនិត្យអប់រំវាទៅ តែបើវាខ្លាំងក្លាទេ វាមានខ្សែបណ្តាញវាច្រើនទៀត អាហ្នឹងយើងស្រាវជ្រាវថែមទៀត ចាំគាត់មានវិធានការទៅដល់អង្គភាពបាទ។

**ស៖** តើ តាសារឿន ឲ្យលោកតាមដានអ្នកដែលត្រូវបានឃុំខ្លួននៅក្នុងមន្ទីររបស់លោក ដោយសារតែអ្នកទាំងអស់នោះត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាពនៅទីក្រុងភ្នំពេញដែរឬទេ?

[១៥:៤០:០១]

**ឆ៖** មានពាក់ព័ន្ធខ្លះ ប៉ុន្តែខ្លះហ្នឹងវានឹងត្រូវស្រាល និងត្រូវដោះលែងវិញ តែវាមានឱកាសទៅជារត់ ទៅជាលួនព្រួយបារម្ភអីចឹងទៅ។ គេចាប់យកមកគេដាក់វិញដដែល។ ជាប់នឹងច្រវាក់វិញដដែលវាមិនព្រមលែង។

**ស៖** សូមអរគុណលោកសាក្សី។ លោកសាក្សី ខ្ញុំចង់សួរលោកថា តើលោកស្គាល់ឈ្មោះ កែវ សារឿន ហៅ សេង ដែរឬទេ? គឺ កែវ សារឿន ហៅ សេង នៅក្នុងកងពល៨០១?

**ឆ៖** ខ្ញុំស្គាល់តែ កែវ សារឿន ប៉ុន្តែហៅ សេង ខ្ញុំមិនដឹងគេប្រែឈ្មោះ ពីអង្កាល់ទេ។ ព្រោះ កែវ សារឿន ហ្នឹងប្រធាន៨១ វរសេនាធំ។ អាហ្នឹងបើថា កែវ សារឿន បាទ នៅប្រធាន៥១ អ៎! ៨១។

**ស៖** តើគាត់ស្ថិតនៅក្នុងគណៈកងពល៨០១ ក្នុងឋានៈជាមេបញ្ជាការវរសេនាធំ៨១ ដែរឬទេ?

**ឆ៖** ជាមេបញ្ជាការវរសេនាធំ៨១។

**ស៖** តើលោកដឹងទេថា មានរឿងអ្វីកើតឡើងចំពោះគាត់? គាត់នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនុំងពេញមួយពេលនុំងតែម្តង ឬក៏គាត់កាន់មុខងាររហូតដល់ឆ្នាំ៧៩ តែម្តង ឬក៏មានហេតុការណ៍អ្វីកើតឡើងចំពោះគាត់?

**ឆ៖** បាទ ក្រោយមកគាត់ចូលក្នុងគណៈកម្មាធិការ៨០១ ចុងក្រោយគេ បាទ។ បានមួយរយៈមកត្រូវគេហៅទៅសិក្សារៀនសូត្រមកភ្នំពេញទៀត ក៏បាត់មិនឃើញត្រឡប់ទៅវិញបាទ។

[១៥:៤២:៤៣]

**ស៖** នៅក្នុងកំណត់ហេតុទី៣ របស់លោកគឺថា លេខ E3/407 លោកបានបញ្ជាក់ថា កែវ សារឿន បានបាត់ខ្លួនក្នុងអំឡុងឆ្នាំ៧៧ នៅពេលដែលគេកោះហៅគាត់ទៅភ្នំពេញ។ តើលោកនៅរក្សាចម្លើយរបស់លោកថា ឆ្នាំ៧៧ នេះត្រូវបានគេចាប់ឈ្មោះ កែវ សារឿន នេះដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្ហាញជូនសាក្សី និងបង្ហាញឯកសារដែលមានលេខ E (សូមទោស) D108/26.86។ ម្តងទៀត D108/26.86 នេះគឺជាបញ្ជីអ្នកទោស ស-២១ ដែលមានចំណងជើងថា "ឈ្មោះអ្នកទោសកម្ទេចថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៧៧"។ នេះ គឺជាឈ្មោះមួយនៅក្នុងចំណោមឈ្មោះផ្សេងៗនៅក្នុងឯកសារនោះ។ ទំព័រដែលខ្ញុំចង់បង្ហាញជូននេះ គឺទំព័រជាភាសាខ្មែរ ERN 00009298, ERN ជាភាសាអង់គ្លេស 00873622 គឺទំព័រ៥០១។ ខ្ញុំសូមទាញចំណាប់អារម្មណ៍សាក្សីទៅលើលេខរៀង ១៨៣ ទៅដល់លេខរៀង ១៩១ នៃឯកសារដែលខ្ញុំចង់ផ្តល់ជូនទៅសាក្សីនេះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១៥:៤៤:៥៣]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ លោកសាក្សីគឺទំព័រទី២ ដែលខ្ញុំគូសជាពណ៌ខៀវ ដែលមានដាក់លេខ ចុះលេខរៀង ដើម្បីកុំឲ្យលោកច្រឡំជួរ។ ឯកសារនេះមិនមាន ERN ជាភាសាបារាំងទេ។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ថា

នៅលេខរៀង១៨៩ ដែលមានឈ្មោះ កែវ សារឿន ហៅ សេង សមាជិកកងពល៨០១ ចូល ស-២១ ខែឧសភា ឆ្នាំ១៩៧៧។ តើឈ្មោះហ្នឹងមែនទេ ដែលជាឈ្មោះដែលលោកបានលើកឡើងនោះ?

**ឆ៖** បាទ ឈ្មោះហ្នឹងពិតប្រាកដ។

[១៥:៤៥:៤៥]

**ស៖** នៅទំព័រដដែលនោះ គឺចន្លោះពីលេខរៀង១៨៣ទៅ១៩១ មានឈ្មោះកម្មាភិបាលមកពីកងពល៨០១។ តើក្នុងលេខរៀងនុ៎ង លោកមានស្គាល់ឈ្មោះអ្នកណាទេ លោកពិនិត្យមើលទៅមើល៍?

**ឆ៖** ឃើញ ប៉ោ សំអុន, ទូច ស៊ន។ បាទ ស្គាល់តែបីហ្នឹងទេតាមមើល និង កែវ សារឿន។

**ស៖** សូមអរគុណ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

ឥឡូវនេះលោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្ហាញឯកសារមួយទៀត ដែលនិយាយសំដៅទៅដល់ កែវ សារឿន។ គឺឯកសារ D267/2.2 បាទលេខឯកសារសូមម្តងទៀត D267/2.2 ឯកសារនេះជាចម្លើយសារភាពរបស់ កែវ សារឿន នៅមន្ទីរស-២១។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោកសាក្សីលោកបានឆ្លើយនៅក្នុងកំណត់ហេតុថា លោកបានឃើញចម្លើយសារភាពមួយចំនួនដែលមានចារ ដែលមានចំណារ។ ដូច្នេះខ្ញុំបង្ហាញឯកសារនេះជូនលោក គឺនៅទំព័រជាភាសាខ្មែរ 00414996, ជាភាសាអង់គ្លេស 00783155។ ខ្ញុំសូមឲ្យលោកមើលចំណារសរសេរដៃនៅក្នុងឯកសារនេះ។

ដូច្នេះខ្ញុំសុំការអនុញ្ញាតពីលោកប្រធាន ដើម្បីបញ្ចាំងឯកសារទំព័រនេះនៅលើអេក្រង់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១៥:៤៨:៣៣]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ខ្ញុំសូមអានចំណារសរសេរដៃរបស់ ឌុច "បងជាទីគោរព! ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ៧៧"។ ខ្ញុំសូមអានជាភាសាអង់គ្លេស ពីព្រោះចំណារសរសេរដៃហ្នឹងមិនមានជាភាសាបារាំងទេ។ ដូច្នេះសូមឲ្យអ្នកបកប្រែអនុវត្តទៅតាមនោះ។ ខ្ញុំសូមដកស្រង់ "នៅពេលសួរអំពីសភាពការណ៍កង អា កែវ

សារឿន វាវាយការណ៍មនុស្សនៅក្នុងខ្សែវាបង្កប់នៅ៨០១ ដល់ទៅ៥៨នាក់។ ក្នុងនោះមានឈ្មោះ ឆោម, ឡែម, ណាត, ថន, កែវ, ណារ៉ុង ហៅ បាវ ដែលដកឲ្យនៅមូលដ្ឋានវិញហើយ ជាដើម"។ លោកសាក្សីទោះបីជាចំណារនេះជាពណ៌ខ្មៅ មិនមែនជាពណ៌ក្រហមក៏ដោយ តើលោកស្គាល់អក្សររបស់អ្នកដែលសរសេរចំណារនេះដែរឬទេ?

**លោក ឆោម សែះ**

**ឆ៖** បាទ អក្សរអត់ស្គាល់ទេ ចំណាំមិនបាន។ តែបើឈ្មោះ ឆោម នេះប្រហែលជាស្គាល់តាមមើល ព្រោះត្រូវបញ្ជូនទៅដែរ ឆោម នេះទៅបាត់ហើយ។

**ស៖** ចុះតើឈ្មោះ ឆោម នុ៎ងមានមុខងារអ្វីដែរនៅក្នុងកងពល៨០១?

**ឆ៖** ជាវរសេនាតូច។

[១៥:៥១:០១]

**ស៖** តើ ឆោម នេះត្រូវបានឃុំនៅមន្ទីរអប់រំកែប្រែអ្នកទោសដែរឬទេ?

**ឆ៖** បាទ អត់ទេដូចឃើញបញ្ជូនទៅបាត់ហើយ អត់មានបាននៅទេ។

**ស៖** នៅពេលដែលលោកថាបញ្ជូនទៅបាត់នុ៎ង មានន័យថាបញ្ជូនទៅភ្នំពេញ ហើយតើគាត់បាត់ខ្លួនមែនទេ?

**ឆ៖** បាទ បញ្ជូនមកភ្នំពេញ គេថាមកភ្នំពេញៗហ្នឹង បាត់ទៅលែងឃើញទៅចូលទៅក្នុងកន្លែងមន្ទីរអប់រំនេះដែរ អត់ឃើញ។

**ស៖** នៅពេលដែលលោកស្តាប់ឈ្មោះមួយចំនួននោះ លោកលើកអំពី តាយ៉ា លេខាភូមិភាគ។ ឥឡូវលោកលើកឈ្មោះ ឆោម, កែវ សារឿន ជាដើម នៅពេលដែលគេកោះទៅ -- ហៅទៅភ្នំពេញ តើលោកធ្លាប់ទទួលបានព័ត៌មានពាក់ព័ន្ធនឹងអង្គភាពនៅភ្នំពេញដែលកោះហៅអ្នកទាំងអស់ហ្នឹងទៅទេ តើអង្គភាពណាជាអ្នកកោះហៅអ្នកទាំងអស់នោះទៅ?

**ឆ៖** ខ្ញុំបាទមិនសូវដឹងទេសាច់រឿងអស់នេះ វាអត់មានទៅជាខ្សែចរន្តចាត់តាំងអី តាមបណ្តាញអីផ្សេងៗ គេមិនប្រាប់ទេ។ គេទៅតាមអង្គភាព បទបញ្ជាពីកងពលគេទៅៗ យើងវាអស់សូវដឹងសាច់រឿងៗរបស់យើង។ រឿងរបស់គេ គេទៅអ៊ីចឹងទៅ ហេតុផល។

**ស៖** សូមអរគុណ។ ខ្ញុំមានសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងសេចក្តីណែនាំដែលលោកអាចទទួលបានក្នុងឋានៈលោកជាប្រធានអប់រំកែប្រែអ្នកទោស។ តើ ស៊ូ សារឿន មានធ្លាប់បញ្ជូនសេចក្តី

ណែនាំមកលោកពាក់ព័ន្ធនឹងការបែងចែកឲ្យបានច្បាស់រវាងអ្នកប្រព្រឹត្តកំហុសស្រាល ហើយនិងអ្នកដែលត្រូវតាមដានឲ្យបានជាប់ជាប្រចាំនោះ?

[១៥:៥៣:២១]

**ឆ៖** បាទ អាហ្នឹងគាត់បានបញ្ជូនតែឯកសារ រៀបរយ វាមាន៣សណ្ឋាននោះបាទ។ អាចដោះស្រាយ បន្ថយ បន្ធូរ ឬក៏កែប្រែ តាមកម្រិត។

**ស៖** សូមអរគុណ។ អម្បាញ់មិញនេះលោកបានឆ្លើយថាមានការកោះហៅ ហើយបន្ទាប់មកមានការសម្លាប់។ ក្នុងចំណោមអ្នកដែលប្រព្រឹត្តកំហុសធ្ងន់ តើត្រូវបាននាំទៅសម្លាប់ចោលដែរឬទេ? ខ្ញុំមិនសំដៅថាមន្ទីរហ្នឹងផ្ទាល់ជាអ្នកសម្លាប់ទេ គឺថាអាចមានសមាជិកកងពល៨០១ ហ្នឹងអ្នកនាំយកទៅសម្លាប់ចោលនៅពេលដែលលោកជាប្រធានមន្ទីរនោះ?

**ឆ៖** រឿងការសម្លាប់ចោលនេះ បើនិយាយពីបទបញ្ជារបស់ខ្ញុំផ្ទាល់តែម្តងមិនដែលបញ្ជាឲ្យសម្លាប់ទេ ព្រោះវាមិនមែនជាជនឧក្រិដ្ឋទាំងស្រុងទេអ្នកទាំងអស់នេះ ទោះបីអ្នកជាប់ច្រវាក់អីក៏ដោយ វាអត់ទាន់បានឯកសារពិតប្រាកដបាទ។ ប៉ុន្តែការគ្រោះថ្នាក់រវាងពីរបីនាក់នេះ មួយធ្វើឲ្យគ្រោះថ្នាក់ដល់កងការពារខ្ញុំម្នាក់ វាសងសឹកទៅ វាប្រកួតប្រជែងគ្នា វ៉ៃអាពេទ្យហ្នឹងទាល់តែស្លាប់ ម្នាក់ទៅ។ អាហ្នឹងវាមានកំហឹងតបវិញអីចឹងទេ។ ពីរទៀត មនុស្សដែលនៅក្នុងច្រវាក់ហ្នឹងរត់ បាទដេញតាមទៅវាអាចទៅវាពិបាក និងតឹងតែងទៅ វាមានប្រតិកម្មបណ្តោយ ឈានទៅស្លាប់ទៅ។ ហើយក្រៅពីហ្នឹង អត់មានថាយកមនុស្សដែលលែងឲ្យធ្វើពលកម្ម ធ្វើអីផ្សេងៗ យកទៅវ៉ៃចោលចេះៗនេះអត់ទេ បាទ អត់មានបានសម្រេចធ្វើទេ។ ដោយឡែកតែរឿងពួកក្រុម៦នាក់ អាហ្នឹងបានបទបញ្ជាទៅគឺឲ្យសម្លាប់ដែរ ស៊ូសារឿន ដែរ ជនក្រៅប្រទេស។

[១៥:៥៥:៥៨]

**ស៖** នៅក្នុងកំណត់ហេតុទី១ គឺ E3/405 នៅចម្លើយ១៦ លោកបានឆ្លើយ ខ្ញុំសូមដកស្រង់ "ការសម្លាប់អ្នកទោសមួយចំនួន ដែលយើងមិនអាចកែប្រែបាននោះ គឺថាភាគច្រើន គឺធ្វើឡើងនៅចុងឆ្នាំ១៩៧៨"។ ក្រៅពីមនុស្សប្រាំមួយនាក់ដែលលោកបានលើកឡើងនោះ តើមានអ្នកណាផ្សេងទៀតដែលត្រូវបានទទួលនៅមន្ទីររបស់លោក ហើយត្រូវបានចម្លើយចោលដែរឬទេ?

**ឆ៖** បាទ ដូចហេតុផលខ្ញុំបានលើកឡើងវាមានបីនាក់ ដែលបីនាក់ទៀតបន្ថែម ដោយវាមានបញ្ហារឹងរូសអី មានប្រតិកម្ម នាំឲ្យគ្រោះថ្នាក់ដល់កងការពារខ្ញុំនេះម្នាក់។ ខ្ញុំរៀបអម្បាញ់មិញនេះបាទ។

ក្រៅពីហ្នឹងអត់មានយកទៅវ៉ៃប្រហារ ដោយគ្មានការពិចារណាអី អត់មាន។

**ស៖** ក្នុងឋានៈជាប្រធានមន្ទីរអប់រំកែប្រែនោះ គោលបំណងរបស់លោកគឺថាទាញយកចម្លើយសារភាពរបស់អ្នកទោស។ តើលោកមានទទួលបញ្ជាពីថ្នាក់លើនៃកងពល៨០១ ពាក់ព័ន្ធទៅនឹងការធ្វើទារុណកម្មទៅលើអ្នកដែលមិនព្រមឆ្លើយនោះ លោកមានបានទទួលបញ្ជាថាឲ្យធ្វើទារុណកម្មទេ ប្រសិនបើអ្នកទោសមិនឆ្លើយនោះ?

[១៥:៥៧:៤៤]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះការតាំងសំណួរបែបនេះ ដោយសារថាវាមិនស្ថិតនៅក្នុងវិសាលភាពនៅក្នុងរចនាសម្ព័ន្ធនោះទេ។ នេះគឺនិយាយអំពីការកាប់សម្លាប់និងមន្ទីរសន្តិសុខដែលខ្ញុំយល់ឃើញថាវាស្ថិតនៅក្រៅវិសាលភាពនេះ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណ ខ្ញុំសូមឆ្លើយតបលោកប្រធាន។ ខ្ញុំបានបញ្ជាក់ហើយ ថាសំណួររបស់ខ្ញុំនោះ គឺចង់ថាតើមានការបញ្ជូនបញ្ជាពីថ្នាក់លើកងពល៨០១ ដែរឬទេ។ នេះជាការទំនាក់ទំនងផ្ទៃក្នុងរវាងកងពល៨០១ និងមន្ទីរសន្តិសុខ។ ដូច្នេះ ខ្ញុំចង់ដឹងថាតើមានបញ្ជាដែរឬទេ? ហើយខ្ញុំចង់ដឹងថាបន្ទាប់មកទៀតនោះ យើងអាចនឹងពិនិត្យមើល រវាង៨០១ ហើយនិងមន្ទីរសន្តិសុខ។ ដូច្នេះវាពាក់ព័ន្ធទៅនឹងមធ្យោបាយទំនាក់ទំនងការងាររវាងអង្គភាពទាំងពីរនេះ ដូច្នេះខ្ញុំគិតថា សំណួរនេះគួរតែអនុញ្ញាតឲ្យសួរលោកប្រធាន។

[១៥:៥៨:៥៨]

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:00:00]

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញា គប្បីរៀបចំសំណួរឡើងវិញ ហើយសំណួរកម្រិតត្រឹមតែបង្ហាញអំពីប្រព័ន្ធទំទាក់ទំនងការងារបានហើយ ជៀសវាងការតាំងសំណួរស៊ីជម្រៅរហូតដល់ទៅ

សកម្មភាពជាក់ស្តែងនៃដំណើរការប្រព្រឹត្តទៅរបស់មន្ទីរសន្តិសុខអូរកន្សែងនោះ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្តាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្តាឯល៖**

**ស៖** លោកសាក្សី ខ្ញុំចង់សួរលោកពាក់ព័ន្ធទៅនឹងការដោះលែងអ្នកទោសនៅមន្ទីរសន្តិសុខរបស់លោក។ តើលោកមិនមានសិទ្ធិសម្រេចដោះលែងទេ មែនទេ គឺថាមាន គឺថាទាល់តែលេខាកងពល៨០១នោះ ទើបអាចមានសិទ្ធិសម្រេចដោះលែងអ្នកទោសណាម្នាក់នោះ។ តើអ៊ីចឹងមែនទេ?

[១៦:០១:០៩]

**លោក នោម សែ៖**

**ឆ៖** បាទ ពិតប្រាកដហើយ។

**ស៖** ពាក់ព័ន្ធទៅនឹងការសម្រេច ពាក់ព័ន្ធទៅនឹង កែវ សារឿន នោះ លោកថា លោកធ្វើការសង្ខេបចម្លើយសារភាពដើម្បីឱ្យមានការសម្រេច។ នៅពេលដែលមានការប្រជុំជាមួយគាត់នោះ តើមានធ្លាប់និយាយថា "ពេលខ្លះនោះ គាត់ត្រូវសួរយោបល់ពីមជ្ឈិមបក្សនៅភ្នំពេញ ហើយត្រូវរង់ចាំការសម្រេចពីមជ្ឈិមបក្សមកនោះ មុននឹងសម្រេចអំពីជោគវាសនារបស់អ្នកទោសណាម្នាក់នោះ"។ គាត់មានធ្លាប់ប្រាប់អ៊ីចឹងដល់លោកទេ?

**ឆ៖** អានេះ ច្បាប់នេះគេលាក់ការជាមូលដ្ឋាន គេវាមិនអាចបរិយាយប្រាប់យើងថាថ្នាក់ក្រោមកម្រិតនេះបានទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណតំណាងសហព្រះរាជអាជ្ញា។ អរគុណសាក្សី។

បាទ កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទទី១៤ ខែមករា ឆ្នាំ២០១៣ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយនៅថ្ងៃចន្ទ ទី១៤ ដើមសប្តាហ៍ក្រោយនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីឈ្មោះ នោម សែ បន្តបញ្ចប់។ សូមភាគី និងសាធារណជនជ្រាប។

[១៦:០២:៣៩]

លោក ឆោម សែ ការស្តាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មរបស់លោកនៅថ្ងៃចន្ទ ទី១៤ ខែមករា ឆ្នាំ២០១៣ គឺថ្ងៃចន្ទសប្តាហ៍ក្រោយនេះទៀត។ ដូច្នេះ អង្គជំនុំជម្រះកោះអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃចន្ទសប្តាហ៍ក្រោយទៀតដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ ហើយមេធាវីប្រឹក្សាសាក្សីសូមអញ្ជើញមកចូលរួមជាមួយនឹងសាក្សីរូបនេះដែរ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សី និងជំនាញ ក្នុងការជូនសាក្សីនេះវិលត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃចន្ទដើមសប្តាហ៍ក្រោយ នៅវេលាម៉ោងប្រាំបួន។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូប ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងឲ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃចន្ទសប្តាហ៍ក្រោយឲ្យបានមុនម៉ោងប្រាំបួន។ ដោយឡែក លោក អៀង សារី ឲ្យនាំមកគាត់ត្រឹមបន្ទប់ដែលរៀបចំជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៤ នាទី)*